សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការការពារពូជដំណាំនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ជា សុវណ្ណរតនៈ**

**ក. ឃី លីហួ**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឃឹម គិរី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ជា សុវណ្ណរតនៈ** និងនាងខ្ញុំ **ឃី លីហួ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសំដែងនូវកត្តញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **នឹង សារ៉ាវុធ** និងអ្នកម្តាយ **ជា សុផានី**

លោកឪពុក **ឃី ហ៊ាង** និងអ្នកម្តាយ **ខាន់ អ៊ីម**

កូនៗសូមថ្លែងនូវអំណរព្រះគុណ និងអរគុណដល់លោកអ្នកមានគុណដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀបប្រដៅ ព្រមទាំងលះបង់គ្រប់បែបយ៉ាង ទាំងពេលវេលា ទាំងកម្លាំងកាយចិត្ត បញ្ញាស្មារតី ផ្គត់ផ្គង់ និងលើកទឹកចិត្តគ្រប់បែបយ៉ាង តាំងពីកូនចាប់កំណើតមក រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ នៃថ្នាក់ឧត្តមសិក្សា និងទទួលបានជោគជ័យគួរឲ្យមានមោទនៈ។ គុណូបការៈ និងព្រហ្មវិហារធម៌របស់អ្នកមានគុណចំពោះយើងដែលជាកូនៗមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទាំងនេះធ្វើឲ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយករុណាធិគុណនេះ នឹងស្ថិតនៅក្នុងដួងព្រលឹងកូនជារៀងដរាបគ្មានថ្ងៃសូន្យឡើយ។

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយចណ្ណា** ព្រមទាំងព្រឹត្តបុរស លោក លោកស្រីដែលជាសាស្ត្រាចារ្យ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងលោកគ្រូ អ្នកគ្រូដែលបានផ្តល់ចំណេះដឹងដែលជាប្រទីបបំភ្លឺសម្រាប់ជីវិតយើងខ្ញុំ ចាប់តាំងពីបឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ។

លោកសាស្ត្រចារ្យ **បណ្ឌិត ឃឹម គីរី** ដែលជាសាស្ត្រាចារ្យណែនាំនៅក្នុងការធ្វើឲ្យមាននូវកិច្ចដំណើរការនៃការតាក់តែងឯកសារនេះប្រកបដោយលទ្ធផលជាផ្លែផ្កា ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ប្រឹក្សា និងអនុសាសន៍ល្អៗរហូតធ្វើឲ្យស្នាដៃនេះ មានអត្ថន័យល្អគ្រប់គ្រាន់ព្រមទាំងបានផ្តល់នូវបទពិសោធន៍ការងារល្អៗដែលធ្វើឲ្យកិច្ចប្រតិបត្តិការនេះប្រកបដោយភាពរលូន។

ជាចុងបញ្ចប់យើងខ្ញុំសូមជូនពរ និងបួងសួងដល់វត្ថុសក្តិសិទ្ធិនៅក្នុងលោកជួយថែរក្សាលោកអ្នកមានគុណ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ កុំបីឃ្លៀតឃ្លាឡើយ

# អារម្ភកថា

យើងខ្ញុំទាំងពីរ សូមគោរពចំពោះលោកឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ មិត្តអ្នកអាន និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និងសេចក្តីស្រឡាញ់រាប់អាន។

យើងខ្ញុំទាំងពីររូប គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៨-២០១៩ ដែលត្រូវបានប្រធានការិយាល័យស្រាវជ្រាវ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយបានអនុញ្ញាតឲ្យយើងខ្ញុំស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា លើប្រធានបទដែលយើងខ្ញុំបានស្នើសុំ« ការការពារពូជដំណាំនៅកម្ពុជា» ដើម្បីចងក្រងជាឯកសារ និងសម្រាប់តម្កល់ទុកក្នុងបណ្ណាល័យសម្រាប់មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ទៅលើយន្តការនៃការការពារពូជដំណាំថ្មីនៅព្រះរាជាណាចក្រកម្ពុជា។

សារណាបញ្ចប់ការសិក្សានេះ គឺជាផ្នែកមួយជួយឲ្យមិត្តអ្នកអានទទួលបានចំណេះដឹងបន្ថែមខាងផ្នែកច្បាប់ ជាពិសេស គឺជួយឲ្យអ្នកទាំងអស់គ្នាទទួលបាននូវពុទ្ធិបន្ថែមដែលទាក់ទងនឹងការការពារ និង លក្ខខណ្ឌដើម្បីទទួលបាននូវការការពារពូជដំណាំនៅកម្ពុជា។

ចំណេះដឹងគឺជាអំណាច និងជាអាវុធដ៏មុតស្រួច សម្រាប់ធ្វើឲ្យមនុស្សមិនឆាប់ចាញ់បោកគេ ធ្វើឲ្យមនុស្សមានភាពក្លាហាន និងចេះដោះស្រាយរាល់បញ្ហាដែលកើតមាន។ ចំណេះវិជ្ជាគឺជាពន្លឺបំភ្លឺផ្លូវ ដែលនាំឲ្យយើងដើរតាមផ្លូវត្រូវ។ ប្រទេសជាតិមួយមានការរីកចម្រើនលូតលាស់ និងមានការអភិវឌ្ឍន៍បានលុះត្រាតែសិស្ស-និស្សិត ឬប្រជាជននៃប្រទេសនោះមានចំណេះដឹងខ្ពង់ខ្ពស់ មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងបានល្អ មានសណ្តាប់ធ្នាប់ល្អ និងមានសុខសន្តិភាព។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តម លោកលោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងយកចិត្តទុកដាក់ក្នុងការអានសារណារបស់យើងខ្ញុំ ហើយសូមជូនពរឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

ទំព័រ

**អក្សរកាត់** ............................................................ iv

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១

## ស្ថាប័ននានាដែលទាក់ទងនឹងការអនុវត្តការការពារបង្កាត់ពូជថ្មីនៃដំណាំ

**ផ្នែកទី១ ៖ ស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងការការពារការបង្កាត់ពូជដំណាំ** ... ៤

**កថាខណ្ឌទី១ ៖ សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី** ( UPOV ) ............ ៤

ក. សញ្ញាណទូទៅនៃសហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ............ ៤

ខ. រចនាសម្ព័ន្ធរបស់សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ............ ៦

គ. គោលការណ៍ទូទៅដើម្បីក្លាយជាសមាជិករបស់ UPOV ............ ៨

**កថាខណ្ឌ ២ ៖ វេទិកាការពារការបង្កាត់ពូជដំណាំអាស៊ីបូព៌ា**( EAPVP ) ............ ១១

**កថាខណ្ឌ ៣ ៖ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក** ( WIPO ) ............ ១២

ក. ប្រវត្តិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ............ ១២

ខ. គោលបំណង និងសកម្មភាពរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO ............ ១៣

គ. រចនាសម្ព័ន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ............ ១៥

**កថាខណ្ឌ ៤ ៖ អង្គការពាណិជ្ជកម្មពិភពលោក** ( WTO ) ............ ១៩

**កថាខណ្ឌ ៦ ៖ ក្រុមប្រឹក្សា** TRIPS ............ ២០

ក. តួនាទីក្នុងការត្រួតពិនិត្យ (Monitoring) ............ ២០

ខ. តួនាទីក្នុងការពិគ្រោះយោបល់ (Consultation) ............ ២១

គ. សហប្រតិបត្តិការខាងបច្ចេកទេស (Technical Cooperation ) ............ ២១

ឃ. ការពិនិត្យឡើងវិញ និងការចរចារនានាស្តីពីកម្មវត្ថុជាក់លាក់........................................២១
ង. ការពិនិត្យឡើងវិញនៃកិច្ចព្រមព្រៀង TRIPS........................................................២២
**ផ្នែកទី២ ៖ ស្ថាប័នជាតិដែលអនុវត្តការការពារការបង្កាត់ពូជដំណាំ**.................២២
**កថាខណ្ឌ១ ៖ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា** ........................................២២
**កថាខណ្ឌ ២ ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍**.........២៤
**កថាខណ្ឌ ៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**............................................២៥

## ជំពូកទី២

## ការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា

**ផ្នែកទី១៖ ការរៀបចំការការពារពូជដំណាំនៅកម្ពុជា** ............................................២៧
**កថាខណ្ឌ១៖ ការរៀបចំលិខិតបទដ្ឋាននានាស្តីពីការការពារពូជដំណាំ** .......................២៧
**កថាខណ្ឌ ២៖ ការបណ្តុះបណ្តាលធនធានមនុស្ស**.......................................................... ២៩
**ផ្នែកទី ២៖ យន្តការនៃការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា**....................៣១
**កថាខណ្ឌ ១៖ សញ្ញាណទូទៅនៃការការពារពូជដំណាំ** ................................................ ៣១
**កថាខណ្ឌ២៖ លក្ខខណ្ឌនៃការការពារ**........................................................................៣៥
ក. បុគ្គលដែលអាចស្នើសុំការការពារពូជថ្មីនៃដំណាំ............................................................៣៥
ខ. លក្ខខណ្ឌគតិយុត្ត .......................................................................................................៣៦
គ. លក្ខខណ្ឌទម្រង់..........................................................................................................៣៩
**កថាខណ្ឌ៣៖ អានុភាពនៃការការពារ**...........................................................................៤៤
ក.អត្ថន័យនៃសិទ្ធិ .........................................................................................................៤៤
ខ.សិទ្ធិអនុញ្ញាតឲ្យតតិយជនធ្វើអាជីវកម្ម .......................................................................៤៥
គ.សិទ្ធិហាមឃាត់មិនឲ្យតតិយជនធ្វើអាជីវកម្ម ................................................................. ៤៦
**កថាខណ្ឌ៣ ៖ ការបញ្ចប់ មោឃភាព និងការលុបចោល** ............................................. ៤៨

១.ការបញ្ចប់ ........................................................................................................ ៤៨

២.ការប្រកាសមោឃភាពនៃសិទ្ធិ ..................................................................................៤៩

៣.ការលុបសិទ្ធិ .......................................................................................................៤៩

**សេចក្តីសន្និដ្ឋាន** .....................................................................................................៥0

**អនុសាសន៍** .......................................................................................................៥៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

១. ASSINSEL: International Association of Plant Breeders for the Protection of Plant Varieties

សមាគមអ្នកបង្កាត់ពូជដំណាំសម្រាប់ការការពារពូជដំណាំ

២.APSA: American Political Science Association

សមាគមន៍វិទ្យាសាស្ត្រនយោបាយអាមេរិក

៣. BMT: Working Group on Biochemical and Molecular Technique and DNA-Profiling in Particular

ក្រុមការងារលើបច្ចេកទេសជីវគីមី និងម៉ូលេគុល និងការធ្វើទម្រង់ DNA លម្អិត

៤. BAT: Agreement between the United States of America and the kingdom of Cambodia on Trade Relations and Intellectual Property Rights Protection

កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក នឹងព្រះរាជាណាចក្រកម្ពុជា ស្តីពីការការពារកម្មសិទ្ធិបញ្ញា

៥. BTA: Bilateral Trade Agreement

កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី

៦. CAJ: Administrative and Legal Committee

គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម

៧.CAJ-AG: Administrative and Legal Committee-Advisory Group

ក្រុមប្រឹក្សាអមគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម

៨.CCIAR: Consultative Group on International Agricultural Research

ក្រុមប្រឹក្សាពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ

៩. DUS: Distinct, uniform and stable (Plant variety)

ភាពប្លែក ឯកសណ្ឋាន និងស្ថេរភាព

១០. IP: Intellectual property

កម្មសិទ្ធិបញ្ញា

១១. IPP: Intellectual Property Protection

ការការពារកម្មសិទ្ធិបញ្ញា

១២. IPPC: International Plant Protection Convention

អនុសញ្ញាស្តីពីការការពារដំណាំអន្តរជាតិ

១៣. IPRs: Intellectual property rights

សិទ្ធិកម្មសិទ្ធិបញ្ញា

១៤.ISTA: International Seed Testing Association

សមាគមធ្វើតេស្តសាកល្បងពូជដំណាំអន្តរជាតិ

១៥. PBRs: Plant Breeders Rights

សិទ្ធិអ្នកបង្កាត់ពូជដំណាំ

១៦. PVP: Plant Variety Protection

ការការពារពូជដំណាំ

១៧. TC: Technical Committee

គណៈកម្មាធិការបច្ចេកទេស

១៨. TC-EDC: Technical Committee-Enlarged Editorial

គណៈកម្មាធិការបច្ចេកទេស-គណៈកម្មាធិការគ្រប់គ្រងបទវិចារណកថា

១៩.TRIPS: Trade Related Aspects of Intellectual Property Rights

កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

២០. TWA: Technical Working Party for Agricultural Crops

ក្រុមការងារសម្រាប់ដំណាំកសិកម្ម

២១. TWF: Technical Working Party for Fruit Crops

ក្រុមការងារបច្ចេកទេសសម្រាប់ដំណាំហូបផ្លែ

២២. TWO: Technical Working Party for Ornamental Plant and Forest Trees

ក្រុមការងារបច្ចេកទេសសម្រាប់រុក្ខជាតិតុបតែងលម្អ និងព្រៃឈើ

២៣. TWP: Technical Working Parties

ក្រុមការងារបច្ចេកទេស

២៤. TWV: Technical Working Party of Vegetables

ក្រុមការងារបច្ចេកទេសសម្រាប់បន្លែ

២៥. UPOV: International Convention of the Protection of Plant and Varieties

អនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ

២៦. WIPO: World Intellectual Property Organization

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ដំណើរការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចពិភពលោកកំពុងមានសន្ទុះយ៉ាងខ្លាំងក្លានាពេលបច្ចុប្បន្ន នឹងទៅពេលអនាគតទន្ទឹមនឹងនេះក៏មានយន្តការរបស់អង្គការជាច្រើនដែលផ្តោតលើបញ្ហានេះដូចជាអង្គការពាណិជ្ជកម្មពិភពលោក(WTO) ក៏ដូចជាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានគោលដៅបង្កើតឲ្យបាននូវបែបបទនៃការប្រកួតប្រជែងនៅក្នុងទីផ្សារសេរី ក៏ដូចជាជម្រុញនូវការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាផងដែរ។

កម្មសិទ្ធិបញ្ញាចែកជាពីរផ្នែកធំៗគឺ កម្មសិទ្ធិឧស្សាហកម្ម និង កម្មសិទ្ធិអ្នកនិពន្ធ។ កម្មសិទ្ធិបញ្ញាតាមន័យទូលាយ គឺជាសិទ្ធិតាមផ្លូវច្បាប់ដែលកើតចេញពីសកម្មភាពបញ្ញារបស់មនុស្សក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ អក្សរសាស្ត្រ និង សិល្បៈ។ ការការពារកម្មសិទ្ធិបញ្ញាមានច្រើនទម្រង់ដូចជាប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម ម៉ាក ម៉ូដែលមានអត្ថប្រយោជន៍ ម៉ាក់សំគាល់ទីតាំងភូមិសាស្ត្រ ការការពារការបង្កាត់ពូជថ្មីនៃដំណាំជាដើម ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ប្រទេសជាច្រើននៅលើពីភពលោកមានការយកចិត្តទុកដាក់យ៉ាងខ្លាំងនោះគឺការការពារការបង្កាត់ពូជថ្មីនៃដំណាំ ដោយសារតែពិភពលោកកំពុងប្រឈមមុខវិបត្តិស្បៀងអាហារ និងវិបត្តិបរិស្ថានផងដែរ។ ដូច្នេះ ដើម្បីការលើកទឹកចិត្តទៅដល់អ្នកបង្កាត់ពូជថ្មីនៃដំណាំតាមរយៈការការពារតាមផ្លូវច្បាប់គឺជារឿង ដែលចាំបាច់ត្រូវធ្វើ នៅខណៈពេលដែលពិភពលោកកំពុងប្រឈមនឹងបញ្ហាផ្សេងៗដូចជា ការប្រែប្រួលអាកាសធាតុ បញ្ហាសន្តិសុខស្បៀងអាហារ ក៏ដូចជាបញ្ហាប្រឈមជាច្រើនទៀតទាក់ទងនឹងបរិស្ថានផងដែរ។

ជាការពិតណាស់ការទាមទារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំមានតាំងពីយូរយារណាស់មកហើយ មិនមែនទើបកើតមានពេលថ្មីៗនេះទេ រីឯនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្មសិទ្ធិបញ្ញាបានចាប់កំណើតមានតាំងពីក្នុងទស្សវត្សទី៦០ និង ៧០ មកម្ល៉េះ ហើយម៉ាកមួយចំនួនក៏បានទទួលកិច្ចការពារនៅក្នុងកំឡុងពេលនោះដែរ ដូចជា ម៉ាក PERTUSSIN ស្ថិតនៅក្នុងជំពូកទី៥ ដែលមានលេខដាក់ពាក្យ ១៩៧៣ នៅក្នុងឆ្នាំ១៩៦៦ ហើយ ម៉ាក RIBENA ស្ថិតក្នុងជំពូកទី៥ និង៣២ ដែលមានលេខដាក់ពាក្យ១០៣១៨ នៅក្នុងឆ្នាំ១៩៧៣។ ជាអកុសលប្រទេសកម្ពុជាបានជួបនូវវិបត្តិសង្គ្រាមក្នុងស្រុកដ៏ធ្ងន់ធ្ងរ ដែលធ្វើអោយវិស័យកម្មសិទ្ធិបញ្ញាត្រូវបានបោះបង់ចោលអស់រយៈពេលជិត២ទសវត្ស។ ដោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានចាប់ផ្តើមស្តារហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិឡើងវិញ ដែលនាំអោយវិស័យកម្មសិទ្ធិបញ្ញា ត្រូវបានដំណើរការឡើងវិញ។ ជាលទ្ធផល នៅឆ្នាំ១៩៩១ ការិយាល័យពាណិជ្ជសញ្ញា ត្រូវបានបង្កើតឡើងនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចទទួលចុះបញ្ជី និងការពារពាណិជ្ជសញ្ញា និងទទួលបានការគាំទ្រ និងជួយជ្រោមជ្រែងបណ្តុះបណ្តាលផ្នែកបច្ចេកទេសពីប្រទេសនានា ជាពិសេស អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (World Intellectual Property Organization) ដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។

ដោយហេតុថាកម្ពុជា បានប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីដូចប្រទេសជាច្រើនទៀតលើពិភពលោក [1] ទើបយើងចាប់ផ្ដើមយកចិត្តទុកដាក់អំពីបញ្ហានេះ និងស្របពេលដែលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥។ ការចូលជាសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកត្រូវគោរពលក្ខន្តិកៈ និង ច្បាប់មួយចំនួន ម៉្យាងវិញទៀតរាល់សមាជិកទាំងអស់សុទ្ធតែមានច្បាប់ស្ដីពីកម្មសិទ្ធិឧស្សាហកម្ម ឬកម្មសិទ្ធិបញ្ញា ដើម្បីងាយស្រួលគ្រប់គ្រងការធ្វើពាណិជ្ជកម្មផ្សេងៗ។ អំឡុងពេលសតវត្សទី២០ ប្រទេសកម្ពុជាបានចាប់ផ្ដើមគិតគូពីបញ្ហានេះ កាលនោះប្រទេសកាណាដាបានជួយរៀបចំសេចក្ដីព្រៀងច្បាប់ចំនួន០៣ដល់កម្ពុជា ក្រោយមកបានយកសេចក្ដីព្រាងច្បាប់នេះទៅជូនអង្គការកម្មសិទ្ធិបញ្ញាពិភពលោកធ្វើសារជាថ្មី ដើម្បីឲ្យស្របតាមកិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនិងដើម្បីតម្រូវនឹងលក្ខន្តិកៈរបស់អង្គការពាណិជ្ជកម្មលោកកម្ពុជាក៏បានរៀបចំឲ្យមានជាហូរហែរច្បាប់ស្ដីពីម៉ាក់ ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ សិទ្ធិប្រហាក់ប្រហែល ច្បាប់ស្ដីពីម៉ាក់សំគាល់ទីតាំងភូមិសាស្ត្រ ច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិបង្កាត់ពូជដំណាំ។

ក្រោយពេលដែលប្រទេសកម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជកម្មពិភពលោក ក៏បានក្លាយជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងTRIPS។ មាត្រា ២៧.៣ ក្នុងកិច្ចព្រមព្រៀងTRIPS បានចែងយ៉ាងច្បាស់ពីបទដ្ឋាននៃការការពារពូជដំណាំ " ***រដ្ឋសមាជិកទាំងឡាយត្រូវផ្ដល់ការការពារសម្រាប់ប្រភេទពូជដំណាំផ្សេងៗ ទោះតាមរយៈប្រកាសនីយបត្រតក្កកម្ម ឬដោយប្រព័ន្ធដោយឡែកដ៏មានប្រសិទ្ធភាពមួយ ឬក៏ដោយការរួមបញ្ចូលគ្នាណាមួយនៃប្រព័ន្ធទាំងពីរ*** " ប្រទេសកម្ពុជាក៏មិនខុសពីបណ្ដាប្រទេសដទៃទៀតឡើយ គឺមានជាប់កាតព្វកិច្ចអនុវត្តតាមកិច្ចព្រមព្រៀង ព្រមគ្នានោះកម្ពុជាក៏បានបង្កើតនូវបណ្ដាលិខិតបទដ្ឋានគតិយុត្តជាតិនានាដែលទាក់ទងនឹងការការពារកម្មសិទ្ធិបញ្ញា ដែលក្នុងនោះរួមមានការរៀបចំ និងអនុម័តច្បាប់ដែលគ្រប់គ្រងលើការការពារពូជថ្មីនៃដំណាំផងដែរ។ ក្រៅពីកាតព្វកិច្ចក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនេះ កម្ពុជាក៏មានគោលបំណងក្នុងការលើកស្ទួយវិស័យកសិកម្មដោយការលើកទឹកចិត្តដល់អ្នកបង្កើតពូជដំណាំថ្មីៗ តាមរយៈការបង្កើតឲ្យមានយន្តការនៃការការពារកម្មសិទ្ធិបញ្ញាលើពូជដំណាំដែលបានត្រូវបង្កើតថ្មីទាំងនោះ។

លើសពីនេះទៅទៀតរដ្ឋាភិបាលក៏បានអនុវត្តនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ ប្រសិទ្ធិភាពទាំងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីធានាកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងរក្សាបាននូវនិរន្តរភាពបរិស្ថាន រួមមាន ផ្នែកដំណាំកសិកម្ម ផលិតកម្មនិងបសុព្យាបាលដំណាំកៅស៊ូ ជលផលនិងវារីវប្បកម្ម និងព្រៃឈើ។ ទន្ទឹមនឹងនេះវិស័យកសិកម្ម មានសក្ដានុពល

[1] មាត្រា៥៦ វាក្យខ័ណ្ឌទី១ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

កាលានិវត្តភាព និងមានឧត្តមភាពប្រៀបធៀបសម្រាប់ទីផ្សារកសិផល និងជាវត្ថុធាតុដើមនៅក្នុងតំបន់ និងនៅលើសាកលលោកដូចជា ផលិតផលស្រូវអង្ករ និងកសិផលនានាមាន ដំឡូងមី ពោត សណ្តែកបាយ សណ្តែកសៀង ជាដើម។

សង្ឃឹមថាប្រធានបទមួយនេះនឹងមានលក្ខណៈពិស្តារ និងស៊ីជម្រៅជម្រុញទិដ្ឋភាពនៃការអនុវត្តកម្មសិទ្ធិបញ្ញានៅកម្ពុជា ក៏ដូចជាសិទ្ធិនៃការការពារជូនទៅដល់ម្ចាស់ពូជដំណាំ ដើម្បីឆ្លើយតបទៅនឹងចំណោទគតិយុត្តដូចជា៖ តើហេតុអ្វីបានជាបង្កើតច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំ? តើមានស្ថាប័នអន្តរជាតិណាដែលពាក់ព័ន្ធ? តើស្ថាប័នជាតិណាដែលពាក់ព័ន្ធ? តើការបង្កើតបទដ្ឋានគតិយុត្តនេះបានហុចផលអ្វីខ្លះជូនដល់ម្ចាស់ពូជដំណាំថ្មី?

គោលបំណងនៃកិច្ចការស្រាវជ្រាវលើប្រធានបទ ការការពារការបង្កាត់ពូជដំណាំនៅកម្ពុជាចាប់ពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ននេះ គឺ ទីមួយ(១) ដើម្បីយល់ដឹងអំពីសិទ្ធិរបស់ម្ចាស់ពូជដំណាំថ្មីនៅកម្ពុជា ទីពីរ(២) ដើម្បីយល់ច្បាស់ពីបទដ្ឋានគតិយុត្តទាំងឡាយដែលបានចែងក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងនានា។

អត្ថប្រយោជន៍នៃកិច្ចការស្រាវជ្រាវនេះនិងមានតម្លៃខ្ពង់ខ្ពស់ ឥតគណនាសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ និងអ្នកអានទាំងឡាយ ឲ្យយល់យ៉ាងច្បាស់អំពីបទដ្ឋានគតិយុត្តដែលទាក់ទងនឹងការការពារការបង្កាត់ពូជថ្មី អ្វីដែលសំខាន់បំផុតនោះគឺដើម្បីជំរុញឲ្យកសិកម្មកម្ពុជាឲ្យមានការរីកចម្រើន ដោយការបង្កើតនូវដំណាំថ្មីដែលមិនធ្លាប់មានពីមុនមក។

ចំពោះរចនាសម្ព័ន្ធនៃប្រធានបទស្រាវជ្រាវមួយនេះ ត្រូវបានចេនាឡើងដោយមានការបែងចែកជា ២ជំពូក ទី១ បង្ហាញ និងវិភាគលម្អិតទៅលើ “*ស្ថាប័ននានាដែលទាក់ទងនឹងការអនុវត្តការការពារការបង្កាត់ពូជថ្មីនៃដំណាំ* ” ចំណែកឯ ជំពូកទី២ នឹងបង្ហាញពី “*យន្តការនៃការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា* ”

# ជំពូកទី១

# ស្ថាប័ននានាដែលទាក់ទងនឹង
# ការអនុវត្តការការពារបង្កាត់ពូជថ្មី
# នៃដំណាំ

# ជំពូកទី១
# ស្ថាប័ននានាដែលទាក់ទងនឹងការអនុវត្តការការពារបង្កាត់ពូជថ្មីនៃដំណាំ

ដើម្បីឲ្យមានដំណើរការបានល្អក្នុងការការពារពូជថ្មីនៃដំណាំគឺត្រូវពឹងផ្អែកទៅលើយន្តការក្នុងការការពារ ប្រសិនជាគ្មានយន្តការនៃការការពារទេ ដំណើរការនៃការការពារនឹងមិនអាចមានប្រសិទ្ធភាពបានឡើយ។ តើមានយន្តការការពារអ្វីខ្លះ ? កើតឡើងយ៉ាងដូចម្ដេច? ចំពោះយន្តការនៃការការពារមិនអាចកើតមានឡើងដោយខ្លួនឯងបានទេ គឺទាល់តែមានស្ថាប័នផ្សេងៗជាអ្នកបង្កើតឡើង ស្ថាប័នទាំងនោះរួមមានស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិ ដែលស្ថានប័នទាំងនោះមានតួនាទីក្នុងការបង្កើតឲ្យមាននូវយន្តការក្នុងការត្រួតពិនិត្យ និងការផ្ដល់ជាជំនួយក្នុងការជំរុញដល់ការអនុវត្តយន្តការនៃការការពារ។ ដោយមើលឃើញថាស្ថាប័នទាំងនេះដើរតួនាទីសំខាន់ក្នុងការការពារ យើងនឹងធ្វើការបកស្រាយពីស្ថាប័នទាំង ២ នេះ ដោយលើកយកផ្នែកទី១ បកស្រាយអំពី " **ស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងការការពារការបង្កាត់ពូជដំណាំ** " និងផ្នែកទី២ បកស្រាយអំពី "**ស្ថាប័នជាតិដែលពាក់ព័ន្ធនឹងការការពារពូជដំណាំ** "។

## ផ្នែកទី១ ៖ ស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងការការពារការបង្កាត់ពូជដំណាំ

នៅក្នុងផ្នែកនេះ យើងនឹងលើកយកមកសិក្សាអំពី បណ្ដាស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងការបង្កាត់ពូជថ្មីនៃដំណាំ ព្រមជាមួយស្ថាប័នដែលរួមចំណែកក្នុងការបង្កើតឲ្យមានការការពារការបង្កាត់ពូជថ្មីនៃដំណាំ ដែលក្នុងនោះរួមមាន សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី UPOV (កថាខណ្ឌទី១) វេទិកាការពារការបង្កាត់ពូជដំណាំអាស៊ីបូព៌ា EAPVP (កថាខណ្ឌទី២) អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO (កថាខណ្ឌទី៣) អង្គការពាណិជ្ជកម្មពិភពលោក WTO (កថាខណ្ឌទី៤) និង ក្រុមប្រឹក្សាTRIPS (កថាខណ្ឌទី៥)។

### កថាខណ្ឌទី១ ៖ សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី

### ក.សញ្ញាណទូទៅនៃសហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី

សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ហៅកាត់ថា UPOV ជាអង្គការអន្តររដ្ឋាភិបាលដែលមានភាពឯករាជ្យ ដែលមានទីស្នាក់ការនៅទីក្រុង ហ្សឺណែវ ប្រទេសស្វីស ( Geneva. Switzerland) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦១ ដោយអនុសញ្ញាអន្តរជាតិស្ដីពីការការពារពូជថ្មីនៃដំណាំ។ អនុសញ្ញា UPOV ត្រូវបានកែប្រែនៅទីក្រុងហ្សឺណែវ នៅក្នុងឆ្នាំ១៩៧២, និងឆ្នាំ១៩៩១។

UPOV មានបេសកកម្មដ៏សំខាន់ក្នុងការផ្ដល់នូវប្រព័ន្ធការពារពូជដំណាំប្រកបដោយប្រសិទ្ធិភាព ដោយលើកកម្ពស់កិច្ចអភិវឌ្ឍន៍នៃពូជថ្មីនៃដំណាំ ក្នុងគោលបំណងបង្កើនផលប្រយោជន៍ដល់សង្គម។ លើសពីនេះទៅទៀតចំនួនសមាជិករបស់ UPOV បានកើនឡើងជាបន្តបន្ទាប់ចាប់ពីពេលដែលបានបង្កើតឡើងរហូតមកទល់

បច្ចុប្បន្ននេះ ដែលបានបញ្ជាក់យ៉ាងច្បាស់ថាពិភពលោកកំពុងតែមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការការពារពូជថ្មីនៃដំណាំ។

មកដល់ពេលបច្ចុប្បន្ននេះចំនួនសមាជិកសរុបរបស់UPOV មានចំនួន ៧៦ ដោយឡែក កម្ពុជាគឺជាប្រទេសសង្កេតការណ៍មួយនៃ UPOV ពោលកម្ពុជាមិនទាន់ក្លាយជាសមាជិករបស់ UPOV នៅឡើយទេ បន្ថែមពីនេះ ប្រទេសទាំង១០ ដែលជាសមាជិករបស់អាស៊ាន គឺមានតែ ពីរ ប្រទេសប៉ុណ្ណោះដែលបានក្លាយជាសមាជិកពេញសិទ្ធិរបស់ UPOV គឺ ប្រទេសសឹង្ហបុរី និងប្រទេសវៀតណាម។[2]

ខាងក្រោមនេះជាតារាងបង្ហាញពីការកើនឡើងនៃចំនួនសមាជិករបស់ UPOV តាំងពីពេលបង្កើតរហូតដល់បច្ចុប្បន្នះ[3]

| ឆ្នាំ | ចំនួនសមាជិក |
|---|---|
| ១៩៧០ | ៤ |
| ១៩៨០ | ១២ |
| ១៩៩០ | ១៩ |
| ២០០០ | ៤៦ |
| ២០១២ | ៧០ |
| ២០១៥ | ៧២ |
| ២០២០ | ៧៦ |

ការការពារពូជដំណាំ ឬ ហៅម្យ៉ាងទៀតថា សិទ្ធិបង្កាត់ពូជដំណាំ គឺជាទម្រង់មួយនៃសិទ្ធិកម្មសិទ្ធិបញ្ញាដែលផ្តល់ឲ្យអ្នកបង្កាត់ពូជដំណាំទៅលើស្នាដៃបង្កាត់ពូជថ្មីរបស់ខ្លួន ដែលមានទំនាក់ទំនងទៅនឹងបទបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងអាជីវកម្មទៅលើពូជដំណាំ ពោលគឺក្នុងករណីដែលមាននរណាម្នាក់ចង់យកពូជដំណាំថ្មីនោះទៅធ្វើអាជីវកម្មត្រូវតែមានការអនុញ្ញាតជាមុនពីអ្នកបង្កាត់ពូជថ្មីនៃដំណាំ។

[2] ឯកសារចងក្រងដោយលោក អ៊ីវ ភីរុណ អ្នកឯកទេសវិធានចម្រុះគ្រប់គ្រងដំណាំ(IPM) ឆ្នាំ២០១៥

[3] https://www.upov.int/edocs/pubdocs/en/upov_pub_437.pdf (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

## ខ. រចនាសម្ព័ន្ធរបស់សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី

### ១. ក្រុមប្រឹក្សា ( The Council )

ក្រុមប្រឹក្សា និងការិយាល័យរបស់សហភាព គឺជាស្ថាប័នអចិន្ត្រៃយ៍នៃសហភាព (មាត្រា ២៥ នៃអនុសញ្ញាឆ្នាំ១៩៩១)។[4] ក្រុមប្រឹក្សាត្រូវមានតំណាងសមាជិកទាំងឡាយនៃសហភាព។ សមាជិកនីមួយៗ នៃសហភាព ត្រូវចាត់តំណាងមួយរូបប្រចាំនៅក្រុមប្រឹក្សានិងអ្នកជំនួសមួយរូប អ្នកតំណាងឬអ្នកជំនួសអាច អមដោយជំនួយការ ឬទីប្រឹក្សាមួយចំនួនផងដែរ។

ភារកិច្ចរបស់ក្រុមប្រឹក្សារួមមាន៖

- សិក្សាទៅលើវិធានការណ៍ដែលសមស្របដើម្បីការពារផលប្រយោជន៍ និងដើម្បីជម្រុញឲ្យមានការអភិវឌ្ឍរបស់សហភាព។
- តែងតាំងអគ្គលេខាធិការ ហើយក្នុងករណីចាំបាច់មានការតែងតាំងអគ្គលេខាធិការរង និងការកំណត់អាណត្តិនៃការតែងតាំងនីមួយៗ។
- ត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំលើសកម្មភាពរបស់សហភាព និងដាក់ចេញនូវកម្មវិធីនយោបាយសម្រាប់ការងារទៅថ្ងៃអនាគតរបស់ខ្លួន។
- ផ្តល់ឲ្យអគ្គលេខាធិការនូវសេចក្តីបង្គាប់សំខាន់ៗទាំងអស់សម្រាប់ការសម្រេចបាននូវសមិទ្ធិផលនៃភារកិច្ចរបស់សហភាព។
- បង្កើតបទបញ្ជារដ្ឋបាល និងហិរញ្ញវត្ថុរបស់ខ្លួន។
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមថវិការបស់សហភាព និងកំណត់ការចូលរួមវិភាគទាននៃសមាជិកនីមួយៗរបស់សហភាព។
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមលើគណនីដែលបង្ហាញដោយអគ្គលេខាធិការ។
- កំណត់កាលបរិច្ឆេទ និងទីកន្លែងសន្និសិទដែលយោងទៅតាមមាត្រា៣៦និងចាត់វិធានការណ៍ចាំបាច់សម្រាប់រៀបចំ។
- ចេញសេចក្តីសម្រេចចាំបាច់ទាំងអស់ដើម្បីធានាការប្រព្រឹត្តទៅដ៏មានប្រសិទ្ធិភាពរបស់សហភាព។

### ២. គណៈកម្មាធិការពិគ្រោះយោបល់

នៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ក្រុមប្រឹក្សាបានសេចក្តីសម្រេចបង្កើតគណៈកម្មាធិការសម្រាប់ការងារពិគ្រោះយោបល់នៅកិច្ចប្រជុំដំបូងរបស់ខ្លួន ដែលក្រោយមក គណៈកម្មាធិការនេះបានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជាគណៈកម្មាធិការពិគ្រោះយោបល់វិញ ដែលទទួលបន្ទុកក្នុងការរៀបចំកិច្ចប្រជុំ ផ្សេងៗរបស់ក្រុមប្រឹក្សា។

---

[4] Article 21 (INTERNATIONAL CONVENTION FOR THE PROTECTION OF NEW VARIETIES OF PLANTS)

### ៣.គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៧ នៅក្នុងសម័យប្រជុំលើកទី១៦ របស់គណៈកម្មាធិការពិគ្រោះយោបល់បានសម្រេចឲ្យបង្កើតគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម ស្របពេលនោះដែល គណៈកម្មាធិការនេះបានពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរទៅលើបញ្ជីគណៈកម្មាធិការនានា និងស្ថាប័នដទៃទៀតរបស់UPOV។ នៅចុងបញ្ចប់ គណៈកម្មាធិការនេះបានសម្រេចក្នុងការស្នើរឲ្យមានការរៀបចំឡើងវិញនូវសកម្មភាពរបស់ស្ថាប័ននានារបស់UPOV នៅក្នុងបែបបទដូចខាងក្រោម៖

- ក្រុមប្រឹក្សា និងគណៈកម្មាធិការពិគ្រោះយោបល់ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញា UPOV នោះនឹងបន្តសកម្មភាពរបស់ខ្លួនដដែល។
- កិច្ចការនានាដែលទាក់ទងនឹងលក្ខណៈបច្ចេកទេសត្រូវបានដោះស្រាយ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍បច្ចេកទេស ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជាគណៈកម្មាធិការបច្ចេកទេសដោយសារតែការពង្រីកសកម្មភាពរបស់ខ្លួន និងមានការចូលរួមចំណែកពីក្រុមការងារបច្ចេកទេសដែលស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យនៃគណៈកម្មាធិការបច្ចេកទេស។
- សម្រាប់កិច្ចការនានាដែលទាក់ទងនឹងលក្ខណៈរដ្ឋបាល និងនីតិកម្ម ព្រមទាំងកិច្ចការងារមួយចំនួន ដែលទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ និងគោលនយោបាយត្រូវបានដោះស្រាយដោយគណៈកម្មាធិការរដ្ឋបាល និងនីតិកម្មដែលមានសេរីភាពពេញលេញក្នុងការបង្កើតអនុក្រុមនានាសម្រាប់ពិចារណាលើបញ្ហាពិសេសនានា។

### ៤.ក្រុមប្រឹក្សាអមគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម ( CAJ-AG )[5]

នៅក្នុងសម័យប្រជុំលើកទី៥២ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងទីក្រុងហ្សឺណែវ (Geneva) នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម (CAJ) បានយល់ព្រមលើមធ្យោបាយសម្រាប់ការរៀបចំសម្ភារៈព័ត៌មាននានាដែលទាក់ទងនឹងអនុសញ្ញា UPOV និងការបង្កើតឲ្យមាននូវក្រុមប្រឹក្សាអមគណៈកម្មាធិការរដ្ឋបាល និងនីតិកម្មដើម្បីជួយក្នុងការរៀបចំឯកសារ ដែលពាក់ព័ន្ធនឹងសម្ភារៈទាំងអស់។

### ៥.គណៈកម្មាធិការបច្ចេកទេស ( TC )[6]

នៅក្នុងសម័យប្រជុំលើកទី៥ របស់ខ្លួន ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧១ ក្រុមប្រឹក្សាបានអនុម័តយល់ព្រមឲ្យបង្កើតគណៈកម្មាធិការគ្រប់គ្រងបច្ចេកទេស[7]។ នៅសម័យប្រជុំលើកទី១៦ របស់គណៈកម្មាធិកាពិគ្រោះយោបល់ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងហ្សឺណែវ (Geneva) នៅថ្ងៃទី៥ដល់ថ្ងៃទី៩ ខែធ្នូ

[5] Administrative and legal Committee Advisory Group

[6] Technical Committee

[7] Technical Steering Committee

ឆ្នាំ១៩៧៧ គណៈកម្មាធិការពិគ្រោះយោបល់បានបើកនូវកិច្ចពិភាក្សារយៈពេលវែងមួយទៅលើបញ្ជីគណៈកម្មាធិការ និងបណ្តាស្ថាប័ននានារបស់ UPOV ។ គណៈកម្មាធិការពិគ្រោះ បានស្នើឲ្យមានការរៀបចំសកម្មភាពឡើងវិញនៃបណ្តាស្ថាប័នទាំងអស់នោះ ក្នុងនោះគណៈកម្មាធិការពិគ្រោះយោបល់យល់ឃើញថា ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនខាងបច្ចេកទេសវិទ្យា គណៈកម្មាធិការពិគ្រោះយោបល់បានស្នើសុំឲ្យមានការផ្លាស់ប្តូរឈ្មោះពីគណៈកម្មាធិការគ្រប់គ្រងបច្ចេកទេស ទៅជាគណៈកម្មាធិការបច្ចេកទេសវិញដោយពង្រីកសកម្មភាពបន្ថែមលើសកម្មភាពដែលធ្លាប់បំពេញពីមុនមក។ សំណើនោះ ត្រូវបានក្រុមប្រឹក្សាអនុម័តយល់ព្រមនៅសម័យប្រជុំសាមញ្ញលើកទី១១នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧។ គណៈកម្មាធិការបច្ចេកទេសមានសមាជិកនៃបណ្តារដ្ឋសមាជិករបស់ UPOV ទាំងអស់ដែលរដ្ឋនីមួយៗត្រូវតែងតាំងអ្នកតំណាងម្នាក់។ ចំពោះប្រធានបទនៃគណៈកម្មាធិការនេះត្រូវតែងតាំងដោយក្រុមប្រឹក្សាមានរយៈពេល ៣ឆ្នាំ ហើយគាត់បំពេញការងារតំណាងឲ្យគណៈកម្មាធិការទាំងមូលដែលពាក់ព័ន្ធនឹងការងារបច្ចេកទេសលើពូជដំណាំ ការសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេស និងការធានាដំណើរការងារឲ្យស្របទៅនឹងគោលនយោបាយរបស់ក្រុមប្រឹក្សា។

## គ.គោលការណ៍ទូទៅដើម្បីក្លាយជាសមាជិករបស់ UPOV

ដើម្បីក្លាយជាសមាជិកនៃសហភាពសហព័ន្ធអន្តរជាតិការពារការបង្កាត់ពូជដំណាំ (UPOV) គឺបណ្តារដ្ឋ ឬ អង្គការអន្តរជាតិនានា ចាំបាច់ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការអភិវឌ្ឍវិធានច្បាប់ទាក់ទងនឹងការការពារពូជថ្មីនៃដំណាំដោយអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១
- ការផ្តល់អនុសាសន៍របស់ក្រុមប្រឹក្សានៃ UPOV ចំពោះវិធានច្បាប់ដែលអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១
- ការអនុវត្តអនុសញ្ញា UPOV ឆ្នាំ១៩៩១
- ការដាក់តម្កល់លិខិតតូបករណ៍នៃការចូលជាសមាជិក
- ការប្រកាសជូនដំណឹងដល់ក្រុមប្រឹក្សាអំពីអ្នកតំណាង និងការផ្លាស់ប្តូរវេនគ្នា
- ការចូលជាធរមាននៃអនុសញ្ញា UPOV ឆ្នាំ១៩៩១
- របបហិរញ្ញវត្ថុ។

### ១.ការអភិវឌ្ឍវិធានច្បាប់ទាក់ទងនឹងការការពារពូជថ្មីនៃដំណាំដោយអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១

រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលនានាត្រូវបានគេផ្តល់លទ្ធភាពឲ្យទាក់ទងទៅការិយាល័យ នៃសហភាពអន្តរ-ជាតិការពារពូជថ្មីនៃដំណាំ UPOV នៅដំណាក់កាលដំបូងបង្អស់សម្រាប់ជំនួយក្នុងការអភិវឌ្ឍបណ្តាវិធានច្បាប់

នានាដោយអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១ ដើម្បីក្លាយជាសមាជិករបស់អង្គការ UPOV ។ សេចក្តីណែនាំអំពីការអភិវឌ្ឍនៃបណ្តាវិធានច្បាប់ដោយអនុលោមទៅតាមអនុសញ្ញា UPOV អាចរកបាននៅក្នុងឯកសារដែលមានចំណងជើងថា «សេចក្តីណែនាំសម្រាប់ការរៀបចំច្បាប់ ដោយអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១ (Guidance for the Preparation of Law Based on the 1991 Act of the UPOV Convention ) » ដែលឯកសារនេះ មានជាភាសាអង់គ្លេស អារ៉ាប់ ចិន បារាំង អាល្លឺម៉ង់ រុស្ស៊ី និងភាសា អេស្ប៉ាញ។

### ២.ការផ្តល់អនុសាសន៍របស់ក្រុមប្រឹក្សានៃ UPOV[8]

ឯកសារនៃការវិភាគ និងច្បាប់ទាំងឡាយត្រូវបានគេដាក់បង្ហោះទៅក្នុងគេហទំព័ររបស់ UPOV មុនពេលសម័យប្រជុំរបស់ក្រុមប្រឹក្សា ដែលច្បាប់នោះនឹងត្រូវត្រួតពិនិត្យដើម្បីជួយបណ្តាសមាជិក និងអ្នកសង្កេតការណ៍ចំពោះការពិចារណាទៅលើច្បាប់នោះ។ ស្របពេលជាមួយគ្នានោះដែរ ដំណាក់កាលនេះ ក៏ជាឱកាសមួយសម្រាប់ការទទួលបាននូវមតិយោបល់នានាពីបណ្តាសមាជិក ក៏ដូចជាអ្នកសង្កេតការនៅមុនការត្រួតពិនិត្យដោយក្រុមប្រឹក្សា។ មតិយោបល់ដែលបានទទួលនឹងត្រូវផ្តល់ទៅឲ្យរដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលដែលស្នើសុំការត្រួតពិនិត្យច្បាប់ និងទៅសមាជិកទាំងអស់របស់សហភាព។ម្យ៉ាងវិញទៀត មតិយោបល់ដែលបានផ្តល់ ដោយបណ្តាសមាជិក និងអ្នកសង្កេតការណ៍នោះនឹងត្រូវបានបង្ហោះចូល ទៅក្នុងគេហទំព័ររបស់ UPOV ។

### ៣.ការអនុវត្តអនុសញ្ញា

ក្រោយពេលដែលដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកនៃអនុសញ្ញាUPOV ហើយរដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលត្រូវប្រកាន់ជំហរមួយនៅក្រោមច្បាប់ជាតិរបស់ខ្លួនដោយអនុលោមតាមអនុសញ្ញា UPOV។ ជាពិសេសដើម្បីទទួលបាននូវការការពារលើការបង្កាត់ពូជថ្មីនៃដំណាំនោះ អ្នកបង្កាត់ពូជដំណាំត្រូវដាក់ពាក្យស្នើរសុំការការពារដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំដោយអនុលោមតាមអនុសញ្ញា UPOV។ ម្យ៉ាងវិញទៀត រដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាល ត្រូវធានាឲ្យមានវិធានការតាមផ្លូវច្បាប់ដើម្បីធានាការអនុវត្តការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំប្រកបដោយប្រសិទ្ធិភាព។

### ៤.ការដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិក

ការដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកតម្រូវឲ្យមានដូចខាងក្រោមៈ

- **លិខិតូបករណ៍នៃការចូលជាសមាជិក**[9]

លិខិតូបករណ៍នៃការចូលជាសមាជិកត្រូវធ្វើឡើងដោយមានការចុះហត្ថលេខារបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រីការបរទេស ឬចំពោះអង្គការអន្តររដ្ឋាភិបាល គឺត្រូវធ្វើឡើងដោយអាជ្ញាធរ ដែលមានសមត្ថភាពសម្រាប់ទំនាក់ទំនងក្រៅប្រទេសរបស់អង្គការ។ លិខិតនេះត្រូវផ្ញើរមកអគ្គលេខាធិការរបស់UPOV។

[8] មាត្រា ៣៤ នៃអនុសញ្ញាUPOV ឆ្នាំ១៩៩១

[9] មាត្រា ៣៤ នៃអនុសញ្ញា UPOV ឆ្នាំ១៩៩១

➢ **ច្បាប់ដែលគ្រប់គ្រងលើសិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ[10]**

ច្បាប់ដែលបានអនុម័តរួចហើយ គឺតម្រូវឲ្យមាននៅខណៈពេលនៃការដាក់តម្កល់លិខិតូបករណ៍ក្រោមទិដ្ឋភាព ២យ៉ាងគឺ ៖

- ច្បាប់ដែលអនុម័តហើយដែលទទួលស្គាល់ដោយសេចក្តីសម្រេចវិជ្ជមានរបស់ក្រុមប្រឹក្សា ក្នុងការចូលជាសមាជិកនៃអនុសញ្ញា UPOV
- សេចក្តីព្រាង ដែលទទួលស្គាល់ដោយសេចក្តីសម្រេចវិជ្ជមានរបស់ក្រុមប្រឹក្សាក្នុងការចូលជាសមាជិកនៃអនុសញ្ញា UPOV

➢ **សេចក្តីប្រកាសពីចំនួនឯកតានៃការចូលរួមវិភាគទាន[11][12]**

នៅក្នុងការចូលរួមនៅក្នុងសហភាពសហព័ន្ធមួយនេះ អនុសញ្ញា UPOV តម្រូវឲ្យរដ្ឋ និងអង្គការអន្តររដ្ឋាភិបាលធ្វើការបញ្ជាក់ពីចំនួនឯកតានៃការចូលរួមវិភាគទាននៅក្នុងសេចក្តីប្រកាសមួយ ដែលផ្ញើទៅអគ្គលេខាធិការរបស់UPOV ។ អនុសញ្ញា UPOV ក៏បានកំណត់ពីចំនួនឯកតានៃវិភាគទាននោះដែរ ដែលឯកតានោះអាចជាចំនួនគត់ ឬ ជាប្រភាគ ដែលចំនួនប្រភាគនោះមិនត្រូវតូចជាង ១/៥ ឡើយ។ តម្លៃមួយឯកតា គឺ៥៣,៦៤១ហ្វ្រង់ស្វីស។

➢ **សេចក្តីប្រកាសពីប្រភេទពូជដំណាំដែលត្រូវការពារ**

លិខិតូបករណ៍នៃការចូលជាសមាជិកត្រូវភ្ជាប់មកជាមួយនឹងសេចក្តីប្រកាសពីប្រភេទពូជដំណាំ ដែលត្រូវការពារផងដែរ។ សេចក្តីប្រកាសទាំងពីរអំពីចំនួនឯកតានៃការចូលរួមវិភាគទាន និងប្រភេទពូជដំណាំដែលត្រូវការពារគឺអាចធ្វើឡើងដោយលិខិតរបស់រដ្ឋមន្ត្រីការបរទេស ឬ លិខិតពីអ្នកតំណាងអចិន្ត្រៃយ៍ ឬ កំណត់លិខិត (Note) ពីបេសកម្មអចិន្ត្រៃយ៍នៅក្នុងទីក្រុង Geneva។

## ៥. ការប្រកាសជូនដំណឹងដល់ក្រុមប្រឹក្សាអំពីអ្នកតំណាង និងការផ្លាស់ប្តូរវេនគ្នា[13]

សមាជិករបស់UPOV គឺតម្រូវឲ្យសមាជិករបស់ខ្លួនធ្វើការជូនដំណឹងដល់ការិយាល័យរបស់សហព័ន្ធពីឈ្មោះ ឋានៈតួនាទី ព័ត៌មានលម្អិតនានាសម្រាប់ការទំនាក់ទំនងរបស់អ្នកតំណាង និងការផ្លាស់ប្តូរវេនគ្នាប្រចាំក្រុមប្រឹក្សា UPOV។

---

[10] មាត្រា ៣៦ នៃអនុសញ្ញា UPOV ឆ្នាំ១៩៩១

[11] Declaration on the number of contribution units

[12] មាត្រា ២៩ នៃអនុសញ្ញា UPOV ឆ្នាំ១៩៩១

[13] មាត្រា ២៩ នៃអនុសញ្ញា UPOV ឆ្នាំ១៩៩១

### ៦. ការចូលជាធរមាននៃអនុសញ្ញា UPOV

រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលនឹងក្លាយជាសមាជិកនៃអនុសញ្ញា UPOV នៅរយៈពេល១ខែក្រោយពីការដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកប្រកបដោយជោគជ័យ ហើយពេលនោះ រដ្ឋ និងអង្គការអន្តរដ្ឋាភិបាលនោះនឹងត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងឋានៈជាសមាជិកយ៉ាងពេញសិទ្ធិមួយរបស់ UPOV។

### ៧.របបហិរញ្ញវត្ថុ

នៅពេលក្លាយជាសមាជិករបស់អង្គការ UPOV ហើយរដ្ឋ និងអង្គការអន្តររដ្ឋាភិបាលត្រូវមានកាតព្វកិច្ចផ្តល់មូលនិធិទៅមូលនិធិរបស់UPOV ដែលគេហៅថា **មូលនិធិមូលធនការងារ**[14] និងវិភាគទានប្រចាំឆ្នាំលើកទី១របស់ខ្លួននៅក្នុងខែមករា បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាសមាជិកភាពរបស់UPOV។

## កថាខណ្ឌ ២ វេទិកាការពារការបង្កាត់ពូជដំណាំអាស៊ីបូព៌ា(EAPVP)[15]

វេទិកាការពារការបង្កាត់ពូជដំណាំ (EAPVP Forum ) គឺជាអង្គការថ្នាក់តំបន់មួយនៅក្នុងតំបន់អាស៊ីបូព៌ា ដែលដើរតួនាទីជាស្ថាប័នកណ្តាលទទួលខុសត្រូវ លើការជម្រុញការអនុវត្តការការពារការបង្កាត់ពូជដំណាំនៅក្នុងបណ្តាប្រទេសជាសមាជិក។ អង្គការថ្នាក់តំបន់មួយនេះបានបង្កើតប្រព័ន្ធ PVP ប្រកបដោយប្រសិទ្ធភាពស្របនឹងអនុសញ្ញា UPOV ក្នុងចំណោមសមាជិកវេទិកាឆ្ពោះទៅរកការសម្រេចសមាជិកភាពរបស់ UPOV ទាំងអស់របស់វេទិកាជាមូលដ្ឋានសម្រាប់ការធ្វើសុខដុមនីយកម្មនិងកិច្ចសហប្រតិបត្តិការ PVP បន្ថែមទៀតនៅក្នុងតំបន់ដើម្បីរួមចំណែកដល់ការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាពនិងការទទួលបានសន្តិសុខស្បៀង ជាពិសេសការការពារការបង្កាត់ពូជដំណាំផងដែរ។ គោលបំណងដ៏ធំរបស់វេទិកាការពារបង្កាត់ពូជដំណាំគឺ ជួយពង្រឹងប្រព័ន្ធ PVP ជាតិឲ្យស្របនឹងអនុសញ្ញា UPOV ដើម្បីលើកទឹកចិត្តការវិនិយោគក្នុងការបង្កាត់ពូជរុក្ខជាតិថ្មី និងចូលរួមចំណែកគាំទ្រដល់សមិទ្ធិផលនៃសមាជិករបស់ UPOV ដើម្បីជួយសម្រួលដល់ការចុះសម្រុងគ្នានៃនីតិវិធីនៃការដាក់ពាក្យនិងការប្រឡងនិងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ PVP ប្រកបដោយប្រសិទ្ធភាពនៅក្នុងតំបន់។[16]

បច្ចុប្បន្នវេទិកាការពារការបង្កាត់ពូជដំណាំ មានសមាជិកចំនួន ១៣ប្រទេស ដែលរួមមានបណ្តាប្រទេសអាស៊ានទាំង ១០ ដែលរួមមាន ប្រទេសប្រ៊ុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់មា ថៃ ហ្វីលីពីន សឹង្ហបុរី និងប្រទេសវៀតណាម រួមទាំងបណ្តាប្រទេសដែលមានកម្លាំងសេដ្ឋកិច្ចខ្លាំងក្លា ៣ទៀតនៅអាស៊ី គឺប្រទេសជប៉ុន ប្រទេសចិន នឹងប្រទេសកូរ៉េខាងត្បូងផងដែរ។ ជារៀងរាល់ឆ្នាំ វេទិកានេះតែងតែប្រារព្ធធ្វើឡើងនូវកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការរវាងបណ្តាសមាជិកទាំងអស់ សកម្មភាពនៃការធ្វើឲ្យទៅ

[14] Working Capital Fund

[15] http://eapvp.org/about/ (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

[16] http://eapvp.org/(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

ជាប្រព័ន្ធតែមួយនៃការការពារពូជដំណាំ និងការអភិវឌ្ឍថ្មីៗលើប្រព័ន្ធនៃការការពារពូជថ្មីនៃដំណាំនៅបណ្តាប្រទេសជាសមាជិក និងប្រទេសដទៃទៀត។ វេទិកានេះ ធ្លាប់បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនចំនួន ១២លើក រួមមកហើយ ស្របពេលនោះដែលប្រទេសកម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំលើកទី៥ ដែលប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ចំណែកឯ កិច្ចប្រជុំលើកទី១២ ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងប៉េកាំងប្រទេសចិន នាថ្ងៃពុធទី ២៤ ខែមេសាឆ្នាំ ២០១៩ នៅឯសណ្ឋាគារក្រអូបហាយលីងក្រុងប៉េកាំងប្រទេសចិន។

## កថាខណ្ឌ ៣ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)

### ក.ប្រវត្តិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក[17]

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក World Intellectual Property Organization ឬ ហៅកាត់ថា WIPO គឺជាភ្នាក់ងារជំនាញមួយនៃបណ្តាញ ប្រព័ន្ធអង្គការរបស់អង្គការសហប្រជាជាតិ។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោកត្រូវបានបង្កើតឡើងដោយអនុសញ្ញាទីក្រុង Stockholm ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ហើយចូលជាធរមាននៅក្នុងឆ្នាំ១៩៧០។ ត្រឡប់ក្រោយទៅកាន់ប្រវត្តិដើមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅឆ្នាំ១៨៨៣ និងឆ្នាំ១៨៨៦ ជាការទទួលយកនូវអនុសញ្ញាទីក្រុងប៉ារីស និងអនុសញ្ញាទីក្រុងប៊ែន Berne។ អនុសញ្ញាទាំងពីរនេះបានផ្តល់នូវការបង្កើតឡើងនូវអគ្គលេខាធិការដ្ឋានអន្តរជាតិមួយ ហើយត្រូវបានជំនួសដោយក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលសហព័ន្ធរបស់ប្រទេសស្វីស។ លេខាធិការដ្ឋានពីរត្រូវបានគេបង្កើតឡើងមួយសម្រាប់ទទួលខុសត្រូវផ្នែកកម្មសិទ្ធិឧស្សាហកម្ម និងមួយទៀតសម្រាប់សិទ្ធិអ្នកនិពន្ធ ដើម្បីដំណើរការកិច្ចការរដ្ឋបាលនៃអនុសញ្ញាទាំងពីរខាងលើ ប៉ុន្តែក្រោយមកនៅឆ្នាំ១៨៩៣ លេខាធិការដ្ឋានទាំងពីរក៏បានរួមបញ្ចូលគ្នា។ មុននឹងក្លាយទៅជាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្ថាប័ននេះមានឈ្មោះថា ការិយាល័យរួមអន្តរជាតិសម្រាប់ការពារកម្មសិទ្ធិបញ្ញា BIRPI ដែលជាពាក្យកាត់ជាភាសាបារាំងនិងអង់គ្លេសគឺ United International Bureaux for the Protection of Intellectual Property ហើយនៅក្នុងឆ្នាំ១៩៦០ BIRPI ត្រូវបានផ្លាស់ពីទីក្រុង Berne ទៅទីក្រុងGeneva។

នៅឆ្នាំ១៩៦៧ សន្និសិទការទូតមួយត្រូវបានរៀបចំធ្វើឡើងនៅទីក្រុង Stockholm ជាពេលដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកត្រូវបានបង្កើតឡើង ហើយរាល់កិច្ចការគ្រប់គ្រងផ្នែករដ្ឋបាល និងបទបញ្ញត្តិនៃអនុសញ្ញាពហុភាគីទាំងឡាយណាដែលនៅជាធរមាន ធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ BIRPI ត្រូវបានផ្លាស់ប្តូរនិងធ្វើការកែប្រែ។ អង្គការអន្តរជាតិភាគច្រើន ដែលជាទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ គឺពុំមានវត្តមានទេក្រោយពីសង្គ្រាមលោកលើកទី១ត្រូវបានបញ្ចប់។ ប៉ុន្តែក៏មានអង្គការ អន្តរជាតិមួយចំនួននៅរស់រានមានជីវិតផងដែរ។ ឧទាហរណ៍ BIRPI ជាអង្គការពហុជាតិមួយដែលទទួលបន្ទុកផ្នែកកម្មសិទ្ធិបញ្ញាតាំងពីមុនសង្គ្រាមលោក

[17] https://www.wipo.int/about-wipo/en/ (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

បន្ទាប់មកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ជាអ្នកស្នងមរតកពីការិយាល័យរួមអន្តរជាតិសម្រាប់ការពារកម្មសិទ្ធិបញ្ញា BIRPI។

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានក្លាយជាទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ តាមរយៈកិច្ចព្រមព្រៀងចុះនៅថ្ងៃទី១៧ខែធ្នូឆ្នាំ១៩៧៤។ នៅក្នុងឆ្នាំ២០០៤ ស្ថាប័ននេះមានរដ្ឋជាសមាជិកចំនួន ១៨១ នៅក្នុងឆ្នាំ២០១៤ មានរដ្ឋជាសមាជិកចំនួន ១៨៧ ហើយគិតត្រឹមថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០ មានសមាជិកចំនួន ១៩៣ ដែល១៩០ជាសមាជិករបស់អង្គការសហប្រជាជាតិ។[18]

អង្គការពិសេសនីមួយៗមានសមាជិកផ្ទាល់របស់គេរៀងៗខ្លួន រដ្ឋជាសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ ត្រូវបានផ្តល់សិទ្ធិឲ្យដើម្បីក្លាយជាសមាជិកទាំងអស់របស់ភ្នាក់ងារពិសេស ប៉ុន្តែមិនមែនសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិដែលជាសមាជិកទាំងអស់នៃភ្នាក់ងារពិសេសនោះទេ។ រដ្ឋនីមួយៗជាអ្នកសម្រេចចិត្តថា ពួកគេចង់ចូល ឬមិនចង់ចូលជាសមាជិកនៃអង្គការពិសេសណាមួយ។ អង្គការពិសេសនីមួយៗមានធម្មនុញ្ញរបស់ខ្លួនរៀងៗខ្លួន រចនាសម្ព័ន្ធគ្រប់គ្រងផ្ទាល់ ការជ្រើសរើសអ្នកគ្រប់គ្រងចំណូលចំណាយផ្ទាល់ ព្រមទាំងកម្មវិធីនយោបាយ និងសកម្មភាពផ្ទាល់រៀងៗខ្លួនដែរ។

## ខ. គោលបំណង និងសកម្មភាពរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO

បេសកម្មរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺជួយលើកស្ទួយតាមរយៈការ បង្កើតកិច្ចសហប្រតិបត្តិការណ៍ជាអន្តរជាតិផ្សព្វផ្សាយប្រើប្រាស់ និងជាពិសេសការការពារនូវស្នាដៃលើចេញពីសកម្មភាពបញ្ញារបស់មនុស្ស ដើម្បីសេចក្តីរីកចម្រើនជឿនលឿនផ្នែកសេដ្ឋកិច្ច វប្បធម៌ និងសង្គមរបស់មនុស្សជាតិ។[19] ប្រសិទ្ធិភាពរបស់វាគឺ ការបែងចែកនូវតុល្យភាពរវាងការជម្រុញលើកទឹកចិត្តដល់សកម្មភាព នៃការផលិតជាលក្ខណៈពិភពលោកតាមរយៈប្រសិទ្ធិភាពនៃការការពារសិទ្ធិសីលធម៌ និងផលប្រយោជន៍នៃសម្ភារៈរបស់អ្នកបង្កើតនៅលើ ស្នាដៃរបស់ខ្លួន និងការទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងផលប្រយោជន៍ផ្នែកវប្បធម៌ដូចជាការបង្កើតជាលក្ខណៈពិភពលោក។

ឧទាហរណ៍ដ៏លេចធ្លោមួយរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺការចុះបញ្ជីស្នាដៃដែលជាកម្មសិទ្ធិបញ្ញា ហើយគេសង្កេតឃើញថាវាមានការកើនឡើងជាលំដាប់នៃការប្រើប្រាស់សន្ធិសញ្ញាអន្តរជាតិក្នុងវិស័យកម្មសិទ្ធិបញ្ញា ដែលជាមធ្យោបាយដ៏ងាយស្រួលក្នុងការអនុវត្ត ពោលគឺការអនុវត្តនូវនីតិវិធីតែមួយក្នុងការដាក់ពាក្យសុំចុះបញ្ជី ប្រកាសនីយបត្រតក្កកម្ម ម៉ាក និងគំនូរឧស្សាហកម្ម។ ការចុះបញ្ជីមានអានុភាពនៅគ្រប់ប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិ ដូចជាសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Paten-

[18] https://www.wipo.int/about-wipo/en/(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

[19] ឯកសារបង្រៀនរបស់សាស្ត្រាចារ្យ **ឃឹម គីរី "កម្មសិទ្ធិបញ្ញា" ឆ្នាំ២០០៩**

Cooperation Treaty (PCT)) កិច្ចព្រមព្រៀងនិងពិធីសារក្រុងម៉ាទ្រីឌ (Madrid Agreement and Madrid Protocol) និងកិច្ចព្រមព្រៀងក្រុងឡាអេ (Hague Agreement)។ ហើយតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) នៅក្នុងឆ្នាំ២០០០ មានការចុះបញ្ជីចំនួន ៩០៩៤៨ ប្រកាសនីយបត្រតក្កកម្ម នៅឆ្នាំ២០០៤ មានចំនួន១លាន នៅឆ្នាំ២០១១មានចំនួន២លាន និងគិតត្រឹមថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ មានពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចំនួន៣លាន។

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ធ្វើសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ជាអន្តរជាតិនិងជាដៃគូយ៉ាងជិតស្និតជាមួយនឹងរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល ដែលរាប់បញ្ចូលទាំងកិច្ចព្រមព្រៀងរវាង WIPO និង WTO ដោយជួយប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកទាំងអស់ក្នុងការអនុវត្តនូវកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (Agreement on Trade Related Aspect of Intellectual Property (TRIPS))។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក៏ជួយធ្វើការដោះស្រាយវិវាទរវាងបុគ្គលឯកជន និងក្រុមហ៊ុនតាមរយៈនៃការប្រើប្រាស់នូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចជា មជ្ឍត្តកម្មនិងសន្ទានកម្មរបស់ខ្លួន ហើយក៏បានជួយដោះស្រាយបញ្ហា ដែលទាក់ទងទៅនឹងការប្រើប្រាស់នូវ Domain Name នៅក្នុងប្រព័ន្ធអ៊ីនធឺណេតផងដែរ លើសពីនេះទៅទៀត អង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានធ្វើការបកស្រាយពន្យល់អំពី កម្ម-សិទ្ធិបញ្ញា ដែលវាត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្ស ស្ថាប័ននេះក៏បានចូលរួមយ៉ាងសកម្មជាមួយរដ្ឋដែលជាសមាជិកនៅក្នុងវិស័យជាច្រើនដូចជា ច្បាប់ ឧស្សាហកម្ម វប្បធម៌ រួមទាំងផ្នែកផ្សេងៗទៀត រាប់បញ្ចូលទាំងការធ្វើសហប្រតិបត្តិការជាមួយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សហគ្រាសធនតូច និងប្រជាកសិករ ដែលពាក់ព័ន្ធនឹងបញ្ហាសុខភាពសាធារណៈ ការបង្កើតថ្មី ក៏ដូចជាដើម្បីផលប្រយោជន៍ដល់សាធារណៈជនទូទៅផងដែរ

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើរតួរនាទីយ៉ាងសំខាន់ៗ មួយចំនួនដូចជា៖[20]

- ផ្តល់នូវសេវាកម្មសម្រាប់ការអនុវត្តជាអន្តរជាតិនូវសិទ្ធិកម្មសិទ្ធិឧស្សាហកម្ម
- ធ្វើឲ្យមានការរីកចម្រើនក្នុងការរៀបចំតាក់តែងច្បាប់ និងនីតិវិធីផ្សេងៗ ដែលទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញាជាតិនៃរដ្ឋជាសមាជិក
- ផ្លាស់ប្តូរព័ត៌មានក្នុងវិស័យកម្មសិទ្ធិបញ្ញា
- ផ្តល់ជាជំនួយបច្ចេកទេសខាងផ្នែកច្បាប់ និងសម្រាប់ការអភិវឌ្ឍន៍
- សម្របសម្រួល និងជួយដោះស្រាយនូវវិវាទកម្មសិទ្ធិបញ្ញា

[20] ឯកសារបង្រៀនរបស់សាស្រ្តចារ្យ **ឃឹម គីរី "កម្មសិទ្ធិបញ្ញា" ឆ្នាំ២០០៩**

- ជាភ្នាក់ងារត្រួតពិនិត្យខាងផ្នែកព័ត៌មានវិទ្យា ព្រមទាំងជាឧបករណ៍សម្រាប់ការរក្សាទុកការចូលរួម និង ប្រើប្រាស់នូវព័ត៌មានដែលមានតម្លៃខាងកម្មសិទ្ធិបញ្ញា។

## គ.រចនាសម្ព័ន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

ធម្មនុញ្ញដែលជាឯកសារមូលដ្ឋានរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកគឺ អនុសញ្ញាដែលចុះហត្ថលេខានៅទីក្រុង Stockholm ក្នុងឆ្នាំ១៩៦៧។ នៅក្នុងការរៀបចំរបស់ស្ថាប័ននេះដែលអនុលោមតាមអនុសញ្ញាស្តីពីការបង្កើតឲ្យមានអង្គការកម្មសិទ្ធិបញ្ញាពិភពលោកឆ្នាំ១៩៦៧ បានបែងចែកនូវរចនាសម្ព័ន្ធជា ៤ ដែលក្នុងនោះមាន មហាសន្និបាត (General Assembly) សន្និសិទ (Conference) គណៈកម្មាការសម្របសម្រួល (Coordination Committee) និងការិយាល័យអន្តរជាតិ ឬ លេខាធិការដ្ឋានរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (International Bureau of WIPO/ Secretariat) ។[21]

### ១.មហាសន្និបាត ( General Assembly )

មហាសន្និបាត គឺជាស្ថាប័នកំពូលរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកក្នុងចំណោមស្ថាប័នដ៏ទៃទៀត។ មហាសន្និបាតធ្វើការប្រជុំរៀងរាល់ ២ឆ្នាំម្តង តាមការកោះអញ្ជើញរបស់អគ្គនាយករបស់ការិយាល័យអន្តរជាតិដែលការប្រជុំរបៀបនេះហៅថា សម័យប្រជុំសាមញ្ញ។ តែស្ថាប័ននេះក៏អាចធ្វើការប្រជុំជាវិសាមញ្ញបានដែរ តាមរយៈការកោះប្រជុំពីសំណាក់អគ្គនាយក ឬតាមសំណើរពីសមាជិក ១ភាគ៤នៃសមាជិកសន្និបាត ឬតាមរយៈសំណើរជាផ្លូវការរបស់គណៈកម្មាការសម្របសម្រួល។

មហាសន្និបាតនេះក៏មានសិទ្ធិធ្វើការពិចារណា និងផ្តល់ការយល់ព្រមទៅលើរបាយការណ៍របស់អង្គការទាក់ទងនឹង អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ លើសពីនេះទៅទៀត មហាសន្និបាត ក៏មានអំណាចក្នុងការអនុម័ត បទបញ្ញាទាំងឡាយទាក់ទងនឹង ផ្នែកហិរញ្ញវត្ថុរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងអនុម័តទៅលើថវិកាចំណាយរួមសម្រាប់រយៈពេល ២ឆ្នាំម្តងសម្រាប់សហគមន៍នានារបស់ ស្ថាប័ន។ ម្យ៉ាងវិញទៀត មហាសន្និបាតជាអ្នកអនុម័តរាល់វិធាន ដែលស្នើរឡើងដោយអគ្គនាយករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងនឹងការជម្រុញការការពារកម្មសិទ្ធិបញ្ញា និងជាអ្នកកំណត់ភាសាសម្រាប់ធ្វើការរបស់អគ្គ-លេខាធិការដ្ឋាន និងការពិចារណាក្នុងការអនុវត្តជាមួយអង្គការសហប្រជាជាតិ ហើយក៏ជាអ្នកកំណត់ថារដ្ឋណាមួយមិនមែនជាសមាជិក និងអង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីចូលរួមក្នុងការប្រជុំធ្វើជាអ្នកសង្កេតការ។ សមាជិរបស់មហាសន្និបាត គឺជារដ្ឋដែលជាសមាជិកនៃអនុសញ្ញានានាដែលជាកើតឡើងពីមហាស-ន្និបាតផ្ទាល់។ រដ្ឋាភិបាលនៃរដ្ឋសមាជិកនីមួយៗត្រូវជ្រើសរើស គណៈប្រតិភូមួយរូបដែលជំនួយដោយគណៈប្រតិភូជាច្រើនរូប អ្នកប្រឹក្សាជាច្រើនរូប និងអ្នកជំនាញការជាច្រើនរូប។ រាល់ការចំណាយរបស់គណៈប្រតិភូ គឺជាបន្ទុក

[21] https://www.wipo.int/about-wipo/en/(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

របស់រដ្ឋាភិបាល ដែលជាអ្នកតែងតាំងគណៈប្រតិភូនោះ។ រដ្ឋនីមួយៗដែលជាសមាជិកមួយ ឬ ច្រើនរបស់សហគមន៍ណាមួយត្រូវមានសិទ្ធិបោះឆ្នោតមួយសម្លេងនៅក្នុងមហាសន្និបាតដូចគ្នា។ ចំនួនកូរ៉ុមរបស់មហាសន្និបាតគឺជាចំនួនពាក់កណ្ដាលនៃមហាសន្និបាត។

ក្នុងករណីដែលខុសពីបទប្បញ្ញត្តិនេះ ប្រសិនបើការប្រជុំរបស់រដ្ឋជាសមាជិក ដែលចូលរួមមានចំនួនតិចជាងពាក់កណ្ដាល ប៉ុន្តែស្មើ ឬ ច្រើនជាងមួយភាគបីនៃរដ្ឋសមាជិកទាំងអស់ក្នុងមហាសន្និបាត មហាសន្និបាតអាចធ្វើសេចក្ដីសម្រេចបាន ប៉ុន្តែធ្វើបានតែសេចក្ដីសម្រេចណា ដែលពាក់ព័ន្ធនឹងនីតិវិធីផ្ទាល់តែប៉ុណ្ណោះ។ សេចក្ដីសម្រេចនោះនឹងមានអានុភាពត្រឹមតែលក្ខខណ្ឌដែលត្រូវបំពេញតែប៉ុណ្ណោះ។

នៅពេលដែលមានរដ្ឋណាមួយអវត្តមានមិនបានចូលរួមប្រជុំ ការិយាល័យអន្តរជាតិនឹងធ្វើការទំនាក់ទំនង ហើយហៅពួកគេឲ្យមកសរសេរបញ្ជាក់នូវសន្លឹកឆ្នោតរបស់ពួកគេ ឬអនុប្បវាទក្នុងរយៈពេល ៣ខែ គិតពីថ្ងៃដែលបានធ្វើទំនាក់ទំនង។ ប្រសិនបើរយៈពេលនេះបានផុតកំណត់ រដ្ឋដែលបានបញ្ជាក់សម្លងឆ្នោតរបស់ពួកគេនិងអនុប្បវាទសម្រេចថាចំនួននៃរដ្ឋខ្វះការសម្រេចចំពោះកូរ៉ុមនូវការប្រជុំ។ ដូច្នេះ ការសម្រេចនេះនឹងមានអានុភាពដូច ដែលបានផ្ដល់ឲ្យដូចជាលក្ខខណ្ឌភាគច្រើន។

ការប្រជុំសាមញ្ញរបស់មហាសន្និបាត ត្រូវបានធ្វើឡើង ២ដង ក្នុងរយៈពេលមួយឆ្នាំតាមការកោះប្រជុំរបស់ប្រធាន។ ចំណែកការប្រជុំវិសាមញ្ញវិញអាចធ្វើឡើងបានគ្រប់គ្រងពេល អាស្រ័យតាមការកោះប្រជុំរបស់ប្រធានដោយមានសំណើពីគណៈកម្មាការសម្របសម្រួល ឬសំណើពីរដ្ឋជាសមាជិកនៃមហាសន្និបាតចំនួនមួយភាគបួន។ ការប្រជុំនេះនឹងប្រព្រឹត្តទៅនៅស្នាក់ការរបស់អង្គការនេះ។ រដ្ឋដែលជាសមាជិកនៅក្នុងអនុសញ្ញានេះ ហើយដែលមិនមែនជាសមាជិករបស់សហគមន៍ណាមួយ អាចចូលរួមក្នុងមហាសន្និបាតក្នុងនាមជាអ្នកសង្កេតការបាន។

**២.សន្និសិទ** ( Conference )

សន្និសិទរបស់អង្គការកម្មសិទ្ធិបញ្ញា គឺបង្កើតឡើងដោយរដ្ឋជាសមាជិកទាំងអស់នៃអង្គការនេះ។ ក្នុងការអនុវត្តជាក់ស្ដែង សន្និសិទកម្រនឹងជួបប្រជុំដាច់ចេញពីមហាសន្និបាតណាស់។ ការជួបប្រជុំនោះ គឺធ្វើឡើងក្នុងពេលតែមួយដូចគ្នាក្នុងបន្ទប់តែមួយដូចមហាសន្និបាតដែរ ហើយការសម្ដែងចេញនូវលក្ខណៈខុសគ្នាក្នុងដំណើរការនោះ គឺអធិតេយ្យប្រធាននៃអង្គប្រជុំ។ នៅពេលមានសន្និសិទត្រូវមានសមាសភាព រដ្ឋជាសមាជិកនៃអនុសញ្ញា WIPO ទោះបីជាមិនមែនជាសមាជិកនៃអង្គការនេះក៏ដោយ។ រដ្ឋាភិបាលនៃរដ្ឋនីមួយៗត្រូវតំណាងដោយគណៈប្រតិភូមួយរូប ដែលត្រូវជំនួយដោយគណៈប្រតិភូជំនួសម្នាក់ ទីប្រឹក្សា និងអ្នកជំនាញការជាច្រើនរូប ដែលការចំណាយសម្រាប់គណៈប្រតិភូជាបន្ទុករបស់រដ្ឋាភិបាលដែលជាអ្នកតែងតាំង។

សន្និសិទនឹងពិភាក្សាអំពីបញ្ហាដូចខាងក្រោមៈ[22]

[22] https://www.wipo.int/about-wipo/en/d1(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

- ពិភាក្សារាល់បញ្ហាទូទៅពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបរិបទកម្មសិទ្ធិបញ្ញា និងការអនុម័តរាល់បទបញ្ជា នានាទាក់ទងនឹងបញ្ហាកម្មសិទ្ធិបញ្ញា និងពិនិត្យនូវរាល់សមត្ថកិច្ច និងស្វ័យភាពរបស់អង្គការ។
- អនុម័តថវិកា ២ឆ្នាំ របស់សន្និសិទ។
- កំណត់នូវការចំណាយរបស់សន្និសិទនិងបង្កើតវិធីជំនួយការបច្ចេកទេសច្បាប់។
- ធ្វើវិសោធនកម្មនូវអនុសញ្ញានេះដូចដែលមានចែងក្នុងមាត្រា ១៧ នៃអនុសញ្ញានេះ។
- ជាអ្នកកំណត់ថា តើរដ្ឋណាមួយជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយអង្គការអន្តររដ្ឋា-ភិបាលណាមួយ និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលណាមួយដែលត្រូវចូលរួមប្រជុំក្នុងនាមជាអ្នកសង្កេតការ។
- អនុវត្តនូវតួនាទីដែលផ្តល់ឲ្យដោយអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។
- សមាជិកម្នាក់ៗ មានសំលេងតែមួយប៉ុណ្ណោះក្នុងសន្និសិទនៅពេលធ្វើការបោះឆ្នោតបញ្ចេញមតិ។ ចំនួនកូរ៉ុមសម្រាប់ការប្រជុំរបស់សន្និសិទ គឺត្រូវចំនួនមួយភាគបី( ១/៣)នៃរដ្ឋសមាជិកទាំងអស់។
- សេចក្តីសម្រេចរបស់អង្គសន្និសិទ ត្រូវយកតាមសំលេងភាគច្រើនពីរភាគបីនៃសំលេងបោះឆ្នោត។ ការ-ខកខានមិនត្រូវបានចាត់ទុកជាការបោះឆ្នោតទេ។ គណៈប្រតិភូអាចត្រូវបានបោះឆ្នោតក្នុងនាមរដ្ឋនីមួយៗ។
- ការប្រជុំរបស់សន្និសិទនឹងប្រព្រឹត្តទៅជាសាមញ្ញតាមការកោះប្រជុំរបស់ប្រធានក្នុងពេលវេលា និងទីកន្លែងដូចគ្នានឹងមហាសន្និបាតដែរ។ សន្និសិទនឹងធ្វើការប្រជុំសាមញ្ញ តាមការកោះប្រជុំរបស់ប្រធាន នៅពេលដែលមានសំលេងភាគច្រើនពីរដ្ឋសមាជិកទាមទារ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់សន្នសិទត្រូវទៅតាមបទបញ្ជាផ្ទៃក្នុង។

**៣.គណៈកម្មាការសម្របសម្រួល** ( Coordination Committee )

សមាសភាពគណៈកម្មាការសម្របសម្រួលរួមមាន រដ្ឋជាសមាជិកទាំងអស់នៃអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាដែលជាសមាជិកទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិនៃសន្និសញ្ញាទីក្រុងប៉ារីស ឬ គណៈកម្មាធិ-ការប្រតិបត្តិនៃសន្និសញ្ញាទីក្រុងប៉ារីស ឬ គណៈកម្មាធិការប្រតិបត្តិនៃសន្និសញ្ញាទីក្រុង Berne។

តួនាទីរបស់គណៈកម្មាការសម្របសម្រួលមានដូចតទៅ៖

- ផ្តល់យោបល់ដល់មហាសន្និបាត សន្និសិទ និងអគ្គនាយកនៅលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបញ្ហាផលប្រយោជន៍ទូទៅមួយ ឬច្រើនដល់សហភាពអង្គការផ្សេងៗទៀត ជាពិសេស ពាក់ព័ន្ធនឹងបញ្ហាការចំណាយថវិកាជាទូទៅ។
- រៀបចំសេចក្តីព្រាងនៃរបៀបវារៈរបស់មហាសន្និបាត
- រៀបចំសេចក្តីព្រាងនៃរបៀបវារៈនិងសេចក្តីព្រាងកម្មវិធី និងថវិការបស់សន្នសិទ

- នៅពេលដែលអណត្តិរបស់អគ្គនាយកត្រូវបានបញ្ចប់ ឬនៅពេលដែលមានការជ្រើសរើសមុខនាទីក្នុងនាមជាអគ្គនាយក ការតែងតាំងបេក្ខជនសម្រាប់តំណាងនេះដោយមហាសន្និបាត ប្រសិនបើមហាសន្និបាតមិនបានតែងតាំងតំណែងនេះបាន គណៈកម្មាការសម្របសម្រួលនឹងតែងតាំងនូវបេក្ខជនផ្សេងទៀត។ នីតិវិធីនេះនឹងផ្ញើរហូតដល់បុគ្គល ដែលត្រូវតែងតាំងត្រូវបានតែងតាំងដោយមហាសន្និបាត។
- អនុវត្តមុខងារដែលបានកំណត់ដោយអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញា។

គណៈកម្មាការសម្របសម្រួល នឹងធ្វើការប្រជុំសាមញ្ញជារៀងរាល់ឆ្នាំតាមការកោះប្រជុំរបស់អគ្គនាយករួមទាំងគំនិតផ្តួចផ្តើមផ្ទាល់របស់គាត់ផងដែរ។ ការប្រជុំនឹងប្រព្រឹត្តិទៅនៅស្នាក់ការរបស់អង្គការ។ គណៈកម្មាការសម្របសម្រួលនឹងធ្វើការប្រជុំវិសាមញ្ញតាមការកោះប្រជុំរបស់ប្រធានដោយផ្ទាល់ ឬ តាមសំណើររបស់ប្រធានប្រជុំឬតាមសំណើរ របស់រដ្ឋសមាជិកមួយភាគបួននៃសមាជិកទាំងអស់។

ចំនួនកូរ៉ុមសម្រាប់ការប្រជុំរបស់គណៈកម្មាការសម្របសម្រួលមានចំនួន មួយភាគបួននៃសមាជិកទាំងអស់។ ការបោះឆ្នោត និងការផ្តល់យោបល់របស់គណៈកម្មាការ សម្របសម្រួលត្រូវធ្វើឡើងតាមសំលេងភាគច្រើនធម្មតានៃការបោះឆ្នោត។ ប្រសិនបើសំលេងភាគច្រើនធម្មតាត្រូវបានអនុម័ត សមាជិកនីមួយៗអាចចាប់ផ្តើមក្រោយពីបោះឆ្នោតនូវសំណើបោះឆ្នោតជាពិសេសដែលអាចធ្វើឡើងតាមរបៀបពីរយ៉ាងគឺ បែងចែកបញ្ជីបោះឆ្នោតជាពីរដែលមួយមានឈ្មោះរបស់រដ្ឋជាសមាជិករបស់គណៈកម្មាការប្រតិបត្តិនៃ សហភាពទីក្រុងប៉ារីស និងបញ្ជីមួយទៀតដែលមានឈ្មោះរបស់រដ្ឋសមាជិកនៃគណៈកម្មាការប្រតិបត្តិនៃសន្និសញ្ញាទីក្រុង Berne។ សន្លឹកឆ្នោតជំទាស់របស់រដ្ឋនីមួយៗត្រូវសរសេរនៅលើសន្លឹកឆ្នោតដែលបានបោះរួច។V រដ្ឋដទៃមិនមែនជាសមាជិកនៃគណៈកម្មាការសម្របសម្រួលអាចត្រូវបានចូលរួមពិភាក្សាបាន តែគ្មានសិទ្ធិបោះឆ្នោតទេ។

**៤.ការិយាល័យអន្តរជាតិឬអគ្គលេខាធិការដ្ឋាន** ( International Bureau or Secretariat)

ការិយាល័យអន្តរជាតិ គឺជាអគ្គលេខាធិការដ្ឋាននៃអង្គការនេះ។ ការិយាល័យនេះដឹកនាំដោយអគ្គលេខាមួយរូប និងជំនួយដោយអគ្គលេខាម្នាក់ជាជំនួយការ។ អគ្គនាយកត្រូវតែងតាំងជាអចិន្ត្រៃយ៍ ដែលមិនមានរយៈពេលតិចជាង ៦ឆ្នាំ ហើយអាចត្រូវបានតែងតាំងសារថ្មីតាមរយៈមហាសន្និបាត។ អគ្គនាយកគឺជាប្រធានប្រតិបត្តិនៃអង្គការនេះដែលនៅក្នុងនោះគាត់ជា៖

- អ្នកតំណាងឲ្យអង្គការ
- រាយការណ៍ និងអនុលោមតាមការណែនាំរបស់មហាសន្និបាតទាំងកិច្ចការខាងក្នុង និងខាងក្រៅរបស់អង្គការ
- រៀបចំសេចក្តីព្រាងកម្មវិធី ថវិកា និងរាយការណ៍នូវសកម្មភាពជាច្រើន។
- បញ្ជូនកម្មវិធីទាំងអស់នេះទៅរដ្ឋាភិបាលដែលមានចំណាប់អារម្មណ៍នឹងការចំណាយរបស់អង្គការ
- តែងតាំងបុគ្គលិកដែលសំខាន់ៗសម្រាប់ប្រសិទ្ធិភាពការងាររបស់ការិយាល័យអន្តរជាតិ។

ថវិការបស់អង្គការកម្មសិទ្ធិបញ្ញាត្រូវបានបែងចែកជាពីរផ្នែក គឺថវិកាសម្រាប់ការចំណាយទូទៅរបស់សហគមន៍ និងការចំណាយរបស់សន្និសីទ។

**កថាខណ្ឌ ៤ អង្គការពាណិជ្ជកម្មពិភពលោក** ( WTO )[23]

អង្គការពាណិជ្ជកម្មពិភពលោក (WTO) គឺជាអង្គការអន្តររដ្ឋាភិបាលមួយដែលធ្វើនិយ័តកម្មពាណិជ្ជកម្មអន្តរជាតិ។ អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានរៀបចំជាផ្លូវការនៅថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៩៥ ដោយមានប្រទេសចំនួន ១២៣ ចុះហត្ថលេខាលើការចូលជាសមាជិក ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀង Marrakesh ដែលជាជំនួយកិច្ចព្រមព្រៀងទូទៅលើពន្ធគយ និងពាណិជ្ជកម្ម (General Agreement on Tariffs and Trade (GATT))។ អង្គការពាណិជ្ជកម្មពិភពលោកទាក់ទងនឹងបទប្បញ្ញត្តិពាណិជ្ជកម្មរវាងប្រទេសជាសមាជិកដោយផ្តល់ក្របខ័ណ្ឌសម្រាប់ការចចារកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងផ្តល់នូវដំណើរការដោះស្រាយវិវាទ ដែលមានគោលបំណងបង្ខំឱ្យដៃគូទាំងអស់គោរពតាមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ បញ្ហាភាគច្រើនដែលអង្គការពាណិជ្ជកម្មពិភពលោកផ្តោតលើការទាញយកពីការចចារពាណិជ្ជកម្មមុន។

ការចរចានាពេលបច្ចុប្បន្នក្រោមយុត្តាធិការរបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានគេ ហៅថា ដូហា (Doha Round) ដែលត្រូវបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០០១ ដោយផ្តោតសំខាន់លើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ កិច្ចព្រមព្រៀងសម្របសម្រួលពាណិជ្ជកម្មគឺ បាលី (Bali Package) ត្រូវបានបញ្ចប់នៅខែធ្នូឆ្នាំ ២០១៣។ នេះគឺជាកិច្ចព្រមព្រៀងដ៏ទូលំទូលាយដំបូងគេបង្អស់នៅក្នុងប្រវត្តិសាស្ត្ររបស់អង្គការ។[24]

លោក Roverto Azevedo គឺជាអគ្គនាយកបច្ចុប្បន្ន ក៏ជាអគ្គនាយកទី ៦ របស់អង្គការពាណិជ្ជកម្មពិភពលោក។ បច្ចុប្បន្នមានប្រទេសជាសមាជិកចំនួន ១៦៣ ប្រទេស ដែលរួមទាំងបណ្តាប្រទេសដែលមានកម្លាំងសេដ្ឋកិច្ចធំៗក្នុងពិភពលោក ដូចជាសហរដ្ឋអាមេរិច ប្រទេសចិន ជប៉ុនជាដើម ព្រមទាំងបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់សុទ្ធតែជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើកលែងតែ សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ តែប៉ុណ្ណោះ។ អង្គការពាណិជ្ជកម្មពិភពលោកមានមូលដ្ឋាននៅទីក្រុងហ្សឺណែវប្រទេសស្វីស។ ប្រទេសកម្ពុជាក៏បានក្លាយជាសមាជិកទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ ក្រោយពីការផ្តល់សច្ចាប័នរបស់រដ្ឋសភាជាតិកម្ពុជា ។

អង្គការពាណិជ្ជកម្មពិភពលោកមានតួនាទីសំខាន់ៗដូចជា៖

- បង្កើតឲ្យមានវិធានពាណិជ្ជកម្ម សម្រាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិនៃពាណិជ្ជកម្មលើទំនិញ និងពាណិជ្ជកម្មលើសេវាកម្ម។ វិធាននេះបានបញ្ចូលនូវបញ្ហាជាច្រើនដែលទាក់ទងទៅនឹង ការធ្វើ

[23] WTO: World Trade Organization

[24] https://www.wto.org/english/thewto_e/thewto_e.htm(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

ពាណិជ្ជកម្ម ឬ បញ្ហាដែលមានឥទ្ធិពលជាដុំកំភួនដល់ការធ្វើពាណិជ្ជកម្ម។ ឧទាហរណ៍ វិធានខ្លះបាន កំណត់យ៉ាងច្បាស់លាស់អំពីរបៀបវាយ តម្លៃលើទំនិញនាំចូលដែលត្រូវអនុវត្តដោយមន្ត្រីគយដើម្បីឈាន ដល់ការយកពន្ធលើការនាំចូល ឬវិធាន ដែលកំណត់អំពីរបៀបដែលត្រូវអនុវត្តលើស្តង់ដាសុវត្ថិភាព និងលទ្ធ-ភាពប៉ះពាល់ដល់សុខភាពនៃទំនិញនាំចូលការផ្តល់ការការពារចំពោះកម្មសិទ្ធិបញ្ញា និង ពីរបៀបរៀបចំធ្វើ ពាណិជ្ជកម្ម។

- ផ្តល់នូវមធ្យោបាយសម្រាប់ដោះស្រាយជម្លោះពាណិជ្ជកម្មរវាងប្រទេសជាសមាជិកដែលកើតចេញពីការ មិនគោរពកិច្ចព្រមព្រៀង។ ដោយសារភាពស្មុគស្មាញនៃកិច្ចព្រមព្រៀង ពេលខ្លះមានការមិនឯកភាពគ្នា លើការបកស្រាយវិធាននានារវាងប្រទេសជាសមាជិក។ យន្តការដោះស្រាយជម្លោះនៃអង្គការពាណិជ្ជកម្ម ពិភពលោកផ្តល់នូវរបៀបដោះស្រាយជម្លោះដល់សមាជិកនានា ក្នុងករណីដែលមធ្យោបាយផ្សេងៗទៀតមិន អាចទទួលយកបានពីភាគីជម្លោះ ហើយក្រុមឯកទេសដោះស្រាយជម្លោះនឹងកំណត់យកវិធានមួយ សម្រាប់ដោះស្រាយ។ យន្តការនេះមានសារៈសំខាន់បំផុត ជាពិសេសសម្រាប់ប្រទេសតូចតាច ដូចជា ប្រទេសកម្ពុជា។ នោះគឺដោយសារយន្តការដោះស្រាយជម្លោះនេះបង្កលក្ខណៈឲ្យជម្លោះពាណិជ្ជកម្ម ទ្វេភាគីជាមួយប្រទេសដែលមានឥទ្ធិពលសេដ្ឋកិច្ចនិងពាណិជ្ជកម្មធំជាង។
- អង្គការពាណិជ្ជកម្មពិភពលោក គឺត្រូវបានប្រើជាវេទិការសម្រាប់ការចរចារដើម្បីធ្វើឲ្យរីកចម្រើនដល់ការធ្វើ សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មអន្តរជាតិ។ ការចរចាត្រូវបានប្រព្រឹត្តទៅតាមរយៈវេទិកាចរចារនានា ដែលសមាជិកទាំងអស់ចរចារកាត់បន្ថយពន្ធនាំចូលផលិតផលទំនិញ ហើយចំពោះការចរចាបើកទីផ្សារ លើវិស័យ សេវាកម្មត្រូវបានប្រព្រឹត្តទៅនៅឯកិច្ចចរចារ Uruguay Round។

**កថាខណ្ឌ ៦ ក្រុមប្រឹក្សា** TRIPS

ក្រុមប្រឹក្សា TRIPS មានសមាជិកអង្គការពាណិជ្ជកម្មពិលោក ទាំងអស់ជាភាគី។[25] ក្រុមប្រឹក្សានេះទទួល ខុសត្រូវសម្រាប់ការត្រួតពិនិត្យប្រតិបត្តិការរបស់កិច្ចព្រមព្រៀង TRIPS ហើយជាពិសេសនេះ គឺជារបៀបដែល សមាជិកទាំងឡាយត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ។

**ក.តួនាទីក្នុងការត្រួតពិនិត្យ** ( Monitoring )

សមាជិកធ្វើការពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួនទៅវិញទៅមក។ ក្នុងការពិនិត្យនេះ គឺជាចំណុចកណ្តាល ចំពោះការងាររបស់ក្រុមប្រឹក្សាTRIPS ក្នុងការពិនិត្យនូវអ្វីដែលកំពុងកើតឡើងនៅក្រោមកិច្ចព្រមព្រៀងនោះ។ ប្រទេសនីមួយៗត្រូវតែធ្វើឲ្យប្រាកដថាច្បាប់របស់ខ្លួនអនុលោមតាមកាតព្វកិច្ចនានា និងដោយយោងតាមតារាង

[25] https://www.wto.org/english/docs_e/legal_e/ursum_e.htm#nAgreement (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

ពេលវេលាដែលត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនោះ។ ប្រទេសភាគច្រើន ត្រូវតែអនុម័តច្បាប់នានាដើម្បីប្រតិបត្តិកាតព្វកិច្ចទាំងនោះ។ ច្បាប់ទាំងនោះត្រូវបានដាក់ជូនទៅក្រុមប្រឹក្សាTRIPS ដោយអនុញ្ញាតឲ្យសមាជិកនានាធ្វើការពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួនទៅវិញទៅមក និងលើកស្ទួយដល់តម្លាភាពនៃនយោបាយរបស់សមាជិកនានាស្តីពីការការពារកម្មសិទ្ធិបញ្ញា។ សមាជិកនានាត្រូវតែ ផ្តល់ដល់ក្រុមប្រឹក្សា TRIPS នូវច្បាប់ចម្បងនៃច្បាប់ និងបទបញ្ជានានារបស់ពួកគេដែលត្រូវដោះស្រាយ ជាមួយនឹងបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀង TRIPS។ ការជូនដំណឹងទាំងនេះ ពេលនោះត្រូវបានប្រើប្រាស់ជាមូលដ្ឋានចម្បងសម្រាប់ឲ្យក្រុមប្រឹក្សា TRIPS ធ្វើការពិនិត្យឡើងវិញនូវច្បាប់របស់សមាជិកនីមួយៗ។

នៅក្នុងការពិនិត្យឡើងវិញទាំងនេះ ប្រទេសនានាត្រូវតែផ្តល់នូវសំណួរជាលាយលក្ខណ៍អក្សរអំពីច្បាប់របស់រដ្ឋដទៃមុនពេលកិច្ចប្រជុំពិនិត្យឡើងវិញ ចម្លើយចំពោះសំណួរទាំងនោះក៏ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដែរ ហើយសំណួរ និងការឆ្លើយតបនានាបន្តបន្ទាប់មកទៀតត្រូវធ្វើឡើងដោយផ្ទាល់មាត់កំឡុងពេលនៃកិច្ចប្រជុំចំណែកឯសំណួរ និងចម្លើយបន្តបន្ទាប់លើសពីនោះទៀតអាចធ្វើទៅបាននៅកិច្ចប្រជុំលើកក្រោយៗទៀត។

**ខ.តួនាទីក្នុងការពិគ្រោះយោបល់** ( Consultation )

អនុញ្ញាតបានតែចំពោះការពិគ្រោះយោបល់ស្តីពីបញ្ហា TRIPS ប៉ុណ្ណោះ។ ក្រុមប្រឹក្សាTRIPS ក៏ជាវេទិកាសាធារណៈមួយដែរ ដែលប្រទេសនានាអាចប្រើប្រាស់ដើម្បី ពិគ្រោះយោបល់គ្នាទៅវិញទៅមកលើបញ្ហានានាដែលពួកគេអាចមានជាមួយគ្នាក្នុងការអនុវត្តកិច្ចព្រមព្រៀង TRIPS។ វាក៏អាចធ្វើឲ្យច្បាស់លាស់ ឬបកស្រាយនូវបទប្បញ្ញត្តិ នានារបស់ TRIPS ផងដែរ។

**គ.សហប្រតិបត្តិការខាងបច្ចេកទេស** ( Technical Cooperation )

ក្រុមប្រឹក្សា TRIPS មានតួនាទីធ្វើសហប្រតិបត្តិការខាងបច្ចេកទេសលើកម្មវិធីការងារមួយ ក្រុមប្រឹក្សានោះបំពេញការងារតាមកម្មវិធីមួយស្តីពីសហប្រតិបត្តិការបច្ចេកទេសជាមួយនឹងទស្សនៈមួយ ចំពោះការត្រួតពិនិត្យលើរបៀបដែលប្រទេសអភិវឌ្ឍន៍នានាដើម្បីបំពេញកាតព្វកិច្ចនានារបស់ពួកគេក្រោមមាត្រា ៦៧ នៃកិច្ចព្រមព្រៀង TRIPS ។ មាត្រានេះតម្រូវឲ្យប្រទេសអភិវឌ្ឍន៍ធ្វើការ ប្តេជ្ញាស្តីពីសហប្រតិបត្តិការ។ កម្មវិធីការងារនោះធានាប្រទេសកំពុងអភិវឌ្ឍន៍នានាអាចមានព័ត៌មានគ្រប់គ្រាន់ស្តីពីកិច្ចសង្គ្រោះដែលត្រូវផ្តល់ឲ្យ វាក៏ធានាផងដែរនូវការតម្រូវណាមួយដែលមិនត្រូវបានបំពេញរបស់ពួកគេ ដោយត្រូវបានប្រាប់ឲ្យដឹង និងឆ្លើយតបចំពោះសំណួរទាំងឡាយ។

**ឃ.ការពិនិត្យឡើងវិញ និងការចរចារនានាស្តីពីកម្មវត្ថុជាក់លាក់**

អង្គការពាណិជ្ជកម្មពិភពលោក គឺជាវេទិកាសាធារណៈមួយសម្រាប់ការចចារ លើសពីនេះទៅទៀតសំដៅធ្វើឲ្យប្រសើរឡើងដល់ការប្តេជ្ញានៅក្នុងវិស័យនៃកម្មសិទ្ធិបញ្ញា និងនៅក្នុងវិស័យផ្សេងៗទៀតដែលគ្រប ដណ្តប់ដោយកិច្ច

ព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀង TRIPS តម្រូវឲ្យមានការការពារបន្ថែមទៀតនៅក្នុងវិស័យដែលត្រូវបានបញ្ជាក់រួមមានៈ

- ការចរចារលើប្រព័ន្ធពហុភាគីមួយនៃការជូនដំណឹង និងការចុះបញ្ជីសម្រាប់ការសម្គាល់ទីតាំងភូមិសាស្ត្រចំពោះស្រាទំពាំបាយជូរ
- ការពិនិត្យឡើងវិញនៃការអនុវត្តបទប្បញ្ញត្តិនានាស្តីពីការការពារការសម្គាល់ទីតាំងភូមិសាស្ត្រ។
- ការពិនិត្យឡើងវិញបន្ទាប់ពីរយៈពេល ៤ឆ្នាំនូវជម្រើសក្នុងការផ្តល់ការការពារបង្កាត់ពូជថ្មីនៃដំណាំតាមរយៈប្រព័ន្ធដាច់ដោយឡែក ឬ តាមរយៈការការពារប្រកាសនីយបត្រតក្កកម្ម។
- ការពិនិត្យលើភាពអាចអនុវត្តបានចំពោះTRIPSនូវបណ្តឹងទាក់ទងនឹងការបំពាននានានៅក្រោមដំណើរការដោះស្រាយជម្លោះ។

**ខ.ការពិនិត្យឡើងវិញនៃកិច្ចព្រមព្រៀង TRIPS**

ក្រុមប្រឹក្សាTRIPS នឹងធ្វើការពិនិត្យឡើងវិញជាទូទៅមួយនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីរយៈពេល ៥ឆ្នាំ ប៉ុន្តែវាក៏ត្រូវបានផ្តល់អំណាចឲ្យធ្វើការពិនិត្យឡើងវិញនៅពេលណាមួយដែលមានការអភិវឌ្ឍថ្មីៗ ដែលទាក់ទងទៅនឹងការអនុញ្ញាតឲ្យធ្វើការកែប្រែ ឬវិសោធនកម្ម។

## ផ្នែកទី២ ស្ថាប័នជាតិដែលអនុវត្តការការពារការបង្កាត់ពូជដំណាំ

បន្ទាប់ពីបានសិក្សាស្វែងយល់ពីបណ្តាស្ថាប័នអន្តរជាតិ ដែលពាក់ព័ន្ធនឹងការបង្កាត់ពូជដំណាំរួចហើយ ឃើញថាយើងបានស្គាល់នូវស្ថាប័នជាច្រើនហើយ ដើម្បីឲ្យការអនុវត្តការការពារការបង្កាត់ពូជដំណាំថ្មីនេះអនុវត្តទៅបានរលូន ក៏បានទាមទារការរួមសហការពីសំណាក់ស្ថាប័នជាតិផងដែរ ដូចនេះក្នុងផ្នែកនេះយើងនឹងលើកយកមកសិក្សាអំពីស្ថាប័នជាតិដែលពាក់ព័ន្ធនឹងការអនុវត្តការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា ដែលក្នុងនោះយើងបានបែងចែកជា ៤កថាខណ្ឌ រួមមាន (កថាខណ្ឌទី១) គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា(កថាខណ្ឌទី២) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ (កថាខណ្ឌទី៣) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

### កថាខណ្ឌ១ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលហៅកាត់ថា គ.ក.ប ត្រូវបានបង្កើតឡើងដោយអនុក្រឹតលេខ ១៤២ អនក្រ.កប ចុះថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០០៨ ដោយមាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មជាលេខាធិការដ្ឋាន ។[26] ក្នុងគោលបំណងជម្រុញធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិតែមួយ និង

[26] https://www.cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=29&childMasterMenuId=29 (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផ្សព្វផ្សាយ អនុវត្តច្បាប់ និងបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានាឲ្យមានភាពរលូនស្របតាមការសន្យារបស់ ព្រះរាជាណាចក្រកម្ពុជានៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហការទទួល និងប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីអង្គការ អន្តរជាតិ និងប្រទេសនានាឲ្យមានប្រសិទ្ធិភាព។ គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានទីតាំងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

គណៈកម្មាធិការគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានសមាភាពដូចខាងក្រោម៖[27]

- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អនុប្រធាន
- រដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងក្រសួងប្រៃសណីយ៍ និង ទូគមនាគមន៍ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងរុក្ខាប្រមាញ់ និង នេសាទ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងយុត្តិធម៌ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក។

ដោយផ្អែកលើភារកិច្ចដែលមានចែងនៅក្នុងអនុក្រឹត្យ នាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានសហការជាមួយអង្គការ (ECAPIII)[28] រៀបចំផែនការសកម្មភាពមួយដែលមាន ៣៩ចំណុច ក្នុងគោលដៅជាក់លាក់មួយ ដើម្បីបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាជាតិដ៏ខ្លាំងមួយ សម្រាប់ការពារកម្មសិទ្ធិបញ្ញា ការគ្រប់គ្រង និងការអនុវត្តច្បាប់អោយស្របទៅនឹងស្តង់ដារកម្មសិទ្ធិបញ្ញាអន្តរជាតិ និងគាំទ្រគោលដៅអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល ។ បន្ទាប់ពីនាយកដ្ឋាន ជាពិសេស ឯកឧត្តម **វ៉ា រុតសាន** ដែលជាអតីតប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា (បច្ចុប្បន្នជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម) បានស្វះស្វែងរកជំនួយគាំទ្រពីដៃ

[27] មាត្រា ៣ អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញាឆ្នាំ២០០៨

[28] The EU-ASEAN Project on the Protection of intellectual Property Rights

គូរអភិវឌ្ឍន៍ក្រៅប្រទេសមកសកម្មភាពចំនួន៧១ ត្រូវបានគាំទ្រដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងធនាគារពិភព-លោក ។ បន្ទាប់មកលោកនាយកបាន បន្ថែមគំនិតដោយបញ្ចូលសកម្មភាពថ្មីៗ ទៅលើសកម្មភាពដែលនៅសេសសល់រហូតដល់ ៥២ សកម្មភាព ។ នាពេលបច្ចុប្បន្ន នាយកដ្ឋានកម្មសិទ្ធិបញ្ញាកំពុងមានទិសដៅទៅមុខបន្ថែមទៀត ដោយធ្វើសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីការពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ការអប់រំ និងផ្សព្វផ្សាយ ។

ភារៈកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានភារៈកិច្ចមួយចំនួនដូចខាងក្រោម៖[29]

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគីឬពហុភាគី ក្នុងវិស័យកម្មសិទ្ធិបញ្ញាជាមួយបណ្តាប្រទេស និង អង្គការអន្តរជាតិនានា។
- សម្របសម្រួលឲ្យមានភាពរលូនលើរាល់ការងារដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងក្រសួងស្ថាប័នពាក់ព័ន្ធ។
- សហការជម្រុញ រៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា និងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា។
- ទទួល និង ប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីបណ្តាប្រទេស និងអង្គការអន្តរជាតិ។
- សហការជាមួយក្រសួងពាក់ព័ន្ធផ្សព្វផ្សាយច្បាប់និងបទបញ្ញត្តិនានា ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាដល់មហាជន មន្ត្រីអនុវត្តច្បាប់ និងសិស្សនិស្សិតតាមគ្រឹះស្ថានអប់រំសិក្សា។
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និងបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា។
- សហការសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និង អនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីពិចារណាអំពីអត្ថប្រយោជន៍ ចំណុចខ្លាំង ចំណុចខ្សោយ មុននឹងរាយការណ៍សុំការយល់ព្រមចូលជាសមាជិកពីប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលយ៉ាងតិចមួយឆ្នាំម្តងនិងតាមដំណាក់កាលនីមួយៗ។

## កថាខណ្ឌ ២ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ជាក្រសួងដែលទើបតែបង្កើតថ្មី ដោយការ ប្តូរឈ្មោះពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មកជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ត្រូវបានកំណត់ដោយអនុក្រឹត្យ។

[29] មាត្រា ៤ អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញាឆ្នាំ២០០៨

ការបង្កើតក្រសួងនេះឡើងគឺ ដើម្បីឆ្លើយតបទៅនឹងការច្នៃប្រឌិតឌីជីថលដែលកំពុងរីកចម្រើននិងនិន្នាការបច្ចេកវិទ្យាសកលសេចក្តីព្រាងច្បាប់ ដែលបានដាក់ជូនរដ្ឋសភាទាក់ទងនឹងសំណើររបស់ក្រសួង តួនាទីរបស់ក្រសួងថ្មីនឹងបន្តធ្វើប្រតិបត្តិការដូចក្រសួងមុនរហូតទាល់តែមុខងារថ្មីត្រូវបានដាក់ឱ្យដំណើរការ។ នៅក្នុងសម័យប្រជុំពេញអង្គនៅថ្ងៃស្អែកនេះរដ្ឋសភាគ្រោងនឹងធ្វើការសម្រេចចិត្ត លើការស្នើសុំផ្លាស់ប្តូរឈ្មោះនិងការផ្លាស់ប្តូរថ្មីរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។ សម័យប្រជុំនេះធ្វើឡើងបន្ទាប់ពីទីស្តីការ គណៈរដ្ឋមន្ត្រីបានយល់ព្រមផ្លាស់ប្តូរឈ្មោះក្រសួងកាលពីខែមករាតាមសំណើរបស់លោកទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលជាចលនាមួយដែលត្រូវបានគាំទ្រដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កថាខណ្ឌ ៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើតឡើងដោយព្រះរាជក្រម នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលនៅក្នុងនោះ ការរៀបចំបណ្តាអង្គភាព និង ការកំណត់បេសកម្មរបស់ក្រសួងព្រមទាំងមុខងារនៃបណ្តាអគ្គនាយកដ្ឋាន អគ្គធិការដ្ឋាន និងនាយកដ្ឋាននានាត្រូវបានកំណត់យ៉ាងច្បាស់ដោយអនុក្រឹត្យ។ បច្ចុប្បន្នក្រសួងនេះមាន អគ្គនាយកដ្ឋានចំនួន៣ និងរដ្ឋបាលចំនួន២។ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទមានការបែងចែកជា អគ្គនាយកដ្ឋាន និងនាយកដ្ឋានជាច្រើនក្នុងការបំពេញមុខងារភារៈកិច្ចទៅតាមជំនាញរៀងៗខ្លួន ដែលក្នុងនោះ អង្គនាយកដ្ឋានកសិកម្ម ជាអង្គភាពមួយទទួលខុសត្រូវលើការត្រួតពិនិត្យបច្ចេកទេសលើពូជដំណាំដើម្បីអាចចុះបញ្ជីការការពារពូជថ្មីនៃដំណាំបាន។ អគ្គនាយកដ្ឋានកសិកម្មមានបណ្តានាយកដ្ឋានជំនាញជាច្រើនជាសេនាធិការ ដូចជា នាយកដ្ឋានពិសោធន៍ជាតិកសិកម្មនាយកដ្ឋានដំណាំស្រូវ នាយកដ្ឋានដំណាំឧស្សាហកម្ម ជាដើម។

ជាងនេះទៅទៀត បណ្តាគ្រឹះស្ថានសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ក៏បានរួមចំណែកក្នុងសកម្មភាពនៃការត្រួតពិនិត្យនេះផងដែរ ដូចជាវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម(CARDI)។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម បានត្រូវបង្កើតឡើងដោយអនុក្រឹតលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង សម្តេច កត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**។ វិទ្យាស្ថាននេះជាគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាកសិករកម្ពុជា តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាសមស្របដើម្បីបង្កើនផលិតផលកសិកម្ម ក្រោមទស្សនទាន «បច្ចេកវិទ្យាដើម្បីវិបុលភាពសង្គម »។

រចនាសម្ព័នរបស់វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍកសិកម្ម មានការបែងចែកជាការិយាល័យជាច្រើនប៉ុន្តែការិយាល័យ ដែលមានតួនាទីពាក់ព័ន្ធខ្លាំងទៅនឹងការការពារពូជថ្មីនៃដំណាំ គឺការិយាល័យរុក្ខជម្រើសវិទ្យា។ គោលដៅចម្បងរបស់ការិយាល័យនេះគឺបង្កើត និង អភិរក្សពូជដំណាំកសិកម្មសំខាន់ៗឲ្យមានសក្តានុពលទិន្នផលខ្ពស់ គុណភាពល្អ ធនទ្រាំទៅនឹងកត្តាជីវៈ និងអជីវៈ ព្រមទាំងបន្សាំទៅនឹងបរិស្ថានដាំដុះផ្សេងៗសម្រាប់តំបន់វាល

ទំនាបអាស្រ័យភ្លៀង តំបន់ស្រោចស្រព និងតំបន់ចម្ការតាមរយៈការស្រាវជ្រាវ និងប្រើប្រាស់ធនធាន ក្នុងស្រុក និងក្រៅស្រុក។ ការិយាល័យនេះមានផ្នែកសំខាន់ៗចំនួន ៤ គឺ (១) ផ្នែកអភិរក្សពន្ធុដំណាំ (២) ផ្នែកដំណាំធញ្ញជាតិ និងពពួកសណ្តែក (៣) ផ្នែកដំណាំផ្តល់ផ្លែ ផ្កាល់មើម និងដំណាំវាយនភ័ណ្ឌ (៤) ផ្នែកដំណាំបន្លែ និងដំណាំលម្អ។

# ជំពូកទី២

# ការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា

# ជំពូកទី២

# ការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា

ក្រោយពីយើងបានសិក្សាទៅលើជំពូកទី១ ដែលនិយាយអំពីស្ថាប័ននានាពាក់ព័ន្ធនឹងការការពារការបង្កាត់ពូជដំណាំរួចហើយ បន្ទាប់ពីនេះទៅយើងនឹងសិក្សាយ៉ាងលម្អិតទៅលើ **យន្តការនៃការការពារការបង្កាត់ពូជដំណាំ**(ផ្នែកទី២) ប៉ុន្តែមុននឹងយើងលើកយកចំណុចនោះមកបកស្រាយ យើងនឹងធ្វើការបកស្រាយទៅលើ **ការរៀបចំការការពារពូជដំណាំនៅកម្ពុជា** (ផ្នែកទី១)ជាមុនសិន។

## ផ្នែកទី១ ការរៀបចំការការពារពូជដំណាំនៅកម្ពុជា

នៅក្នុងផ្នែកនេះ យើងនឹងលើកយកការរៀបចំការការពារពូជដំណាំនៅកម្ពុជាមកបកស្រាយយ៉ាងលម្អិត ដែលក្នុងនោះរួមមាន ការរៀបចំលិខិតបទដ្ឋាននានាស្តីពីការការពារពូជដំណាំ (កថាខណ្ឌទី១) និងការបណ្តុះបណ្តាលធនធានមនុស្ស (កថាខណ្ឌទី២)។

### កថាខណ្ឌ១ ការរៀបចំលិខិតបទដ្ឋាននានាស្តីពីការការពារពូជដំណាំ

ការជម្រុញប្រទេសកម្ពុជាឲ្យធ្វើការកែទម្រង់ផ្នែកកម្មសិទ្ធិបញ្ញា បានកើតឡើងដោយសារឥទ្ធិពលពីខាងក្រៅប្រទេស ហើយត្រូវបានចាប់ផ្តើមដំណើរការជាលើកដំបូងជាមួយនឹងកិច្ចព្រមព្រៀងផ្នែកកម្មសិទ្ធិបញ្ញា និងពាណិជ្ជកម្មទ្វេភាគី(BAT)[30] ដែលបានចុះហត្ថលេខាជាមួយសហរដ្ឋអាមេរិចនៅ ថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦ ហើយចូលជាធរមាននៅ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦។ គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺសំដៅទៅរកទំនាក់ទំនងពាណិជ្ជកម្ម ដែលមានផលចំណេញទៅវិញទៅមករវាងប្រទេសទាំងពីរ និងដើម្បីផ្តល់ការការពារ ព្រមទាំងការដាក់ឲ្យប្រតិបត្តិតាមយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធិភាពនូវសិទ្ធិលើកម្មសិទ្ធិបញ្ញា។ តាមមាត្រា ១១ របស់ BTA[31] តម្រូវឲ្យប្រទេសកម្ពុជាប្រតិបត្តិតាមការប្តេជ្ញាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះក្នុងកម្រិតអប្បបរិមា ហើយត្រូវភ្ជាប់ខ្លួន ឬចូលរួមបង្កើតនូវសមាជិកភាពរបស់ខ្លួនឡើងទៅនឹងអនុសញ្ញានានាជាច្រើន ដែលក្នុងនោះក៏មានបណ្តាអនុសញ្ញាដែលទាក់ទងទៅនឹងការការពារពូជដំណាំផងដែរ ដូចជាអនុសញ្ញាអន្តរជាតិស្តីពីការការពារការបង្កាត់ពូជដំណាំឆ្នាំ១៩៧៨ ឬឆ្នាំ១៩៩១ ជាដើម។

ក្រោយមក ប្រទេសកម្ពុជាបានចូលខ្លួនធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោកតាមរយៈការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ ហើយស្របពេលជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជាក៏បានក្លាយខ្លួនជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀង TRIPS ដែលកិច្ចព្រមព្រៀងនេះផ្តោត

[30] Agreement between the United States of America and the kingdom of Cambodia on Trade Relations and Intellectual Property Rights Protection (October 25,1996)

[31] Bilateral Trade Agreement

សំខាន់ទៅលើការការពារគ្រប់ទម្រង់ទាំងអស់នៃកម្មសិទ្ធិបញ្ញា ដើម្បីធានាការធ្វើពាណិជ្ជកម្មប្រកបដោយសេរី និងស្មោះត្រង់។ ការក្លាយខ្លួនជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ បានធ្វើឲ្យប្រទេសកម្ពុជាជាប់នូវកាតព្វកិច្ចនានាដើម្បីផ្តល់ការការពារកម្មសិទ្ធិបញ្ញា ជាពិសេសការផ្តល់ការការពារលើពូជថ្មីនៃដំណាំ។ ក្នុងការសម្រេចឲ្យបាននូវគោលដៅនេះ កម្ពុជាបានសម្រេចបង្កើតជាក្រុមការងារក្នុងការរៀបចំនូវយន្តការការពារកម្មសិទ្ធិបញ្ញាដោយអនុលោមទៅតាមកិច្ចព្រមព្រៀងនានា។

គម្រោងផែនការសកម្មភាពលើវិស័យកម្មសិទ្ធិបញ្ញារបស់កម្ពុជា ត្រូវបានក្រុមការងារបច្ចេកទេសលើវិស័យនេះរៀបចំផែនការសកម្មភាពជាបួនផ្នែកដែលមានសកម្មភាពចម្បងចំនួន ៣៩។ ផែនការសកម្មភាពសំខាន់ទាំងបួននោះមានដូចជាៈ (១) ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាលើវិស័យកម្មសិទ្ធិបញ្ញា និងការចូលជាភាគីហត្ថលេខីនៃបណ្តាសន្ធិសញ្ញាអន្តរជាតិនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញា(២) ការជម្រុញការកសាងសមត្ថភាពលើវិស័យកម្មសិទ្ធិបញ្ញា (៣) ការអភិវឌ្ឍបណ្តាលិខិតបទដ្ឋានគតិយុត្តដែលមាន (៤) ការផ្សព្វផ្សាយជា សាធារណៈពីកម្មសិទ្ធិបញ្ញា។ ចំពោះផែនការសកម្មភាពទីមួយដែលទាក់ទងនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាលើវិស័យកម្មសិទ្ធិបញ្ញា និងការចូលជាភាគីហត្ថលេខីនៃបណ្តាសន្ធិសញ្ញាអន្តរជាតិនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញានោះ មានសកម្មភាពសម្បងចំនួន ១១ ដែលក្នុងនោះក៏មានសកម្មភាពមួយចំនួន ទាក់ទងនឹងការការពារការបង្កាត់ពូជដំណាំផងដែរ។ នៅក្នុងនោះរួមមានការត្រួតពិនិត្យលើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំដើម្បីសម្របសម្រួលក្នុងការចូលជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្តីពីការការពារការបង្កាត់ពូជថ្មីនៃដំណាំ(UPOV)និងការត្រួតពិនិត្យលើលិខិតូបករណ៍ ដែលតម្រូវឲ្យមានក្នុងការចូលជាសមាជិករបស់ UPOV និងការសិក្សាពីផលវិបាកនៃការចូលជាសមាជិក និងការត្រៀមរៀបចំលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិនានាសម្រាប់អនុវត្តការការពារការបង្កាត់ពូជដំណាំ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្រុមប្រឹក្សានៃសហភាព UPOV មិនទាន់បានក្លាយជាសមាជិកពេញសិទ្ធិរបស់ UPOV នៅឡើយទេ ប៉ុន្តែប្រទេសកម្ពុជាបានអនុម័តច្បាប់ជាតិរបស់ខ្លួនពាក់ព័ន្ធនឹងការការពារពូជដំណាំរួចហើយ។ នៅមុនពេលអនុម័តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំ កាលពីខែកុម្ភៈ ឆ្នាំ២០០៨ សហភាពអន្តរជាតិការពារការបង្កាត់ពូជថ្មីនៃដំណាំបានមកបំពេញបេសកម្មនៅបណ្តាប្រទេសជាច្រើននៅក្នុងអាស៊ីបូព៌ា ដូចជា ប្រទេសវៀតណាម ប្រទេសសឹង្ហបុរី ប្រទេសឡាវ ប្រទេសកម្ពុជា ជាដើម ដែលក្នុងនោះបណ្តាប្រទេសទាំងនោះគឺគេបែងចែកជា ពីរ ក្រុមគឺ បណ្តាប្រទេសជាសមាជិកសហភាពនេះ និងបណ្តាប្រទេសមិនមែនជាសមាជិករបស់សហភាពនេះ ដែលនៅក្នុងនោះបណ្តាប្រទេសជាសមាជិកមាន ដូចជា ប្រទេសវៀតណាម និងប្រទេសសឹង្ហបុរី គឺបានពិភាក្សាគ្នាលើបញ្ហាចម្បង ៣ យ៉ាង គឺការធ្វើឲ្យប្រសើរឡើងថែមទៀតនូវប្រព័ន្ធនៃការការពារដែលមានស្រាប់ ការពង្រីកវិសាលភាពនៃការការពារ និងពិភាក្សាលើករណីលើកលែងនៃមាត្រា ១៥(២) នៃអនុសញ្ញា UPOV។ ចំណែកឯបណ្តាប្រទេសដែលមិនទាន់

ក្លាយជាសមាជិករបស់ UPOV ហើយមានបំណងចង់ក្លាយជាសមាជិករបស់សហភាព នេះ គឺបានជួបពិភាក្សាគ្នាជាមួយអ្នកជំនាញមកពី UPOV លើបញ្ហាចម្បងតែ ២ យ៉ាងប៉ុណ្ណោះ គឺការបញ្ជ្រៀបការយល់ដឹងពីការការពារការបង្កាត់ពូជថ្មីនៃដំណាំ និងការរៀបចំសេចក្តីព្រាងច្បាប់ជាតិ និងបណ្តាវិធានទាំងឡាយដែលពាក់ព័ន្ធនឹងការការពារពូជថ្មីនៃដំណាំ។

ក្រៅពីច្បាប់គោលទាក់ទងនឹងការការពារពូជដំណាំ ក្រុមការងារបច្ចេកទេសមកពីបណ្តាស្ថាប័នពាក់ព័ន្ធរួមទាំងអ្នកជំនាញមកពី UPOV បាននឹងកំពុងសិក្សាពីលទ្ធភាពនៃការអនុវត្តការការពារពូជដំណាំ ព្រមទាំងរៀបចំបណ្តាលិខិតបទដ្ឋានគតិយុត្តនានាដើម្បីបំពេញបន្ថែមលើច្បាប់ ដែលមានស្រាប់ដែលក្នុងនោះមានដូចជា អនុក្រឹត្យស្តីពីការអនុវត្តការការពារពូជថ្មីនៃដំណាំ ប្រកាសស្តីពីនីតិវិធីនៃការផ្តល់ការការពារពូជថ្មីនៃដំណាំប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល រួមជាមួយនឹងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីកម្រៃរដ្ឋបាលនៃការចុះបញ្ជី កម្រៃរក្សាសុពលភាពប្រចាំឆ្នាំ នៃសិទ្ធិការពារពូជថ្មីនៃដំណាំ និងកម្រៃសេវាកម្មបច្ចេកទេសផ្សេងៗទៀត ប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ទាក់ទងនឹងលក្ខណៈសម្បត្តិ និងនីតិសម្បទារបស់ភ្នាក់ងារតំណាង និងបណ្តាលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដទៃទៀត។ សព្វថ្ងៃនេះ បើទោះបីជាប្រទេសកម្ពុជាមានច្បាប់ទាក់ទងនឹងការការពារពូជថ្មីនៃដំណាំហើយក៏ដោយ ក៏ការអនុវត្តនៅមិនទាន់ធ្វើនៅឡើយដែរ គឺរងចាំឲ្យមានលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀតក្នុងការបំពេញទៅលើច្បាប់គោលនោះ ក្នុងគោលបំណងដើម្បីធានាការអនុវត្តប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធភាព។

## កថាខណ្ឌ ២ ការបណ្តុះបណ្តាលធនធានមនុស្ស

ទន្ទឹមនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងយន្តការការពារពូជថ្មីនៃដំណាំរបស់ប្រទេសកម្ពុ-ជារួចហើយ ការបណ្តុះបណ្តាលធនធានមនុស្សនិងអ្នកជំនាញនានាទាក់ទងនឹងការបង្កាត់ពូជដំណាំគឺជាកត្តាមួយយ៉ាងសំខាន់នឹងជាបញ្ហាមួយដែលគួរយកចិត្តទុកដាក់ផងដែរ។ យន្តការនៃការការពារពូជថ្មីនៃដំណាំអាចដំណើរការទៅបានដោយរលូននោះ វាទាមទារឲ្យមានលិខិតបទដ្ឋានគតិយយុត្តនានាពាក់ព័ន្ធនឹងការការពារឲ្យបានគ្រប់គ្រាន់ និងសមស្របទៅតាមបទដ្ឋានអន្តរជាតិហើយក៏តម្រូវឲ្យមានអ្នកជំនាញនានាដើម្បីអនុវត្តយន្តការនោះផងដែរ។ ដោយសារប្រទេសកម្ពុជាមានបច្ចេកវិទ្យានៅអន់ថយនៅឡើយ ដូច្នេះការទទួលយកបទពិសោធន៍ និងបច្ចេកវិទ្យាពីប្រទេសជិតខាងជាមិត្តគឺជាកត្តាចាំបាច់មួយដែលត្រូវធ្វើ។ ប្រទេសកម្ពុជាបានធ្វើសហប្រតិបត្តិការជាមួយបណ្តាអង្គការអន្តរជាតិថ្នាក់តំបន់ និងពិភពលោកជាច្រើនដើម្បីផ្លាស់ប្តូរបទពិសោធន៍ថ្មីៗទាក់ទងនឹងពូជដំណាំ។ អង្គការ

KOICA [32] របស់ប្រទេសកូរ៉េខាងត្បូងបានសហការជាមួយនឹង KSVS [33] ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងរយៈពេលវែងទាក់ទងនឹងការការពារពូជថ្មីនៃដំណាំ។ កម្មវត្ថុនៃការរៀបចំនេះគឺដើម្បីជួយផ្តល់ជំនាញបច្ចេកទេសថ្មីៗ ទាក់ទងនឹងការបង្កាត់ពូជដំណាំ ការត្រួតពិនិត្យពូជដំណាំថ្មី និង ការណែនាំពីការរីកចម្រើនការការពារដំណាំនៅ ប្រទេសកូរ៉េដើម្បីឲ្យប្រទេសចូលរួមយកមកធ្វើជាគំរូដើម្បីអភិវឌ្ឍនៅតាមប្រទេសរៀងៗខ្លួន។

ចំពោះការបណ្តុះបណ្តាលនេះ ប្រទេសកម្ពុជាតែងតែបញ្ជូនអ្នកជំនាញរបស់កម្ពុជាទៅចូលរួមដើម្បីដកស្រង់បច្ចេកទេសនានាសម្រាប់យកមកបំពេញបន្ថែមលើអ្វីដែលនៅខ្វះខាត។ ក្រៅពីការធ្វើសហប្រតិបត្តិការជាមួយអង្គការនេះកម្ពុជាក៏ធ្វើសហប្រតិបត្តិការជាមួយអង្គការ JICA[34] របស់ជប៉ុនផងដែរ។ អង្គការនេះតែងតែផ្តល់នូវការបណ្តុះបណ្តាលនានាដល់ប្រទេសដែលចូលរួមជាពិសេសគឺ បណ្តាលប្រទេសជាសមាជិកនៃវេទិការការការពារពូជដំណាំនូវអាស៊ីបូព៌ា (EAPVP)[35] ។ ការបណ្តុះបណ្តាលមានច្រើនយ៉ាង ដូចជាការបណ្តុះបណ្តាលរយៈពេលវែងនិងរយៈពេលខ្លី ដំណើរទស្សនកិច្ចសិក្សាទៅប្រទេសជប៉ុនរបស់មន្រ្តីជាន់ខ្ពស់លើការការពារពូជដំណាំ និងការបញ្ជូនអ្នកជំនាញរបស់អង្គការ JICA ទៅកាន់ប្រទេសណាមួយជាដើម។ ក្រៅពីនេះប្រទេសកម្ពុជាក៏បានបញ្ជូនមន្ត្រីជំនាញរបស់ខ្លួនទៅចូលរួមសិក្ខាសាលាអន្តរជាតិ លើបច្ចេកទេសការការពារពូជដំណាំនានាផងដែរដើម្បីលើកកម្ពស់កម្រិតបច្ចេកទេសឲ្យស្របទៅនឹងថ្នាក់តំបន់និងពិភពលោកដូចជា សិក្ខាសាលារបស់អង្គការ UPOV សិក្ខាសាលា APSA [36]សហការជាមួយអង្គការ UPOV ជាដើម។

ដោយឆ្លងកាត់បទពីសោធន៍នៃការបណ្តុះបណ្តាលបច្ចេកទេសជាច្រើនមក ប្រទេសកម្ពុជាបានទទួលនូវបច្ចេកទេសនិងបទពិសោធន៍ជាច្រើន។ ក្រៅពីតម្រូវការអ្នកជំនាញបច្ចេកទេស កម្ពុជាក៏នៅត្រូវការឧបករណ៍បច្ចេកទេសនិងបច្ចេកវិទ្យាទំនើបៗដើម្បីបម្រើឲ្យការងារត្រួតពិនិត្យពូជដំណាំងដែរ។ ចំពោះករណីនេះយើងសង្ឃឹមថា បណ្តាអង្គការអន្តរជាតិដែលធ្វើសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ដូចជាអង្គការ KOICA អង្គការ JACA អង្គការ UPOV ព្រមទាំងបណ្តាប្រទេសជាមិត្តរបស់កម្ពុជាដូចជាប្រទេសជប៉ុន ប្រទេសកូរ៉េ ប្រទេសចិនជាដើម នឹងជួយកម្ពុជាក្នុងការបំពាក់ឧបករណ៍បរិក្ខាទំនើបៗ នៅក្នុងមន្ទីពិសោធន៍ដើម្បីងាយស្រួលក្នុងការធ្វើតេស្តពិសោធន៍លើពូជដំណាំនិងធានាភាពសុក្រឹត្យនៃលទ្ធផលពិសោធន៍ ដើម្បីងាយស្រួលដល់អ្នកស្នើសុំការការពារពូជដំណាំ និងមិនធ្វើឲ្យខូចផលប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំ។

[32] Korea International Cooperation Agency

[33] Korea Seed and Variety Service

[34] Japan International Cooperation Agency

[35] The East Asia Plant Variety Protection Forum

[36] American Political Science Association

## ផ្នែកទី ២ យន្តការនៃការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា

នៅក្នុងផ្នែកនេះ យើងនឹងលើកយកមកបកស្រាយយ៉ាងលម្អិតនូវយន្តការនៃការការពារការបង្កាត់ពូជថ្មីនៃដំណាំដែលក្នុងនោះរួមមាន សញ្ញាណទូទៅនៃការការពារពូជដំណាំ(កថាខណ្ឌទី១) លក្ខខណ្ឌនៃការការពារ(កថាខណ្ឌទី២) និងអនុភាពនៃការការពារ(កថាខណ្ឌទី៣) មួយទៀតគឺការបញ្ចប់ មោឃភាព និងការលុបចោល(កថាខណ្ឌទី៤)។

### កថាខណ្ឌ ១ សញ្ញាណទូទៅនៃការការពារពូជដំណាំ

យោងតាមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឬ ហៅថាកិច្ចព្រមព្រៀង TRIPS បានបង្កើតឲ្យមានស្តង់ដារអប្បបរមានៃការការពារកម្មសិទ្ធិបញ្ញា។ ជាងនេះទៅទៀត កិច្ចព្រមព្រៀង TRIPS តម្រូវឲ្យសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ទាំងអស់ផ្តល់ការការពារលើពូជថ្មីនៃដំណាំ។ បទដ្ឋាននៃការការពារពូជថ្មីនៃដំណាំ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងTRIPSមាត្រា ២៧.៣ ដោយបានចែងថា " ***រដ្ឋសមាជិកទាំងឡាយត្រូវផ្តល់ការការពារសម្រាប់ប្រភេទពូជដំណាំផ្សេងៗទោះតាមរយៈប្រកាសសនីយបត្រតក្កកម្ម ឬដោយប្រព័ន្ធដោយឡែកដ៏មានប្រសិទ្ធិភាពមួយ (effective sui generis system) ឬក៏ដោយការរួមបញ្ចូលគ្នាណាមួយនៃប្រព័ន្ធទាំងពីរ "***។

ចំណែកឯប្រទេសកម្ពុជាវិញ បានជ្រើសរើសយកប្រព័ន្ធនៃការការពារពូជថ្មីនៃដំណាំតាមរយៈប្រព័ន្ធដាច់ដោយឡែក (effective sui generis system) ដោយមិនបានបញ្ចូលទៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មឡើយពោលគឺ កម្ពុជាបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំកាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨។ ច្បាប់នេះរួមមាន៩ជំពូកនិងមាន៨៤មាត្រា។ បើយោងតាមការគ្រោងទុក ការរៀបចំសេចក្តីព្រាងនិងជំនួយបច្ចេកទេសពីអង្គការ UPOV ក្នុងការជួយរៀបចំសេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ចប់កាលពីឆ្នាំ ២០០៥ តែដោយសារតែវាមានលក្ខណៈស្មុគស្មាញខ្លាំងពេកទើបត្រូវពន្យាពេលរហូតដល់ឆ្នាំ២០០៨ ទើបមានការអនុម័តច្បាប់នេះ។ មុនពេលអនុម័តច្បាប់នេះ ប្រទេសកម្ពុជាក៏ធ្លាប់ចេញអនុក្រឹត្យមួយពាក់ព័ន្ធនឹងការការពារពូជដំណាំផងដែរគឺ អនុក្រឹត្យស្តីពីស្តង់ដា និងការគ្រប់គ្រងសម្ភារៈកសិកម្មកាលពីឆ្នាំ១៩៩៨។

បើទោះបីជាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្រុមប្រឹក្សារបស់សហភាព UPOV មិនទាន់ក្លាយជាសមាជិកពេញសិទ្ធិរបស់ UPOV ក៏ដោយក៏ប្រទេសកម្ពុជាកំពុងត្រៀមខ្លួនរួចជាស្រេចដើម្បីក្លាយជាសមាជិកពេញសិទ្ធិរបស់សហភាព នេះ តាមរយៈការអនុម័តច្បាប់ជាតិរបស់ខ្លួននេះឯង។

ដើម្បីងាយស្រួលក្នុងការសិក្សាពីយន្តការនៃការការពារពូជដំណាំនៅក្រោមច្បាប់ របស់ប្រទេសកម្ពុជា យើងគួរយល់យពីទិដ្ឋភាពទូទៅនៃការបង្កាត់ពូជដំណាំជាមុនសិន។ តើអ្វីទៅជាការបង្កាត់ពូជដំណាំ? តើអ្វីទៅជា

អ្នកបង្កាត់ពូជដំណាំ?តើការបង្កាត់ពូជដំណាំបានផ្តល់សារៈសំខាន់អ្វីខ្លះ? នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំរបស់ប្រទេសកម្ពុជា ពុំបានឲ្យនិយមន័យការបង្កាត់ពូជដំណាំទេ។

ការបង្កាត់ពូជដំណាំ គឺជាលទ្ធផលនៃការកំណត់និងបែងចែកក្រុមនៃដំណាំដែលត្រូវបានជ្រើសចេញពីក្នុងចំណោមប្រភេទតែមួយដែលមានលក្ខណៈរួមគ្នាដែលភាសាបច្ចេកទេសជាភាសាអង់គ្លេសហៅថា Species។

ពាក្យថា Species គឺមានភាពស្រដៀងគ្នាទៅនឹងពាក្យផ្សេងៗទៀតនៃការធ្វើចំណាត់ថ្នាក់នៃភូតគាមសាស្ត្រ ក្នុងចំណោមពពួករុក្ខជាតិទាំងអស់[37] វាមានលក្ខណៈច្បាស់លាស់ដែលនៅក្នុងចំណោមប្រភេទដំណាំតែមួយ(Species) អាចមានចំនួនដ៏ច្រើននៃប្រភេទផ្សេងៗនៃពូជដំណាំ។ វាអាចធ្វើឲ្យយើងមានការភ័ន្តច្រឡំរវាងពាក្យបច្ចេកទេសមួយចំនួនដូចជាពាក្យ Plant Kingdom Species និង Variety ដែលនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំរបស់ប្រទេសកម្ពុជា មិនបានកំណត់និងវែកញែកពីភាពខុសគ្នានៃពាក្យទាំងអស់នេះឲ្យបានច្បាស់លាស់ទេ។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់ និងដឹងពីភាពខុសគ្នារវាងពាក្យទាំងបីនេះ ហើយវាក៏មានភាពងាយស្រួលក្នុងការស្វែងយល់ពីទិដ្ឋភាពទូទៅនៃការបង្កាត់ពូជដំណាំផងដែរ ប្រសិនបើគេយល់ដឹងពីភាពខុសគ្នារវាងពាក្យទាំងនេះច្បាស់លាស់។ ពាក្យទាំងបីនេះសុទ្ធតែបញ្ជាក់ពីការធ្វើចំណាត់ថ្នាក់នៃភូតគាមសាស្ត្រ។

ពាក្យ Plant Kingdom គឺសំដៅរាល់ពពួករុក្ខជាតិទាំងអស់ដែលរួមមានពពួកបន្លែ ផ្លែឈើ វល្លិ ផ្កា ស្មៅជាដើម។

រូបភាពខាងក្រោមនេះជាប្រភេទនៃ Plant Kingdom ។



ពាក្យ Species ( ប្រភេទពូជនៃដំណាំតែមួយ )សំដៅដល់ក្រុមនៃរុក្ខជាតិដែលមានលក្ខណៈស្រដៀងគ្នា ឬនៅក្នុងក្រុមតែមួយទោះបីវាមានរូបរាង ទំហំ និងពណ៌មិនដូចគ្នាក៏ដោយ។ ម្យ៉ាងវិញទៀតវាក៏ជាគោលការណ៍នៃការធ្វើចំណាត់ថ្នាក់ នៃសរីរាង្គទាំងឡាយដែលស្ថិតនៅក្រោម Genus និងនៅលើ Subspecies។ ឧទាហរណ៍៖ នៅក្នុងរូបភាពខាងក្រោម មានការបែងចែកជា៣ក្រុម គឺក្រុមរុក្ខជាតិបន្លែ ក្រុមរុក្ខជាតិហូបផ្លែ និងក្រុមរុក្ខជាតិផ្កា។

[37] PLANT KINGDOM

នៅក្នុងក្រុមរុក្ខជាតិបន្លែ យើងឃើញថាបន្លែទាំងអស់ស្ថិតនៅក្នុងក្រុមតែមួយ គឺប្រភេទស្ពៃក្តោប បើទោះបីវាមានទំហំ រូបរាង និងពណ៌មិនដូចគ្នាក៏ដោយ។ នៅក្នុងក្រុមរុក្ខជាតិហូបផ្លែក៏មិនខុសគ្នាដែរ គឺផ្លែឈើទាំងអស់នោះស្ថិតនៅក្នុងក្រុមតែមួយ គឺប្រភេទផ្លែប៉ោមទោះបីវាមានពណ៌មិនដូចគ្នាក៏ដោយ។

កសិករ និងអ្នកដាំដុះត្រូវការដំណាំទាំងឡាយ ដែលមានលក្ខណៈពិសេសចេញពីការបង្កាត់ពូជថ្មីនៃដំណាំក្នុងចំណោម Species ហើយត្រូវបានគេប្រើប្រាស់ដើម្បីទាញយកផលចំណេញក្នុងអាជីវកម្ម និងភាពសមស្របតាមបរិស្ថាននៃការរស់នៅរបស់ពួកគេ។



ពូជនៃដំណាំ (Variety) សំដៅដល់រាល់ប្រភេទពូជដំណាំ ឬក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយដែលមានលក្ខណៈដូចគ្នា និងធ្វើឲ្យឃើញថាប្លែកខុសពីរុក្ខជាតិដទៃទៀត ក្នុងប្រភេទពូជដំណាំតែមួយក្នុងលក្ខណៈមួយ ឬច្រើន ហើយដែលមានលក្ខណៈទាំងនេះនៅតែអាចរក្សាបាន ដើម្បីយកទៅប្រើប្រាស់ធ្វើជាពូជដំណាំបាន ឬ ការបង្កាត់ដោយសរីរាង្គដទៃទៀត។ ម្យ៉ាងវិញទៀត វាក៏ជាគោលការណ៍នៃការធ្វើចំណាត់ថ្នាក់ នៃសរីរាង្គទាំងឡាយដែលស្ថិតនៅក្រោម Genus និងនៅលើ Subspecies ។ ឧទាហរណ៍ៈ នៅក្នុងរូបភាពខាងក្រោម មានការបែងចែកជា៣ក្រុម គឺក្រុមរុក្ខជាតិបន្លែ ក្រុមរុក្ខជាតិហូបផ្លែ និងក្រុមរុក្ខជាតិផ្កា។ នៅក្នុងក្រុមរុក្ខជាតិបន្លែ យើងឃើញថាបន្លែទាំងអស់ស្ថិតនៅក្នុងក្រុមតែមួយ គឺប្រភេទស្ពៃក្តោបដែលជា Species ប៉ុន្តែនៅក្នុង Species មួយវាក៏អាចមានពូជនៃដំណាំជាច្រើនខុសគ្នាទៅតាមទំហំ រូបរាង និងពណ៌ជាដើម ដូចនៅក្នុងរូបខាងក្រោមដែលនូវក្នុងក្រុមបន្លែតែមួយ ប៉ុន្តែមានរូបរាង ពណ៌មិនដូចគ្នាទេ ដែលគេហៅថាជាពូជផ្សេងៗនៃដំណាំតែមួយ។

ក្រៅពីការយល់ពីនិយមន័យនៃការបង្កាត់ពូជដំណាំ និយមន័យរបស់អ្នកបង្កាត់ពូជដំណាំក៏មានសារៈសំខាន់ណាស់ដែរ ព្រោះវាបានកំណត់អំពីថាតើបុគ្គលណាដែលអាចទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំ ហើយប្រសិនបើលក្ខខណ្ឌគ្រប់យ៉ាងត្រូវបានបំពេញហើយនោះ ពួកគេនឹងទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំ។ ប៉ុន្តែនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំរបស់ប្រទេសកម្ពុជាមិនបានឲ្យ

និយមន័យច្បាស់លាស់លើពាក្យថា អ្នកបង្កាត់ពូជដំណាំទេ។ ដោយយោងតាមអនុសញ្ញា UPOV មាត្រា ១(៤) បានឲ្យនិយមន័យថា ៖

- អ្នកបង្កាត់ពូជដំណាំ គឺជាអ្នកដែលបានបង្កាត់ ឬរកឃើញ ឬអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃអ្នកដែលបានបង្កាត់ រកឃើញ ឬអភិវឌ្ឍពូជដំណាំ
- សន្តតិជននៃបុគ្គលដែលបានរៀបរាប់ខងលើ

បន្ទាប់ពីបានយល់ពីទិដ្ឋភាពទូទៅនៃការបង្កាត់ពូជដំណាំ ក៏ដូចជាអ្នកបង្កាត់ពូជដំណាំ យើងគួរយល់ដឹងពីសារៈសំខាន់នៃការបង្កាត់ពូជដំណាំផងដែរ។ ការបង្កាត់ពូជដំណាំពិតជាមានសារៈសំខាន់ណាស់នូវក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សយើងម្នាក់ៗ ជាពិសេសក្នុងវិស័យស្បៀងអាហារ។ សារៈសំខាន់នៃការបង្កាត់ពូជដំណាំមានដូចជា៖

- ផ្តល់នូវទិន្និផលខ្ពស់ ងាយស្រួលប្រមូលផល និងប្រើប្រាស់រយៈពេលដាំដុះខ្លី។
- ទទួលបានប្រាក់ចំណេញយ៉ាងច្រើនពីការធ្វើអាជីវកម្មលើពូជដំណាំដែលបង្កាត់បាន និងពីការយកពូជនោះទៅដាំដុះ។
- គុណភាពដំណាំមានលក្ខណៈល្អជាងពូជដំណាំមុនៗ
- មានទីផ្សារថ្មីនៃការធ្វើអាជីវកម្មពូជថ្មីនៃដំណាំនៅក្នុងប្រទេស និងនូវក្រៅប្រទេស
- ធ្វើឲ្យពូជដំណាំមានច្រើនប្រភេទ សម្បូរបែប
- ផ្តល់ភាពស្រស់បំព្រងនៃបរិស្ថាន និងជាលំនឹងធម្មជាតិ
- ទទួលបាននូវប្រភេទពូជនៃដំណាំដែលអាចធន់នឹងសត្វចង្រៃ និងការប្រែប្រួលធាតុអាកាសនិងជំងឺបាន
- កាត់បន្ថយការចំណាយលើអាហារដោយសារភាពសម្បូរបែបនៃអាហារដែលផ្តល់ឲ្យដោយដំណាំ
- ទទួលបានដំណាំដែលមានសារជាតិចិញ្ចឹម និងរសជាតិល្អប្រសើរជាងមុន
- ទទួលបានពូជដំណាំដែលសាកសមទៅនឹងប្រភេទដីដែលប្រើប្រាស់ ហើយធ្វើឲ្យការប្រើប្រាស់ដីកាន់តែមានប្រសិទ្ធិភាព
- ផលិតផលមានច្រើនសម្បូរបែបទៅតាមការនិយមពេញចិត្ត
- ផ្តល់ជម្រើសច្រើនសម្រាប់ផលិតផល និងប្រភេទរបស់វា។ ឧទាហរណ៍ៈ ប្រេងឆាអាចផលិតចេញពីសណ្តែកសៀង ល្ង ផ្កាឈូករត្ន ដើមអូលីវ និងបណ្តារុក្ខជាតិគាបយកប្រេងជាច្រើនទៀត។ សមាសភាគប្រេង នៃរុក្ខជាតិគាបយកប្រេង ផ្តល់ឲ្យនូវផលិតផលមានប្រយោជន៍ជាច្រើន ដូចជាប្រេងម៉ាស៊ីនសម្រាប់ចាក់យានយន្ត។វាគឺជាអ្វី ដែលអ្នកបង្កាត់ពូជដំណាំបានចាប់ផ្តើមធ្វើកិច្ចការរបស់ខ្លួនលើដំណាំដែលវាបានផ្តល់សារៈសំខាន់ជាច្រើនក្នុងវិស័យកសិកម្ម។ ជាដំបូង អ្នកបង្កាត់ពូជដំណាំប្រើបច្ចេកទេសកាត់បន្ថយសារធាតុក្លុយកូស៊ីណូឡាត ( Glucosinolate ) នៅក្នុងរុក្ខជាតិគាបយកប្រេង ដូច្នេះគេអាចបម្លែង

វាទៅជាចំណីសត្វបាន។ ជាងនេះទៅទៀតគេអាចប្រើបច្ចេកទេសកាត់បន្ថយសារធាតុអាស៊ីត Erotic ដូនេះគេអាចចម្រាញ់វាទៅជាប្រេងរុក្ខជាតិ ដែលមនុស្សអាចប្រើប្រាស់បានដើម្បីចម្អិនអាហារបាន។ ថ្មីៗនេះ ដោយសារការរីកចម្រើននៃបច្ចេកទេស និង បច្ចេកវិទ្យា អ្នកបង្កាត់ពូជដំណាំកំពុងធ្វើការអភិវឌ្ឍលើពូជនៃដំណាំប្រភេទនេះឲ្យមានអាស៊ីត Oleic កម្រិតខ្ពស់ និងអាស៊ីត Linoleic កម្រិតទាប ដែលមានសារធាតុជាតិចិញ្ចឹមមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់។

## កថាខណ្ឌ២ លក្ខខណ្ឌនៃការការពារ

### ក. បុគ្គលដែលអាចស្នើសុំការការពារពូជថ្មីនៃដំណាំ

ដើម្បីទទួលបានការការពារពូជថ្មីនៃដំណាំ បុគ្គលដែលចង់ទទួលបាននូវការការពារលើពូជថ្មីនៃដំណាំរបស់ខ្លួនត្រូវតែធ្វើការដាក់ពាក្យស្នើសុំការការពារលើពូជថ្មីនៃដំណាំនោះ មានន័យថា ច្បាប់របស់ប្រទេសកម្ពុជាធានាឲ្យមានការការពារលើពូជថ្មីនៃដំណាំយ៉ាងពេញលេញ ប៉ុន្តែការការពារនោះតម្រូវឲ្យបុគ្គលដែលចង់ទទួលបាននូវការការពារត្រូវដាក់ពាក្យស្នើសុំនូវការការពារតាមដែលច្បាប់តម្រូវ។ បុគ្គលទាំងអស់ដែលរួមមានទាំងរូបវន្តបុគ្គលឬ នីតិបុគ្គលដែលបានបង្កាត់ ឬរកឃើញ ឬអភិវឌ្ឍពូជថ្មីនៃដំណាំ ហើយមានបំណងចង់បានការការពារលើពូជថ្មីនៃដំណាំរបស់ខ្លួននោះ ត្រូវតែធ្វើការដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ម្យ៉ាងវិញទៀត អ្នកដែលស្នើសុំការការពារ ក៏ច្បាប់តម្រូវឲ្យមានលក្ខណៈសម្បត្តិមួយចំនួនផងដែរដើម្បីអាចស្នើសុំការការពារលើពូជដំណាំបាន។ លក្ខណៈសម្បត្តិទាំងនោះមាន ដូចជា៖[38]

- អ្នកដាក់ពាក្យស្នើសុំត្រូវមានសញ្ជាតិជាខ្មែរ ឬសញ្ជាតិបរទេស ប៉ុន្តែត្រូវមាននិវេសដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាឬ
- មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬរដ្ឋណាមួយដែលមានបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីនេះ អ្នកបង្កាត់ពូជដំណាំអាចដាក់ពាក្យស្នើសុំដោយខ្លួនឯងឬ ដោយភ្នាក់ងារតំណាងមកដាក់ពាក្យស្នើសុំជំនួសខ្លួនបាន។[39] ប្រសិនបើអ្នកដាក់ពាក្យស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យស្នើរសុំនោះត្រូវមានភ្នាក់ងារតំណាងដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ កំពុងប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា។

ភ្នាក់ងារតំណាងដែលដាក់ពាក្យស្នើសុំចុះបញ្ជីពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបំពេញបានលក្ខខណ្ឌដូចមានចែងក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ មកទល់នឹងបច្ចុប្បន្ននេះ ប្រកាសរួមកំណត់

[38] មាត្រា ១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[39] មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ពីលក្ខណៈសម្បត្តិរបស់ភ្នាក់ងារស្នើសុំការចុះបញ្ជីពូជថ្មីនៃដំណាំនេះ មិនទាន់មាននៅឡើយទេ គឺកំពុងស្ថិតនៅដំណាក់កាលនៃការរៀបចំរបស់ក្រុមការងារបច្ចេកទេសរបស់ក្រសួងទាំងពីរនៅឡើយ។

## ខ. លក្ខខណ្ឌគតិយុត្ត

### ១. កម្មវត្ថុនៃការការពារ

### ១.១ ពូជថ្មីនៃដំណាំដែលការពារ

ពូជដំណាំដែលបានរកឃើញហើយ មិនមែនសុទ្ធតែទទួលបាននូវការការពារទាំងអស់នោះទេ ពោលគឺអាស្រ័យលើលក្ខណៈវិនិច្ឆ័យក្នុងការទទួលបាននូវសិទ្ធិការពារពូជដែលបានរកឃើញនោះ ។មានន័យថាលក្ខណៈវិនិច្ឆ័យទាំងបួននោះមានអ្វីខ្លះ? តើវាមានលក្ខណៈយ៉ាងដូចម្តេចខ្លះ?

**១.១.១. ភាពថ្មី** ( Novelty )

លក្ខណៈវិនិច្ឆ័យទី១ គឺពូជដំណាំដែលចង់ទទួលបាននូវសិទ្ធិនៃការការពារនោះត្រូវតែមានភាពថ្មី។ តាមន័យធម្មតាពាក្យថ្មី ត្រូវបានគេប្រើប្រាស់លើវត្ថុ ឬរបស់អ្វីមួយ ដែលគេមិនដែលបានឃើញ ឬជួបប្រទះពីមុនមក។ តាមន័យគតិយុត្ត ពាក្យនេះមានអត្ថន័យស៊ីជម្រៅ និងជាក់លាក់ជាង ពោលគឺគេបានកំណត់ន័យនៃពាក្យថ្មីនេះថា ពូជដំណាំដែលអាចចាត់ទុកថាថ្មីបានលុះត្រាតែពុំទាន់បានដាក់លក់ ឬ ចរាចរនៅលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬ ចរាចរនៅលើទីផ្សារក្នុងរយៈពេលមិនលើសពីមួយឆ្នាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនលើសពីប្រាំមួយឆ្នាំចំពោះ ដំណាំវល្លិ និងដំណាំឈើ និងមិនលើសពីបួនឆ្នាំចំពោះគ្រប់ដំណាំផ្សេងៗទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ។ ម្យ៉ាងវិញទៀត នូវក្នុងអនុសញ្ញា UPOV ឆ្នាំ១៩៩១ ដែលជាលិខិតគុបករណ៍អន្តរជាតិមួយយ៉ាងសំខាន់ក្នុងការការពារពូជថ្មីនៃដំណាំមានលក្ខណៈជាសកលនោះ ក៏បានចែងកំណត់អំពីអត្ថន័យនៃពាក្យថ្មី(Novelty) នេះដែរ ដែលការចែងនោះមានលក្ខណៈដូចគ្នានឹងច្បាប់របស់កម្ពុជាដែរ។[40]

**១.១.២. ភាពខុសប្លែក**( Distinctness )

ដើម្បីទទួលបាននូវសិទ្ធិការពារលើពូជដំណាំ ពូជដំណាំនោះត្រូវតែមានលក្ខណៈវិនិច្ឆ័យទី២នោះគឺ ភាពខុសប្លែក។ ពូជដំណាំដែលអាចចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជដទៃទៀតដែលគេស្គាល់ជាទូទៅត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬកាលបរិច្ឆេទសិទ្ធិអាទិភាព [41]។[42]

[40] មាត្រា ៦ នៃអនុសញ្ញាUPOV ឆ្នាំ ១៩៩១

[41] កាលបរិច្ឆេទអាទិភាព មានន័យថា ជាកាលបរិច្ឆេទដែលដាក់សំណុំលិខិតស្នើសុំមុនគេបង្អស់ ដែលប្រើប្រាស់ធ្វើជាមូលដ្ឋានដើម្បីទទួលបាន សិទ្ធិអាទិដូចមានចែងក្នុងអនុសញ្ញាទីក្រុងប៉ារីស។

[42] មាត្រា ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។



### ១.១.៣.ឯកសណ្ឋានភាព ( Uniformity )

ដើម្បីអាចដឹងថាពូជដំណាំមួយអាចមានសណ្ឋានភាពឬអត់ លុះត្រាតែឆ្លងកាត់ការធ្វើតេស្តពិសោធន៍នៅមន្ទីរពិសោធន៍ ដោយប្រើប្រាស់បច្ចេកទេស និងឧបករណ៍ទំនើបជាមុនសិន។ ការពិសោធន៍ត្រូវធ្វើឡើងតាមដំណាក់កាល ដើម្បីទទួលបានពូជដំណាំនៅតាមជំនាន់នីមួយៗ។

ពូជដំណាំដែលអាចចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សានូវឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីជាពូជដំណាំនោះត្រូវផលិតតាមរយៈភេទ ឬអភេទក្តី[43] ។[44]




### ១.១.៤.ស្ថេរភាព ( Stability )

ដើម្បីអាចដឹងថាពូជដំណាំមួយមានស្ថេរភាព ឬអត់ គឺមិនខុសពីការពិសោធន៍រកឯកសណ្ឋានភាពនៃពូជដំណាំឡើយ គឺត្រូវឆ្លងកាត់ការធ្វើតេស្តពិសោធន៍នៅមន្ទីរពិសោធន៍ដូចគ្នាដោយប្រើប្រាស់បច្ចេកទេស និង

[43] ពូជដំណាំដែលផលិតឡើងដោយភេទ មានន័យថា ពូជដែលកើតឡើងពីការបង្កកំណើតដោយមានអន្តរាគមពីកាម៉ែតញីនិងការម៉ែតឈ្មោល(កោសិកាបន្តពូជញី និង ឈ្មោល)។ពូជដំណាំដែលកើតឡើងដោយអភេទ មានន័យថាពូជដែលមិនមែនកើតឡើងពីការបង្កកំណើតដោយមានវត្តមានការម៉ែតញីឈ្មោលនោះទេ គឺកើតឡើងពីការដុះចេញពីស្ប៉ ឬជាលិកាដើម មើម ឬស ដោយធ្វើមីតូស។

[44] មាត្រា ៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ឧបករណ៍ទំនើបជាមុនសិន។ ការពិសោធន៍ត្រូវធ្វើឡើងជាច្រើនដំណាក់កាល ដើម្បីទទួលបានពូជដំណាំនៅតាមជំនាន់នីមួយៗមានស្ថេរភាពហើយវាមិនប្រែប្រួលខុសពីពូជដើម។

ពូជដំណាំ ដែលអាចចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់និងជំនាន់នីមួយៗ។[45]




## ១.២.ពូជថ្មីនៃដំណាំដែលមិនត្រូវការការពារ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា សិទ្ធិការពារពូជថ្មីនៃដំណាំពុំមានវិសាលភាពគ្របដណ្តប់ចំពោះករណីដូចខាងក្រោម៖[46]

- ការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍
- ការដាំសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម
- ការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងៗទៀត លើកលែងតែវាក្យខណ្ឌទី៤ មាត្រា១៥នៃច្បាប់នេះ។

ដោយផ្អែកលើការការពារផលប្រយោជន៍ដោយស្របច្បាប់ និងព្រំដែននៃសិទ្ធិរបស់ម្ចាស់សិទ្ធិពូជដំណាំថ្មីនៃដំណាំ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហការជាមួយក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ អាចដាក់ចេញនូវបទប្បញ្ញត្តិដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនានា ដើម្បីអនុញ្ញាតឲ្យកសិករ ផលិត

[45] មាត្រា ១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[46] មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

និងប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផល ដែលប្រមូលបានពីការដាំដុះពូជថ្មីនៃដំណាំ ដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្ត។

## ២. បុគ្គលដែលត្រូវការពារ

អ្នកដែលត្រូវការពារ សំដៅលើម្ចាស់ពូជដំណាំផ្ទាល់និងអ្នកដែលទទួលបាននូវសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ពូជដំណាំនោះពីម្ចាស់ពូជដំណាំដូចជា ទាយាទ ឬតតិយជនជាដើម។ ចំពោះអ្នកកាន់កាប់សិទ្ធិ ឬទទួលបានសិទ្ធិស្របច្បាប់ក៏ត្រូវបានការពារដូចម្ចាស់ដើមដែរ។

ដូចនេះ ក្នុងនាមជាម្ចាស់សិទ្ធិការពារពូជដំណាំ ត្រូវបានទទួលការការពារតាមផ្លូវច្បាប់យ៉ាងខ្លាំងក្លាដូចជា ការប្រឆាំងទៅនឹងតតិយជនជាដើម គឺជាតម្លៃតបស្នងមួយដែលម្ចាស់ពូជដំណាំបានខិតខំប្រឹងប្រែងក្នុងការបង្កាត់ ឬរកឃើញ និងអភិវឌ្ឍពូជថ្មីនៃដំណាំនានា ដែលស្នាដៃទាំងនេះបានជួយដល់ការរីកចម្រើនខ្លាំងណាស់ដល់សេដ្ឋកិច្ចជាតិរួមទាំងការផ្គត់ផ្គង់តម្រូវការស្បៀងអាហាររបស់មនុស្ស ក៏ដូចជាការលើកទឹកចិត្តនិងអភិវឌ្ឍពូជដំណាំប្រកបដោយនិរន្តភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

## គ. លក្ខខណ្ឌនម្រង់

### ១. ការស្នើសុំការការពារពូជថ្មីនៃដំណាំ

### ១.១. ការស្នើសុំការការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំជាតិ

សំណុំលិខិតស្នើសុំការការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំជាតិ មានន័យថាជាពូជដំណាំដែលបានបង្កាត់រកឃើញ ឬធ្វើការអភិវឌ្ឍនៅប្រទេសដែលបានស្នើសុំការការពារពូជថ្មីនៃដំណាំនោះ។ សំណុំលិខិតស្នើសុំនេះ ហៅថាសំណុំលិខិតស្នើសុំការការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំជាតិ ដែលបែបបទក្នុងការស្នើសុំចុះបញ្ជីត្រូវអនុលោមតាមច្បាប់ជាអ្នកកំណត់។ ចំពោះគំរូពាក្យសុំ រួមទាំងឯកសារពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ដែលទាក់ទងទៅនឹងនីតិវិធីក្នុងការផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ។

នៅពេលដាក់ពាក្យស្នើសុំ អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ឯកសារ ឬពូជដំណាំតាមកាលបរិច្ឆេទ និងទីកន្លែងដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី។ ដោយហេតុថា យន្តការនៃការការពារពូជថ្មីនៃដំណាំរបស់ប្រទេសកម្ពុជាមិនទាន់ត្រូវបានអនុវត្តនៅឡើយនោះ ឯកសារដែលបានរៀបរាប់ខាងលើនេះគ្រាន់តែជាឯកសារមូលដ្ឋានតម្រូវមួយចំនួនដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំរបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ហេតុនេះហើយ ចំពោះសេចក្តីពន្យល់លម្អិតអំពីឯកសារមូលដ្ឋានខាងលើនេះក៏ដូចជានីតិវិធីនៃការដាក់ពាក្យស្នើសុំនោះ យើងត្រូវរង់ចាំមើលទៅលើលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងការការពារពូជថ្មីនៃដំណាំ ដែលមានដូចជា អនុក្រឹត្យស្តីពីការអនុវត្តការការពារពូជថ្មីនៃដំណាំ ប្រកាសស្តីពីនីតិ

វិធីនៃការផ្ដល់ការការពារពូជថ្មីនៃដំណាំ ប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីកម្រៃរដ្ឋបាលនៃការចុះបញ្ជីកម្រៃក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ និងកម្រៃសេវាកម្មបច្ចេកទេសផ្សេងៗទៀត និងបណ្ដាលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដទៃទៀត។

## ១.២.ការស្នើសុំការការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំបរទេស

ការស្នើសុំការការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំបរទេសមានន័យថា ម្ចាស់ពូជដំណាំដែលបានបង្កាត់ ឬស្រាវជ្រាវរកឃើញពូជដំណាំនោះ មិនមែនបង្កាត់ ឬរកឃើញនៅក្នុងប្រទេសដែលបានស្នើសុំចុះបញ្ជីការការពារនោះទេ។

ជាទូទៅ ការការពារពូជថ្មីនៃដំណាំ មិនមានអានុភាពការការពារពាសពេញពិភពលោកទេ គឺជាបឋមការការពារលើពូជថ្មីនៃដំណាំមួយមានអានុភាពត្រឹមតែដែនដីដែលបានចុះបញ្ជីតែប៉ុណ្ណោះ គឺមិនមានអានុភាពអនុវត្តគ្រប់ទីកន្លែងនោះទេ។ ប្រសិនបើចង់ឲ្យមានអានុភាពនៅកន្លែងណាមួយនោះ គេត្រូវចុះបញ្ជីនៅទីនោះ។ ដូចគ្នានេះដែរ ប្រសិនបើម្ចាស់ពូជដំណាំបរទេសចង់ឲ្យមានការការពារពូជដំណាំរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជានោះ គេត្រូវចុះបញ្ជីនៃការការពារនៅប្រទេសកម្ពុជាដោយអនុលោមទៅតាមច្បាប់របស់កម្ពុជា។ ប៉ុន្តែអ្វីដែលជាបញ្ហាចោទនោះគឺនៅត្រង់លក្ខខណ្ឌគ្រឹះ ដែលទាមទារក្នុងការចុះបញ្ជីគឺថា ប្រសិនបើប្រទេសណាមួយចង់ស្នើសុំការការពារនៅក្នុងប្រទេសកម្ពុជា គឺត្រូវគោរពលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់កម្ពុជា ហើយអ្វីដែលចោទនោះគឺថា ពូជដំណាំដែលចង់ចុះបញ្ជីនោះថ្មី ឬលែងថ្មីទៀតហើយ ព្រោះពូជដំណាំអាចត្រូវបានគេដាក់លក់ ឬធ្វើចរាចររួចមកហើយនៅប្រទេសដើមដំបូងរបស់ម្ចាស់ពូជដំណាំ ដែលគេបានចុះបញ្ជីដំបូងរួចហើយ។ ត្រង់ចំណុចនេះ មាត្រា៧ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំរបស់កម្ពុជាក៏បានកំណត់ផងដែរពីបែបបទដែលចាត់ទុកថា ពូជដំណាំមួយជាពូជដំណាំថ្មីនោះ ដោយបានចែងថា ពូជដំណាំដែលអាចចាត់ទុកថាថ្មីបាន លុះត្រាតែពុំទាន់បានដាក់លក់ ឬចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬចរាចរលើទីផ្សារក្នុងរយៈពេលមិនលើសពី ១ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនលើសពី ៦ឆ្នាំចំពោះដំណាំវល្លិ៍ និងដំណាំឈើ និងមិនលើសពី ៤ឆ្នាំចំពោះគ្រប់ដំណាំផ្សេងៗទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជាដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ។ នេះមានន័យថា បើការដាក់លក់ ឬធ្វើចរាចរពូជដំណាំលើទីផ្សារនៅក្រៅព្រះរាជាណាចក្រកម្ពុជាលើសពីរយៈពេល៦ឆ្នាំ ចំពោះគ្រប់ដំណាំវល្លិ និងដំណាំឈើ និងលើសពីរយៈពេល ៤ឆ្នាំ ចំពោះដំណាំផ្សេងៗទៀតនោះ នោះពូជដំណាំនោះនឹងលែងចាត់ទុកថាថ្មីទៀតហើយ នោះម្ចាស់ពូជដំណាំមិនអាចស្នើសុំការការពារនៅក្នុងប្រទេសកម្ពុជាបានទេ។ ទន្ទឹមនឹងនេះ អ្នកដាក់ពាក្យស្នើសុំត្រូវបង្ហាញ នូវសិទ្ធិអាទិភាពនៃពាក្យស្នើសុំដំបូងដែលបានចុះបញ្ជីមុនគេសម្រាប់ពូជដំណាំដូចគ្នានៅប្រទេសណាមួយ ឬ តំបន់ណាមួយដែលជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ។

ក្នុងករណីមានពាក្យសុំច្រើននៅច្រើនប្រទេស សិទ្ធិអាទិភាពនឹងត្រូវផ្តល់ឲ្យចំពោះការដាក់ពាក្យសុំលើកដំបូងបង្អស់តែប៉ុណ្ណោះ។

អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់នូវសិទ្ធិអាទិភាពឲ្យបានច្បាស់លាស់ក្នុងពាក្យសុំ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយសិទ្ធិអាទិភាពត្រូវមានរយៈពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យសុំលើកដំបូងបង្អស់។ ដើម្បីប្រើប្រាស់សិទ្ធិអាទិភាពរបស់ខ្លួន អ្នកដាក់ពាក្យសុំត្រូវប្រគល់ឯកសារចម្លងនៃសំណុំលិខិតស្នើសុំ ដែលបានដាក់លើកដំបូងបង្អស់ចំនួនមួយច្បាប់ និងត្រូវមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមដោយការិយាល័យ ដែលបានទទួលសំណុំលិខិតស្នើសុំដំបូងបង្អស់ក្នុងរយៈពេល ៣ខែគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំនៅព្រះរាជាណាចក្រកម្ពុ-ជា។ ក្នុងករណីនេះ មន្ត្រីកាន់កាប់បញ្ជីអាចផ្តល់ពេលវេលាសមស្របបន្ថែមសម្រាប់ការផ្តល់ព័ត៌មាន ឯកសារ ឬពូជដំណាំតាមការស្នើសុំ។ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវខាងលើមិនត្រូវបានបំពេញត្រឹមត្រូវទេនោះ ការទាមទារសិទ្ធិអាទិភាពត្រូវចាត់ទុកថាមិនបានធ្វើឡើយ។

## ២. ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ

### ២.១. ការដាក់ឈ្មោះពូជដំណាំ

ការដាក់ឈ្មោះដំណាំ ក៏ជាលក្ខខណ្ឌមួយចាំបាច់ក្នុងការស្នើសុំការការពារការបង្កាត់ពូជដំណាំផងដែរ ដែលនេះជាលក្ខខណ្ឌមួយតម្រូវឲ្យមានដាច់ខាត ដែលមានកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីការការពារការបង្កាត់ពូជដំណាំ ក៏ដូចជាច្បាប់របស់កម្ពុជាលើការការពារពូជថ្មីនៃដំណាំផងដែរ។ ដើម្បីទទួលបានការការពារលើពូជថ្មីនៃដំណាំ អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីនៃដំណាំក៏ត្រូវស្នើសុំការដាក់ឈ្មោះឲ្យពូជថ្មីនៃដំណាំរបស់ខ្លួននៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ រួមទាំងបណ្តាឯកសារដែលពាក់ព័ន្ធដទៃទៀតផងដែរ។ ឯកសារ ដែលស្នើសុំការដាក់ឈ្មោះ និងឯកសារពាក់ព័ន្ធដទៃទៀត ត្រូវបញ្ជូនបន្តទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីត្រួតពិនិត្យមើលសំណុំឯកសារការដាក់ឈ្មោះនោះ ថាតើឈ្មោះពូជដំណាំដែលបានស្នើសុំនោះ ជាឈ្មោះសមស្រប ឬយ៉ាងណា។

ឈ្មោះពូជថ្មីនៃដំណាំ ដែលចាត់ទុកថាមិនសមស្របក្នុងករណីដូចខាងក្រោម៖[47]

- មិនអាចសម្គាល់ពូជដំណាំបាន
- មានសញ្ញាតែមួយ លើកលែងតែសញ្ញានោះអាចសម្គាល់ពូជដំណាំបាន
- នាំឲ្យសាធារណជនយល់ខុស ឬបណ្តាលឲ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ ឬតម្លៃ
- ឬអត្តសញ្ញាណនៃពូជដំណាំ ឬរដ្ឋជាភាគីហត្ថលេខីនៃសហភាពអន្តរជាតិការពារពូជថ្មីនៃដំណាំ
- ពូជដំណាំ ដែលដូចទៅនឹងឈ្មោះពូជដំណាំដែលទទួលបានសិទ្ធិមុន។

[47] មាត្រា ២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ចំពោះឈ្មោះ ដែលបានប្រើក្នុងការស្នើសុំ ឬចុះបញ្ជីនៅរដ្ឋជាភាគីហត្ថលេខីនៃសហភាពអន្តរជាតិការពារការបង្កាត់ពូជថ្មីនៃដំណាំ អាចប្រើប្រាស់ឈ្មោះនោះសម្រាប់ការស្នើសុំ ឬចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាបាន លើកលែងតែឈ្មោះនោះមានអត្ថន័យមិនសមស្របតាមប្រពៃណីវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា ដូច្នេះក្នុងករណីនេះ អ្នកកាន់កាប់បញ្ជីអាចតម្រូវឲ្យផ្តល់ឈ្មោះថ្មីបាន។ ក្នុងករណីដែលឈ្មោះពូជដំណាំត្រូវបានចុះបញ្ជីរួចហើយ មន្ត្រីកាន់កាប់បញ្ជី ក៏អាចលុបឈ្មោះពូជដំណាំនោះចេញពីបញ្ជីការពារពូជថ្មីនៃដំណាំផងដែរ ប្រសិនបើគេត្រួតពិនិត្យឃើញថា ឈ្មោះនោះមិនគួរត្រូវបានចុះបញ្ជីទេនោះ ដោយតម្រូវឲ្យម្ចាស់សិទ្ធិត្រូវស្នើឈ្មោះថ្មីសមស្របដើម្បីចុះបញ្ជី។

បន្ទាប់ពីទទួលបានការការពារពូជថ្មីនៃដំណាំ ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំត្រូវប្រើប្រាស់ឈ្មោះពូជដំណាំដែលបានចុះបញ្ជីរួចហើយក្នុងការធ្វើអាជីវកម្មលើពូជដំណាំនោះ បើទោះបីជាសិទ្ធិការពារនោះផុតសុពលភាពក៏ដោយ។ លើសពីនេះទៅទៀត ពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬការបញ្ជាក់ប្រហាក់ប្រហែលផ្សេងៗទៀត ក៏អាចប្រើភ្ជាប់មកជាមួយឈ្មោះពូជថ្មីនៃដំណាំ ដែលបានការពារនៅពេលដែលពូជនោះត្រូវបានធ្វើអាជីវកម្មផងដែរ។

ជាងនេះទៅទៀត ឈ្មោះដំណាំដែលបានទទួលការការពារ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីការពារពូជថ្មីនៃដំណាំនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ដូចជាបញ្ជីពូជដំណាំរបស់ជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទផងដែរ ដែលបញ្ជីពូជដំណាំជាតិនេះរួមមានទាំងពូជដែលមានស្រាប់ និងពូជថ្មីនៃដំណាំដែរ។ ការដាក់បញ្ចូលឈ្មោះដំណាំទៅក្នុងបញ្ជីទាំងអស់នេះ គឺមានលក្ខណៈងាយស្រួលក្នុងការផ្តល់ការការពារ ការពិនិត្យឈ្មោះដំណាំ និងការស្រាវជ្រាវ និងការធ្វើតេស្តសាកល្បងនានាផងដែរ។

## ២.២.ការត្រួតពិនិត្យ

នៅពេលដែលទទួលបានសំណុំលិខិតស្នើសុំសិទ្ធិការពារពូជថ្មីនៃដំណាំ មន្ត្រីកាន់កាប់បញ្ជីមុននឹងប្រគល់ដល់អ្នកដាក់ពាក្យសុំចាំបាច់ត្រូវធ្វើការពិនិត្យលើពាក្យសុំដើម្បី កំណត់ថាបានបំពេញនូវលក្ខខណ្ឌនៃភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព។ ដើម្បីអាចកំណត់ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាពបាន មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស។[48]

នៅពេលការសិក្សាវាយតម្លៃលទ្ធផលបច្ចេកទេសបង្ហាញលទ្ធផលវិជ្ជមាន និងមានការស្នើដាក់ឈ្មោះពូជដំណាំអាចចុះបញ្ជីបាន មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ហើយត្រូវបោះពុម្ពវិញ្ញាបនបត្របញ្ជាក់សិទ្ធិនោះនៅក្នុងព្រឹត្តិបត្រផ្លូវការមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍។[49] ប៉ុន្តែនៅពេលដែលការត្រួតពិនិត្យបង្ហាញថា ការស្នើសុំដាក់ឈ្មោះពូជដំណាំមិនអាចចុះបញ្ជី

[48] មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[49] មាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

បាន មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឲ្យអ្នកដាក់ពាក្យផ្តល់ឈ្មោះផ្សេងទៀតក្នុងរយៈពេលមិនលើសពី ៣ខែ។ ក្នុងករណីអ្នកដាក់ពាក្យខកខានមិនបានបំពេញតាមលក្ខខណ្ឌនេះទេ ត្រូវបដិសេធពាក្យសុំ។

### ២.៣.ការបង់ប្រាក់កម្រៃសេវាផ្សេងៗ

រូបវន្តបុគ្គល ឬនិតិបុគ្គល ដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវបង់កម្រៃរដ្ឋបាលនៃការចុះបញ្ជី និងកម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ហើយពាក់ព័ន្ធនឹងការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពូជថ្មីនៃដំណាំត្រូវបង់កម្រៃសេវាកម្មបច្ចេកទេសនៅក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

កម្រៃរដ្ឋបាលពាក់ព័ន្ធក្នុងការចុះបញ្ជី កម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ និងកម្រៃសេវាកម្មបច្ចេកទេស រួមទាំងកម្រៃដទៃទៀត ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលរហូតមកទល់នឹងបច្ចុប្បន្ននេះ ប្រកាសរួមនេះនៅមិនទាន់មាននៅឡើយទេ ដោយហេតុថា យន្តការនៃការការពារពូជថ្មីនៃដំណាំនៅកម្ពុជាមិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។ បច្ចុប្បន្ន បណ្តាលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការអនុវត្តយន្តការការពារពូជដំណាំ រួមទាំងប្រកាសរួមស្តីពីកម្រៃសេវានានាទាំងនេះផងកំពុងស្ថិតនៅក្នុងការពិចារណា និងពិភាក្សាគ្នារវាងអ្នកជំនាញមកពីបណ្តាស្ថាប័នជាតិពាក់ព័ន្ធនានា រួមជាមួយនឹងអ្នកជំនាញការរបស់បណ្តាអង្គការអន្តរជាតិនានាក្រោមទម្រង់ជាជំនួយបច្ចេកទេសផងដែរ។

### ២.៤.ការការពារបណ្តោះអាសន្ន

ដើម្បីការពារផលប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំ គេបានបង្កើតឲ្យមានយន្តការការពារបណ្តោះអាសន្នក្នុងការការពារនៅអំឡុងពេលនៃការដាក់ពាក្យស្នើសុំ ឬការបោះផ្សាយនៃពាក្យស្នើសុំរហូតដល់ការទទួលបានសិទ្ធិការពារពូជថ្មីនៃដំណាំ។ យន្តការនេះត្រូវបានកំណត់យ៉ាងច្បាស់នូវក្នុងមាត្រា ១៣ នៃអនុសញ្ញាអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំ (UPOV) ឆ្នាំ១៩៩១។ យ៉ាងណាមិញ ព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមួយទទួលយកយន្តការនេះផងដែរ ដោយអនុលោមតាមអនុសញ្ញា (UPOV) ឆ្នាំ១៩៩១។ ច្បាប់របស់កម្ពុជាបានកំណត់ថា នៅចន្លោះពេលពីការបោះពុម្ពផ្សាយនៃពាក្យស្នើសុំរហូតដល់ការផ្តល់សិទ្ធិការពារពូជដំណាំ ម្ចាស់សិទ្ធិមានសិទ្ធិទាមទារសំណងសមស្របចំពោះសកម្មភាពមួយចំនួនដែលច្បាប់បានកំណត់។ សកម្មភាពទាំងនោះរួមមានៈ ការយកពូជ ឬបំណែកពូជដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាពការផលិត ឬការផលិតឡើងវិញ ការកំណត់លក្ខខណ្ឌក្នុងគោលបំណងពង្រីកពូជ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬការចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល ការធ្វើសន្និធិ[50] ជាដើម។[51]

[50] ការសន្សំទុក ការសំចៃទុក ឬការទុកសំចៃ

[51] វាក្យខណ្ឌទី ១ មាត្រា ១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

## កថាខណ្ឌ៣ អានុភាពនៃការការពារ

### ក.អត្ថន័យនៃសិទ្ធិ

អត្ថន័យនៃសិទ្ធិ មានវិសាលភាពធំទូលាយណាស់។ តាមទ្រឹស្តី លក្ខណៈនៃសិទ្ធិមានភាពដាច់ខាត ឬផ្តាច់មុខ និងរៀងរហូត ពោលគឺសិទ្ធិគ្មានអាយុកាលទេ។ មានន័យថា សិទ្ធិមិនត្រូវបានរលត់តាមរយៈការមិនបានប្រើប្រាស់នោះឡើយ ម្យ៉ាងទៀតក៏មិនបានរលត់ទៅតាមការស្លាប់របស់កម្មសិទ្ធិករដែរ ។ សិទ្ធិនេះត្រូវបានផ្ទេរបន្តទៅឲ្យទាយាទ។ លើសពីនេះទៅទៀត សិទ្ធិនេះក៏មិនអាចរំលោភបានដែរ មានន័យថា គ្មាននរណាម្នាក់អាចប្រើប្រាស់សិទ្ធិលើកម្មសិទ្ធិដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិករបានឡើយ។ ផលប្រយោជន៍ជាច្រើនដែលកម្មសិទ្ធិករទទួលបានដូចជា ផលប្រយោជន៍ខាងសេដ្ឋកិច្ចរបស់កម្មសិទ្ធិករផ្ទាល់ និងការការពារតាមរយៈផ្លូវច្បាប់ រួមទាំងការប្រើប្រាស់ផ្សេងៗវាជាឆន្ទៈរបស់កម្មសិទ្ធិករក្នុងការផ្ទេរ លក់ ឬធ្វើអំណោយជាដើម។ ប៉ុន្តែសិទ្ធិរបស់កម្មសិទ្ធិករអាចត្រូវដកហូត ប្រសិនបើការប្រើប្រាស់ទាំងឡាយផ្ទុយនឹងច្បាប់។

ចំណែកឯ សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំលើពូជ ដែលខ្លួនបានបង្កាត់ក៏មិនខុសពីអ្វីដែលបានបង្ហាញខាងលើដែរ ពោលគឺអ្នកបង្កាត់ពូជដំណាំមានសិទ្ធិធំធេងលើពូជដំណាំរបស់ខ្លួន។ រាល់ការប្រើប្រាស់ទាំងឡាយណា ដែលមិនមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ការប្រើប្រាស់ទាំងនោះចាត់ទុកជាការប្រើប្រាស់ដោយខុសច្បាប់។ ប៉ុន្តែអ្វីដែលមានលក្ខណៈខុសប្លែកនោះគឺ ប្រសិនបើស្នើសុំការការពារលើពូជដំណាំបានហើយ ប៉ុន្តែម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំ មិនបានយកទៅអនុវត្តនាំឲ្យមានការដកហូតវិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំមកវិញពីម្ចាស់សិទ្ធិ។ ម៉្យាងវិញទៀត សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំអាចត្រូវបាត់បង់ដោយសារការធ្វើអាជីវកម្មរបស់រដ្ឋ ឬការផ្ទេរសិទ្ធិទាំងស្រុងទៅឲ្យតតិយជនណាម្នាក់តាមការព្រមព្រៀងរបស់ម្ចាស់សិទ្ធិ។ មិនតែប៉ុណ្ណោះ សិទ្ធិការពារលើពូជថ្មីនៃដំណាំមិនអាចប្រើប្រាស់អស់មួយជីវិតនោះទេ ពោលគឺវាមានរយៈពេលកំណត់នៃការការពារ។ សុពលភាពនៃសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល ២០ឆ្នាំ លើកលែងតែដំណាំ ដែលមានលក្ខណៈពិសេស ដូចជាដំណាំវល្លិ និងដំណាំឈើ ដែលមានរយៈពេល ២៥ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ។ ផុតរយៈពេលនៃការការពារនេះ សិទ្ធិការពារលើពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំនឹងអស់សុពលភាពការពារតាមផ្លូវច្បាប់ ហើយវានឹងក្លាយជាទ្រព្យសម្បត្តិសាធារណៈដែលយើងគ្រប់រូបអាចប្រើប្រាស់បាន។

### ខ.សិទ្ធិអនុញ្ញាតឲ្យតតិយជនធ្វើអាជីវកម្ម

#### ១.ការធ្វើអាជីវកម្មបានដោយមានការអនុញ្ញាត

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានសិទ្ធិលក់ ឬផ្ទេរសិទ្ធិការពារពូជដំណាំទៅឲ្យបុគ្គលណាម្នាក់ធ្វើអាជីវកម្មបានដែលរូបភាពទាំងនោះស្តែងឡើងតាមរយៈការផ្ទេរសិទ្ធិនោះឲ្យទៅទាយាទ ឬតាមរយៈកិច្ចសន្យាសហគ្រាសជាដើម ឬអាចជាកិច្ចសន្យាការងារក្នុងករណីម្ចាស់សិទ្ធិពូជដំណាំនោះជានិយោជិត។ អ្នកទាំងនេះ ជាអ្នកកាន់កាប់

សិទ្ធិស្របច្បាប់នូវសិទ្ធិនិងកាតព្វកិច្ចរបស់ពួកគេដូចនឹងម្ចាស់ដើមដែរ។ ចំពោះការលក់ ឬផ្ទេរទៅឲ្យតតិយជន ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវចុះហត្ថលេខាដោយភាគីពាក់ព័ន្ធ ហើយត្រូវកត់ត្រានៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ដោយជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

អ្នកដាក់ពាក្យស្នើសុំការការពារសិទ្ធិការពារពូជថ្មីនៃដំណាំ ឬម្ចាស់សិទ្ធិពូជថ្មីនៃដំណាំអាចប្រគល់ទៅឲ្យតតិយជនដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គលនូវអាជ្ញាប័ណ្ណផ្តាច់មុខ ឬអាជ្ញាប័ណ្ណមិនផ្តាច់មុខទាក់ទងនឹងសិទ្ធិទាំងអស់ ឬសិទ្ធិណាមួយដែលច្បាប់ផ្តល់ឲ្យតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ។ ក្នុងន័យនេះ បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណនោះអាចប្រើប្រាស់សិទ្ធិនោះក្នុងគោលបំណងប្រើប្រាស់ និងអាស្រ័យផលលើពូជដំណាំដែលបានការពារដែលការប្រើប្រាស់នេះ ត្រូវអនុលោមទៅតាមការព្រមព្រៀងទាំងឡាយនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ។ ក្នុងករណី អ្នកបង្កាត់ពូជដំណាំជានិយោជិត ការផ្ទេរទៅឲ្យនិយោជករបស់ខ្លួនតាមរយៈកិច្ចសន្យាការងារ ហើយរាល់ការអនុវត្តសិទ្ធិនិងកាតព្វកិច្ចឬខសំខាន់ផ្សេងៗអាស្រ័យលើការព្រមព្រៀងក្នុងកិច្ចសន្យាការងាររបស់គូភាគី។

## ២.ការធ្វើអាជីវកម្មបានដោយមិនចាំបាច់មានការអនុញ្ញាត

ការធ្វើសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់លើពូជដំណាំដែលបានទទួលការការពារដោយវិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ចាំបាច់ត្រូវមានការយល់ព្រមអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំដើមជាមុនសិន។ ក្នុងករណីបុគ្គលណាម្នាក់ប្រើប្រាស់ដោយមិនមានការអនុញ្ញាត ត្រូវចាត់ទុកជាការប្រើប្រាស់ដោយខុសច្បាប់ ព្រោះរំលោភលើសិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំដើម ឬម្ចាស់ពូជដំណាំដើម។ ផ្ទុយមកវិញ ទាក់ទងទៅនឹងករណីមួយចំនួន គេអាចធ្វើអាជីវកម្មលើពូជថ្មីនៃដំណាំនោះបាន ដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំដើមឡើយ។ ការធ្វើអាជីវកម្មនេះសំដៅលើការធ្វើអាជីវកម្មរបស់រដ្ឋ ឬតតិយជនដែលទទួលបានការអនុញ្ញាតពីរដ្ឋ។ ក្នុងករណីនេះ ទោះបីជាអ្នកបង្កាត់ពូជដំណាំនោះមិនយល់ព្រមក្តី ឬយល់ព្រមក្តី ក៏មិនមែនជាបញ្ហាចោទដែរ មិនតែប៉ុណ្ណោះការធ្វើអាជីវកម្មបែបនេះដោយរដ្ឋ ត្រូវបានចាត់ទុកជាការធ្វើអាជីវកម្មដោយស្របច្បាប់។ ក្នុងករណីនេះ សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំដើមរួមតូចបន្តិច ដែលខុសពីអត្ថន័យនៃពាក្យ ***សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ*** ដែលបានលើកឡើងខាងលើ ដោយសារតែអំណាចសាធារណៈ ដែលមិនខុសពីការធ្វើជាតិតូបនីយកម្មនោះទេ។[52] តែទោះបីជាយ៉ាងណាក៏ដោយផលប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំមិនត្រូវបានបាត់បង់ព្រោះតែបញ្ហានេះទេ ប្រសិនបើរដ្ឋធ្វើអាជីវកម្មដោយខ្លួនឯង រដ្ឋត្រូវចេញសំណងខូចខាតដល់ម្ចាស់សិទ្ធិ តែបើតតិយជនធ្វើអាជីវកម្មតាមរយៈការដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឲ្យផ្តល់អាជ្ញាប័ណ្ណបញ្ជាក្នុងការប្រើប្រាស់ពូជថ្មីនៃដំណាំដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុ-

[52] ការធ្វើឲ្យកម្មសិទ្ធិឯកជនក្លាយជារបស់រដ្ឋ

ជា ហើយក្នុងករណីនេះបុគ្គល ដែលទទួលបានអាជ្ញាប័ណ្ណបញ្ចានោះ ត្រូវបង់ប្រាក់សំណងសមស្របទៅឲ្យម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ។[53]

ក្នុងករណីចាំបាច់មួយចំនួនដើម្បីអនុញ្ញាតឲ្យកសិករផលិត និងប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផលដែលប្រមូលផលបានមកពីការដាំដុះពូជថ្មីនៃដំណាំ ដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្តនោះ ស្ថាប័នជំនាញដែលតំណាងឲ្យរដ្ឋគឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អាចដាក់ចេញនូវបទប្បញ្ញត្តិ ដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនានាបាន។[54]

### គ.សិទ្ធិហាមឃាត់មិនឲ្យតតិយជនធ្វើអាជីវកម្ម

### ១.រយៈពេលនៃការការពារ

រាល់សកម្មភាពទាំងឡាយណា ដែលប៉ះពាល់ដល់សិទ្ធិអ្នកបង្កាត់ពូជដំណាំដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិត្រូវចាត់ទុកជាអំពើខុសច្បាប់ រំលោភលើសិទ្ធិការពារពូជថ្មីនៃដំណាំរបស់អ្នកបង្កាត់ពូជដំណាំ។ ម្ចាស់សិទ្ធិមានសិទ្ធិគ្រប់គ្រាន់ក្នុងការរារាំងការរំលោភនេះ។ បើនិយាយពីសិទ្ធិគ្រប់គ្រងលើពូជដំណាំ ត្រូវគិតពីរយៈពេលនៃការការពារ ពីព្រោះការការពារពូជដំណាំមានអាជ្ញាយុកាលមិនមែនមានសិទ្ធិប្រើប្រាស់ជារៀងរហូតទេ។ រយៈពេលនៃការការពារខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែជាទូទៅ គេកំណត់រយៈពេល ២០ឆ្នាំ សម្រាប់ពូជថ្មីនៃដំណាំធម្មតា និងរយៈពេល ២៥ឆ្នាំ សម្រាប់ដំណាំវល្លិ និងដំណាំឈើ។ [55] ក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ បានកំណត់ថា ***សុពលភាពសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល ២០ឆ្នាំ លើកលែងតែដំណាំដែលមានលក្ខណៈពិសេស ដូចជាដំណាំវល្លិ និងដំណាំឈើ ដែលមានរយៈពេល ២៥ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ*** ។ ក្នុងរយៈពេលនៃការការពារនេះ ម្ចាស់សិទ្ធិពូជថ្មីណៃដំណាំបានទទួលផលចំណេញយ៉ាងច្រើនពីពូជដំណាំរបស់ខ្លួន ទាំងសារៈប្រយោជន៍ផ្លូវច្បាប់ និងប្រាក់ចំណូលផ្សេងៗ ដោយសារតែអំឡុងពេលនេះមានរយៈពេលយូរគួរសមល្មមសម្រាប់ការការពារ ដោយហេតុថាពេលខ្លះ ពូជដំណាំមួយអាចត្រូវបានគេឈប់ប្រើប្រាស់ ឬប្រើប្រាស់តិចតួច នៅពេលដែលអ្នកបង្កាត់ពូជដំណាំដដែល ឬអ្នកបង្កាត់ពូជដំណាំផ្សេងទៀតនោះបានរកឃើញពូជថ្មីៗ ធ្វើឲ្យអ្នកប្រើប្រាស់សម្រេចចិត្តជ្រើសរើសអ្វី ដែលល្អប្រសើរជាងមុននាំឲ្យមានសារៈប្រយោជន៍របស់វាកាន់តែខ្សោយទៅម្តងបន្តិចៗ។ តែទោះបីជាយ៉ាងណាក៏ដោយអំឡុងពេលដែលការពារ គ្មាននរណាម្នាក់អាចប្រើប្រាស់ពូជដំណាំដែលបានស្នើសុំការការពារនោះបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិពូជថ្មីនៃដំណាំទេនោះ។

[53] មាត្រា ៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធអ្នកបង្កាត់ពូជដំណាំ

[54] មាត្រា ១៦ នៃច្បាប់ស្តីពីគ្រប់គ្រងពូជដំណាំ និងសិទ្ធអ្នកបង្កាត់ពូជដំណាំ

[55] មាត្រា ១៩.២ នៃអនុសញ្ញា UPOV ឆ្នាំ ១៩៩១

ការប្រើប្រាស់ជាសាធារណៈនូវពូជដំណាំនោះបាន លុះត្រាតែរយៈពេល ២០ឆ្នាំសម្រាប់ពូជដំណាំធម្មតា ឬ២៥ឆ្នាំសម្រាប់ពូជដំណាំវល្លិ និងពូជដំណាំឈើត្រូវបានបញ្ចប់ ពេលនោះពូជដំណាំនោះលែងក្លាយជារបស់អ្នកបង្កាត់ពូជដំណាំទៀតហើយ គឺមានន័យថា អ្នកបង្កាត់ពូជដំណាំបានបាត់បង់នូវសិទ្ធិជាម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំហើយសិទ្ធិនោះបានធ្លាក់ទៅជារបស់សាធារណជន ដែលមានន័យថាអ្នកណាក៏ដោយក៏មានសិទ្ធិធ្វើអាជីវកម្ម ឬប្រើប្រាស់ដោយមិនចាំបាច់សុំការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំនោះឡើយ។ ប៉ុន្តែអ្នកបង្កាត់ពូជដំណាំនោះ ក៏នៅតែអាចប្រើប្រាស់ពូជដំណាំរបស់ខ្លួនបានដដែលតែគ្មានសិទ្ធិហាមឃាត់រាល់ការធ្វើអាជីវកម្មផ្សេងៗបានឡើយ អ្វីដែលអ្នកបង្កាត់ពូជដំណាំអាចការពារបាន គឺឈ្មោះពូជដំណាំរបស់ខ្លួន[56]។ ការដាក់ឈ្មោះពូជដំណាំ ក៏ជាលក្ខខណ្ឌតម្រូវមួយផងដែរ នៅពេលដែលអ្នកបង្កាត់ពូជដំណាំដាក់ពាក្យស្នើសុំសិទ្ធិការពារពូជថ្មីនៃដំណាំរបស់ខ្លួន ដែលការដាក់ឈ្មោះពូជដំណាំនោះត្រូវតែមានលក្ខណៈសមស្របមិនស្ថិតនៅក្នុងការហាមឃាត់ដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំរបស់កម្ពុជា[57] ដោយមានការត្រួតពិនិត្យ និងវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ។ បន្ទាប់ពីការត្រួតពិនិត្យ វាយតម្លៃ និងមានការឯកភាពលើឈ្មោះដែលបានដាក់ស្នើសុំមកពីក្រសួងសាមីទាំងពីរហើយ វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំត្រូវបានផ្តល់ជូនអ្នកដាក់ពាក្យសុំហើយឈ្មោះរបស់ពូជដំណាំនោះក៏ត្រូវបានបញ្ចូលទៅក្នុងបញ្ជីពូជដំណាំរបស់ជាតិផងដែរ។[58] ឈ្មោះដំណាំនេះហើយដែលត្រូវបានការពារ និងតម្រូវឲ្យប្រើប្រាស់ជាទូទៅ ទោះបីជាសិទ្ធិការពារផុតសុពលភាពក៏ដោយ។ ចំណុចនេះ វាមានលក្ខណៈដូចទៅនឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលផងដែរ។

### ២.ទណ្ឌកម្មនៃការរំលោភសិទ្ធិ

ដូចដែលបានបកស្រាយខាងលើរួចមកហើយ ក្នុងអំឡុងពេលនៃការការពារម្ចាស់សិទ្ធិមានសិទ្ធិគ្រប់យ៉ាងប្រឆាំងនឹងតតិយជនរាល់ការធ្វើសកម្មភាពដោយរំលោភសិទ្ធិ ដែលការរំលោភនេះសំដៅដល់ការអនុវត្តសកម្មភាពរំលោភសិទ្ធិនានារបស់អ្នកបង្កាត់ពូជដំណាំក្នុងការធ្វើអាជីវកម្ម ឬប្រើប្រាស់ពូជដំណាំដែលបានការពារនោះដោយពុំមានការព្រមព្រៀងពីអ្នកបង្កាត់ពូជដំណាំ ដែលទទួលបានសិទ្ធិការពារពូជថ្មីនៃដំណាំនោះម្ចាស់សិទ្ធិមានសិទ្ធិប្តឹងទៅតុលាការអំពីបញ្ហានេះ ដើម្បីធ្វើបណ្តឹងរដ្ឋប្បវេណី ឬស្នើសុំដីការបណ្តោះអាសន្នដើម្បីហាមឃាត់ការប្រព្រឹត្តរំលោភលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬក៏អាចស្នើសុំការផាកពិន័យដល់ជនប្រព្រឹត្តល្មើសតែត្រូវបង្ហាញភស្តុតាងឲ្យច្បាស់លាស់ថាពិតជាមានករណីបែបនេះកើតឡើងមែន។ [59] ការបង្ហាញពីសកម្មភាពនៃការរំលោភ

[56] មាត្រា ២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[57] មាត្រា ២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[58] មាត្រា ៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[59] មាត្រា ៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

សិទ្ធិនេះត្រូវមានទំនាក់ទំនងទៅនឹងពូជដំណាំដែលបានការពារ ដែលស្ថិតក្នុងវិសាលភាពនៃការការពារពូជដំណាំ។ ប៉ុន្តែមានករណីខ្លះទោះបីជាការធ្វើអាជីវកម្ម ឬប្រើប្រាស់ពូជដំណាំដែលបានការពារនោះក៏ដោយ ក៏មិនចាត់ទុកជាការរំលោភសិទ្ធិដែរ ប្រសិនបើការធ្វើអាជីវកម្មលើពូជដំណាំ ដែលអ្នកបង្កាត់ពូជដំណាំនោះបានអនុញ្ញាតឲ្យតតិយជនប្រើប្រាស់រួចហើយ ឬសកម្មភាពនៃការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍ ឬការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនគ្មានបំណងធ្វើអាជីវកម្មដោយបំពាន ឬក៏ការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងទៀត។ មួយវិញទៀត ការដាក់ចេញនូវបទប្បញ្ញត្តិ ដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំ ដែលធ្វើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ដើម្បីអនុញ្ញាតឲ្យកសិករផលិត និងប្រើប្រាស់ក្នុងគោលបំណងយកទៅដាំដុះបន្តនោះ ក៏មិនត្រូវបានគេចាត់ទុកជាការរំលោភសិទ្ធិការពារពូជថ្មីនៃដំណាំដែរ។[60]

ក្នុងករណីដែលតុលាការរកឃើញថាជននោះពិតជាមានចេតនារំលោភសិទ្ធិការពារពូជថ្មីនៃដំណាំដូចនឹងអ្វីដែលម្ចាស់សិទ្ធិបានលើកឡើងមែននោះ នោះជននោះនឹងប្រឈមនឹងការផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀលទៅម្ភៃលានរៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៥ឆ្នាំ ឬផ្តន្ទាទោសទាំងពីរនេះ ហើយក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[61]

ពូជដំណាំមួយកាលបើបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវហើយនោះ នោះពូជដំណាំនោះនឹងត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់វិញ ហើយផ្តល់សិទ្ធិឲ្យម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំប្រឆាំងនូវរាល់ទម្រង់នៃការរំលោភបំពានសិទ្ធិទាំងឡាយណា ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់សិទ្ធិ។ តែផ្ទុយទៅវិញ ប្រសិនបើអ្នកបង្កាត់ពូជដំណាំផ្តល់ព័ត៌មានមិនពិត ដែលដាក់សុំការការពារពូជថ្មីនៃដំណាំក្នុងគោលបំណងចង់ក្លាយខ្លួនជាម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនោះ អ្នកបង្កាត់ពូជដំណាំនោះ ក៏នឹងត្រូវប្រឈមមុខនឹងការផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀលទៅប្រាំលានរៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ៦ខែ ឬត្រូវផ្តន្ទាទោសទាំងពីរនេះផងដែរ ហើយក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[62]

## កថាខណ្ឌ៣ ការបញ្ចប់ មោឃភាព និងការលុបចោល

### ១.ការបញ្ចប់

សិទ្ធិការពារពូជថ្មីនៃដំណាំ នឹងត្រូវបានបញ្ចប់មុនកាលបរិច្ឆេទផុតសុពលភាពក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជីនៃក្រសួងក្រសួង

[60] មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[61] មាត្រា ៧២ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[62] មាត្រា ៧១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ ។ កាលបរិច្ឆេទនៃការបញ្ចប់ ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬបើគ្មានការកំណត់កាលបរិច្ឆេទសុំបញ្ចប់ច្បាស់លាស់នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ។

## ២.ការប្រកាសមោឃភាពនៃសិទ្ធិ

មន្ត្រីកាន់កាប់បញ្ជី ត្រូវប្រកាសជាមោឃភាពនូវសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំក្នុងករណីរកឃើញថា៖[63]

- លក្ខខណ្ឌដូចដែលមានចែងនៅក្នុងមាត្រា៧ ឬមាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨ មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ។
- លក្ខខណ្ឌដូចដែលមានចែងនៅក្នុងមាត្រា៩ ឬមាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨ មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ ដោយផ្អែកលើព័ត៌មាននិងឯកសារដែលផ្តល់ដោយអ្នកបង្កាត់ពូជដំណាំ។
- សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ត្រូវបានផ្តល់ទៅឲ្យបុគ្គលដែលគ្មានសិទ្ធិទទួល លើកលែងតែសិទ្ធិនេះផ្ទេរទៅឲ្យបុគ្គលដែលមានសិទ្ធិទទួល។

## ៣.ការលុបសិទ្ធិ

មន្ត្រីកាន់កាប់បញ្ជី ត្រូវលុបសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក្នុងករណីដូចខាងក្រោម៖[64]

- លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៩ ឬមាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨ លែងបំពេញបាន។
- ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មិនបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជីដោយ៖
  - ➢ មិនបានផ្តល់នូវព័ត៌មាន ឯកសារ ឬពូជដំណាំ ដែលចាំបាច់សម្រាប់ការផ្ទៀងផ្ទាត់
  - ➢ ខកខានមិនបានបង់កម្រៃ ដើម្បីរក្សាសិទ្ធិឲ្យនៅជាធរមាន ឬ
  - ➢ មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែលទទួលបានសិទ្ធការពារនោះត្រូវបានលុប។

[63] មាត្រា ២១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[64] មាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាចំពោះប្រធានបទខាងលើរួចមក បានបង្ហាញពីឥទ្ធិពលនៃកិច្ចព្រមព្រៀងផ្នែកកម្មសិទ្ធិបញ្ញា និង ពាណិជ្ជកម្មទ្វេភាគី (BAT) រវាងកម្ពុជាជាមួយសហរដ្ឋអាមេរិចនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦ ហើយចូលជាធរមាននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦ បានធ្វើឲ្យជាប់កាតព្វកិច្ចក្នុងការក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញាជាច្រើន ដែលក្នុងនោះក៏មានបណ្តាអនុសញ្ញាដែលទាក់ទងនឹងការការពារពូជដំណាំផងដែរ ដូចជាអនុសញ្ញាអន្តរជាតិស្តីពីការការពារការបង្កាត់ពូជដំណាំឆ្នាំ១៩៧៨ ឬ ឆ្នាំ១៩៩១ ជាដើម ដែលនេះជាចំណុចចាប់ផ្តើមមួយ ដែលធ្វើឲ្យកម្ពុជាមានគំនិតនៅក្នុងការបង្កើតឲ្យមានយន្តការនៃការការពារពូជថ្មីនៃដំណាំនៅក្នុងកម្ពុជា។ ក្រោយពីប្រទេសកម្ពុជាបានធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោកតាមរយៈ ការចូលជាសមាជិកអង្គការពាណិជ្ជពិភពលោកនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ និងបានក្លាយជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងTRIPS ដែលតាមរយៈកិច្ចព្រមព្រៀងនេះ គឺតម្រូវឲ្យសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO) ទាំងអស់ផ្តល់ការការពារលើពូជថ្មីនៃដំណាំ។ យន្តការនៃការការពារសម្រាប់ប្រភេទពូជដំណាំផ្សេងៗទៀត អាចត្រូវបានផ្តល់តាមរយៈប្រកាសសនីយបត្រតក្កកម្ម ឬ ដោយប្រព័ន្ធដោយឡែកដ៏មានប្រសិទ្ធភាពមួយ (effective subgenres system) ឬក៏ដោយការរួមបញ្ចូលគ្នាណាមួយនៃប្រព័ន្ធទាំងពីរ។

ព្រះរាជាណាចក្របានជ្រើសរើសយកប្រព័ន្ធនៃការការពារពូជថ្មី នៃដំណាំតាមរយៈប្រព័ន្ធដាច់ដោយឡែក (effective sui generis system) ដោយមិនបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីប្រកាសសនីយបត្រតក្កកម្មឡើយ ពោលគឺ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិបង្កាត់ពូជដំណាំកាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ។ មកទល់នឹងសព្វថ្ងៃនេះ បើទោះបីជាប្រទេសកម្ពុជាមានច្បាប់ទាក់ទងនឹងការការពារពូជដំណាំហើយក៏ដោយ ក៏ការអនុវត្តនៅមិនទាន់ធ្វើនៅឡើយទេ គឺត្រូវរង់ចាំឲ្យមានលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀតនៅក្នុងការបំពេញបន្ថែមទៅលើច្បាប់គោលដែលមានស្រាប់ ក្នុងគោលបំណងដើម្បីធានាការអនុវត្តប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងមានប្រសិទ្ធិភាព ប៉ុន្តែមកទល់នឹងពេលនេះកម្ពុជាមិនទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយដើម្បីបំពេញបន្ថែមទៅលើច្បាប់គោលនៅឡើយទេ។ ដោយយល់ឃើញពីភាពចាំបាច់ ក្រុមការងារបច្ចេកទេសមកពីបណ្តាស្ថាប័នពាក់ព័ន្ធនានា រួមទាំងអ្នកជំនាញមកពីសហភាព UPOV បាននឹងកំពុងសិក្សាពីលទ្ធផលនៃការអនុវត្តការការពារពូជដំណាំ ព្រមទាំងរៀបចំបណ្តាលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងនីតិវិធីអនុវត្តឲ្យបានឆាប់រហ័សតាមការដែលអាចធ្វើទៅបាន។

នៅក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងយន្តការនៃការការពារការបង្កាត់ពូជថ្មីនៃដំណាំនៅក្នុងប្រទេសកម្ពុជា ការបណ្តុះបណ្តាលធនធានមនុស្ស និងអ្នកជំនាញនានាទាក់ទងនឹងការបង្កាត់ពូជដំណាំក៏ជាបញ្ហាមួយដែលគួរតែយកចិត្តទុកដាក់ផងដែរ។ នៅក្នុងយន្តការនៃការការពារពូជថ្មីនៃដំណាំអាចដំណើរការ

ទៅបានដោយរលូននោះ វាទាមទារឲ្យមានបណ្តាលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការការពារឲ្យបានគ្រប់គ្រាន់សមស្របទៅតាមបទដ្ឋានអន្តរជាតិ ហើយក៏តម្រូវឲ្យមានអ្នកជំនាញនានាដើម្បីអនុវត្តយន្តការនោះផងដែរ។

មិនតែប៉ុណ្ណោះក្រៅពីតម្រូវការអ្នកជំនាញបច្ចេកទេស កម្ពុជាក៏នៅត្រូវការឧបករណ៍បច្ចេកទេស និងបច្ចេកវិទ្យាទំនើបៗ ដើម្បីបម្រើការឲ្យការងារត្រួតពិនិត្យពូជដំណាំផងដែរ។ ចំពោះករណីនេះ យើងសង្ឃឹមថា បណ្តាអង្គការអន្តរជាតិដែលធ្វើសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ដូចជាអង្គការ JICA អង្គការ KOICA សហភាពUPOV ព្រមទាំងបណ្តាប្រទេសជាមិត្តរបស់កម្ពុជា ដូចជាប្រទេសជប៉ុន ប្រទេសកូរ៉េ ប្រទេសចិន ជាដើម នឹងជួយប្រទេសកម្ពុជានៅក្នុងការបំពាក់ឧបករណ៍បរិក្ខាទំនើបៗ នៅក្នុងមន្ទីរពិសោធន៍ដើម្បីងាយស្រួលក្នុងការតេស្តពិសោធន៍ពូជដំណាំនិងមិនធ្វើឲ្យខូចប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំ។

សរុបសេចក្តីមក យើងឃើញថា បើទោះបីជាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្រុមប្រឹក្សានៃសហភាព UPOV មិនទាន់បានក្លាយជាសមាជិកពេញសិទ្ធិរបស់សហភាព UPOV ក៏ដោយ ក៏ប្រទេសកម្ពុជាបានបង្កើតនៅច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ព្រមទាំងបានបំពេញនូវភារកិច្ចជាច្រើនយ៉ាងសកម្ម ដើម្បីបំពេញកាតព្វកិច្ចនានាដែលមានកំណត់ដោយកិច្ចព្រមព្រៀងអន្តរជាតិ ក្នុងគោលដៅដើម្បីអភិវឌ្ឍប្រទេសកម្ពុជាឲ្យបានរីកចម្រើន ជាពិសេសគឺវិស័យកសិកម្ម។ ហើយវិស័យនេះក៏ជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងត្រឹមត្រូវបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ជាចក្ខុវិស័យ យើងសង្ឃឹមថា យន្តការនៃការការពារពូជថ្មីនៃដំណាំនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព និងការជឿជាក់ ហើយទន្ទឹមនឹងនោះ កម្ពុជានឹងក្លាយជាសមាជិកពេញសិទ្ធិរបស់សហភាពអន្តរជាតិការពារពូជថ្មីនៃដំណាំ តាមរយៈការខិតខំប្រឹងប្រែងយ៉ាងសកម្មកន្លងមករបស់ខ្លួន។

# អនុសាសន៍

# អនុសាសន៍

នៅក្នុងការជម្រុញឲ្យការអនុវត្តយន្តការការពារពូជថ្មីនៃដំណាំនៅកម្ពុជា អាចដំណើរការទៅបានយ៉ាងរលូននិង មានប្រសិទ្ធិភាពនោះ យើងខ្ញុំសូមផ្តល់អនុសាសន៍ដល់ស្ថាប័នពាក់ព័ន្ធទទួលបន្ទុកនៅលើវិស័យនេះទាំងអស់គួរតែអនុវត្តកិច្ចការមួយចំនួនដូចជា៖

-យកចិត្តទុកដាក់នូវក្នុងការពង្រឹងទៅលើការបណ្តុះបណ្តាលធនធានមនុស្ស និងអ្នកជំនាញលើការចុះបញ្ជីការពារពូជថ្មីនៃដំណាំឲ្យបានច្បាស់លាស់ ក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្សនិងអ្នកជំនាញទៅលើការពិសោធន៍និងការធ្វើតេស្តសាកល្បងទៅលើបច្ចេកទេសនៃពូជដំណាំដើម្បីដឹងច្បាស់ថាពូជដំណាំមួយមានស្ថេរភាព ឯកសណ្ឋានភាព និងភាពប្លែកឬអត់ ទាំងអស់នេះជាកត្តាសំខាន់ខ្លាំងបំផុត ដោយហេតុថាវាទាក់ទងនឹងប្រសិទ្ធិភាពនៃការអនុវត្ត និងទាក់ទងទៅនឹងផលប្រយោជន៍ជាមូលដ្ឋានរបស់ម្ចាស់ពូជដំណាំ ម្យ៉ាងទៀតវាក៏អាចធ្វើឲ្យបាត់បង់នូវការជឿជាក់ពីម្ចាស់ពូជដំណាំផងដែរ។

-ត្រូវបង្កើនកិច្ចសហប្រតិបត្តិការឲ្យបានច្រើន ទាំងកិច្ចសហប្រតិបត្តិការនៅក្នុងថ្នាក់តំបន់និងកិច្ចសហ-ប្រតិបត្តិការជាអន្តរជាតិដែលទាក់ទងនឹងការការពារពូជថ្មីនៃដំណាំ ក៏ដូចជាកិច្ចសហប្រតិបត្តិជាមួយប្រទេសដែលជាបណ្តាមិត្តរបស់កម្ពុជាដែលមានបច្ចេកវិទ្យាទំនើប ដើម្បីចែករំលែកបទពិសោធន៍ពីការរីកចម្រើននៃប្រព័ន្ធការពារពូជថ្មីនៃដំណាំរបស់គេមកពង្រឹងការអនុវត្តនៅក្នុងប្រទេស។ មួយវិញទៀត តាមរយៈកិច្ចសហប្រតិបត្តិការនេះកម្ពុជាត្រូវការជំនួយបច្ចេកទេសជាលំហូរនៃបច្ចេកទេស ឧបករណ៍បរិក្ខាបំពាក់ក្នុងមន្ទីរពិសោធន៍ ការបណ្តុះ-បណ្តាលធនធានមនុស្សតាមរយៈការបញ្ជូនអ្នកជំនាញទៅសិក្សាវគ្គសិក្សារយៈពេលខ្លីនិងវែង ក៏ដូចជាការបញ្ជូនអ្នកជំនាញបរទេសមកបណ្តុះបណ្តាលនៅក្នុងប្រទេសជាដើម។

-ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយពីប្រព័ន្ធនៃការការពារពូជថ្មីនៃដំណាំនៅក្នុងកម្ពុជា ដោយហេតុថាប្រជាពលរដ្ឋនៅក្នុងប្រទេសមានការយល់ដឹងអំពីយន្តការការពារនេះនៅតិចតួចណាស់។

-ជម្រុញឲ្យមានការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់ដល់ដំណើរការនៃការអនុវត្តការការពារពូជថ្មីនៃដំណាំឲ្យកាន់តែលឿនជាមុនដើម្បីឲ្យការអនុវត្តនូវយន្តការនោះបានឆាប់រហ័សផងដែរ។

-បច្ចុប្បន្ននេះប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្នុងក្រុមប្រឹក្សានៃសហភាពអន្តរជាតិការការពារពូជថ្មីនៃដំណាំប៉ុណ្ណោះ។ សម្រាប់ចក្ខុវិស័យទៅថ្ងៃអនាគត យើងសង្ឃឹមថាក្រុមការងារបច្ចេកទេសក៏ដូចជាស្ថាប័នពាក់ព័ន្ធនឹងបន្តការខិតខំប្រឹងប្រែងបន្តទៀត ដើម្បីក្លាយជាសមាជិកពេញសិទ្ធិនៃអង្គការមួយនេះ។

-សង្ឃឹមថាទៅថ្ងៃអនាគត ប្រសិនបើមានខ្វះខាតលិខិតបទដ្ឋានគតិយុត្តលើការការពារពូជថ្មីនៃដំណាំនោះ ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកទាំងអស់គួរតែរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់បន្ថែមទៀតដើម្បីជម្រុញឲ្យការអនុវត្តមានប្រសិទ្ធិភាពនិងភាពជឿជាក់ខ្ពស់ពីម្ចាស់ពូជដំណាំ។

-អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ យើងឃើញថាក្រសួងដែលមានសមត្ថកិច្ចសម្រាប់អនុវត្តការការពារការបង្កាត់ពូជដំណាំនៅកម្ពុជា មានក្រសួង២ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេសនិងនវានុវត្តន៍និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទវិញ ពីព្រោះបើយើងពិនិត្យទៅលើបណ្តាប្រទេសជិតខាងយើងក៏ដូចជាប្រទេសជឿនលឿនភាគច្រើន ដូចជាប្រទេសចិនប្រទេសជប៉ុនជាដើមយើងឃើញថា ក្រសួងមានសមត្ថកិច្ចសម្រាប់អនុវត្តការការពារការបង្កាត់ពូជដំណាំគឺក្រសួងកសិកម្ម។

-ម្យ៉ាងវិញទៀត បច្ចុប្បន្ននេះកម្ពុជាកំពុងយកចិត្តទុកដាក់លើការអនុវត្តនូវកម្មវិធីច្រកចេញចូលតែមួយនៅតាមបណ្តាស្ថាប័ននានារបស់រដ្ឋផងដែរ។ ការផ្តល់សមត្ថកិច្ចផ្តាច់មុខទៅឲ្យក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទតែមួយ ធ្វើឲ្យចំណេញពេលវេលានិងថវិការបស់អ្នកដាក់ពាក្យស្នើរសុំការការពារពូជថ្មីនៃដំណាំ ព្រមទាំងមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកដាក់ពាក្យស្នើសុំការការពារពូជថ្មីនៃដំណាំ ដែលបណ្តាលមកពីភាពយឺតយ៉ាវនៃនីតិវិធីផងដែរ។ លើសពីនេះទៅទៀត ប្រសិនបើនៅពេលអនាគត វិស័យកម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងក្លា ដូចនៅបណ្តាប្រទេសជឿនលឿនដទៃទៀតនោះ កម្ពុជាគួរតែបង្កើតឲ្យមាននូវការិយាល័យកម្មសិទ្ធិបញ្ញា ដែលមានតួនាទីចុះបញ្ជីនូវរាល់ទម្រង់ទាំងអស់នៃកម្មសិទ្ធិបញ្ញា។

# ឯកសារយោង

# ឯកសារយោង

## ក.បទដ្ឋានអន្តរជាតិ

១.កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (Agreement on Trade Related Aspect of Intellectual Property Right "TRIPS"),1994

២.អនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម (Paris Convention for the Protection of Industrial Property) អនុម័តដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ និងវិសោធនកម្មចុងក្រោយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

៣.អនុសញ្ញាសហព័ន្ធអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំឆ្នាំ១៩៩១ (International Convention for the Protection of New Varieties of Plants)1991

៤.អនុសញ្ញាសហព័ន្ធអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំឆ្នាំ១៩៦១ (International Convention for the Protection of New Varieties of Plants)1961

៥.អនុសញ្ញាសហព័ន្ធអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំឆ្នាំ១៩៧២ (International Convention for the Protection of New Varieties of Plants)1972

៦.អនុសញ្ញាសហព័ន្ធអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំឆ្នាំ១៩៧៨ (International Convention for the Protection of New Varieties of Plants)1978

៧.អនុសញ្ញាអន្តរជាតិស្តីពីធនធានសេនេទិចរុក្ខជាតិសម្រាប់ស្បៀងអាហារ និងកសិកម្ម (International Convention for Plant genetic resources for food and agriculture)

៨.អនុសញ្ញាស្តីពីភាពខុសប្លែកគ្នានៃជីវសាស្ត្រ (Convention on Biological Diversity)

៩.កិច្ចព្រមព្រៀង Marrakesh (Agreement Marrakesh)

## ខ.បទដ្ឋានជាតិ

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២. ស្តីពីច្បាប់ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣

៣. ស្តីពីច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

៤. ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

៥.អនុក្រឹត្យលេខ ៣៥ អនក្រ.កប ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែនិង ថាមពល

៦.អនុក្រឹត្យលេខ ១៤២ អនក្រ.កប ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

៧.ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៧

៨. ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

## គ.សៀវភៅ និងឯកសារផ្សេងៗ

១.ការពន្យល់និងឧទាហរណ៍: *កម្មសិទ្ធិបញ្ញា* រៀបរៀងដោយក្រសួងពាណិជ្ជកម្ម
ការពន្យល់និងឧទាហរណ៍:*មូលដ្ឋានគ្រឹះនៃច្បាប់ពាណិជ្ជកម្ម* រៀបរៀងដោយក្រសួងពាណិជ្ជកម្ម
២.កម្រងឯកសារស្ដីពី *សិក្ខាសាលាកម្មសិទ្ធិបញ្ញានៅកម្ពុជា* (ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៨ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)
៣.កម្រងឯកសារស្ដីពី *កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក: បទឧទ្ទេសនាមរបស់ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានក្រុមចចារកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក* (ខែសីហា ឆ្នាំ២០០៤ រាជធានីភ្នំពេញ)
៤.បណ្ឌិត ចាប សុថារិទ្ធ *កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក: កាលានុវត្តភាព និងការប្រឈម* វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព, ភ្នំពេញ , ២០១១
៥.សាស្ត្រាចារ្យ ខាំ សុមករា *នីតិកម្មសិទ្ធិបញ្ញា* ភ្នំពេញ ,២០១១
៦.ឯកសារនីតិកម្មសិទ្ធិបញ្ញា រៀបរៀងដោយសាស្ត្រាចារ្យ ឃឹម គីរី សម្រាប់ឆ្នាំសិក្សា ២០១១-២០២០
៧.របាយការណ៍បូកសរុបការងារឆ្នាំ២០១១ និងទិសដៅឆ្នាំ២០១២ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម
៨.សាស្ត្រាចារ្យ ជា គឹមអៀង *សៀវភៅពន្យល់ពាក្យជីវវិទ្យាសម្រាប់ថ្នាក់ទី១០ ១១ និង១២*
៩.សាស្ត្រាចារ្យ ធូ ភន *សៀវភៅពន្យល់ពាក្យជីវិទ្យាសម្រាប់ថ្នាក់ទី១០ ១១ និង១២*
១០.DVD ស្ដីពីចំណេះដឹងលើកម្មសិទ្ធិបញ្ញារបស់ ECAP II
១១.ការពន្យល់និងឧទាហរណ៍: *នីតិកម្មសិទ្ធិបញ្ញា* រៀបរៀងដោយ ឯកឧត្តម ឥន យឿន និង សាស្ត្រាចារ្យ អ៊ុក វណ្ណារ័ត្ន (បោះពុម្ពលើកទី១) ឆ្នាំ ២០១៣

## ឃ.គេហទំព័រ

១. http;//www.upov.int/eng/brief.htm (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ ២០២០

២.http;//www.upov.int/en/publications/conventions/index.html(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៣.http;//www.patentlens.net/daisy/bios/1234#upov(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០២០)

៤. http;//www.gdi.mime.gov.kh/(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៥. http;//www.ecap-project.org/inder.php?q=asean ip offices(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៦. http;//www.unescap,org/tid/mtg/ip cam.pdf(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៧. http;//www.wipo.int/directory/en/contact.jsp?country id=90&-type=ADMIN IP(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៨. http;//ebookbrowse.com/Cambodia-0723-pdf-d157622143(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

៩. http;//ppvtpp.setjen.deptan.go.id.ing.promedia,co>id/berita-193-the-4th-cast-asta-plant-variety-(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)
១០. http;//www.wto.org/English/thewto e/tif e/fact l l.htm(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)
១១.http;//en.wikipedia.org/wiki/Developed country(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០២០)
១២.http;//www.wipo.int/wipolex/en/other treaties/parties.jsp?treAtY id=255&group id=22(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)
១៣.http;//en.wikipedia.org/wiki/Word Trade Organization(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)
១៤. www.ecapwww.ecap-project.orgproject.orgnmorey@epo.orgnmorey@org(កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១. ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិបង្កាត់ពូជដំណាំ

២. Agreement on Trade-related aspects of Intellectual Property Rights (TRIPs)

៣. International Convention for the Protection of New Varieties of Plant (UPOV)

៤. តារាងពូជស្រូវនៅកម្ពុជា

# ឧបសម្ព័ន្ធទី១
# ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង
# សិទ្ធិបង្កាត់ពូជដំណាំ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានអនុម័ត កាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាល ទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងពូជដំណាំ

# និង

# សិទ្ធិអ្នកបង្កាត់ពូជដំណាំ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឱ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និង ការការពារពូជថ្មីនៃដំណាំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណង ធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និង ការអភិវឌ្ឍពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថាន ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ពូជដំណាំ រួមទាំងពូជដំណាំដែលមានស្រាប់ និង ពូជថ្មីនៃដំណាំ លើកលែងតែការគ្រប់គ្រង ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៤.-**

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
# ការការពារពូជថ្មីនៃដំណាំ

## ផ្នែកទី ១
## លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

**មាត្រា ៦.-**

ពូជថ្មីនៃដំណាំដែលទទួលបាននូវសិទ្ធិការពារត្រូវមានលក្ខណវិនិច្ឆ័យ ដូចខាងក្រោម:

-ភាពថ្មី

-ភាពខុសប្លែក

-ឯកសណ្ឋានភាព

-ស្ថេរភាព ។

**មាត្រា ៧.-**

ពូជដំណាំ ដែលអាចចាត់ទុកថាថ្មី លុះត្រាតែពុំទាន់បានដាក់លក់ ឬ ចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬ ចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី ១ (មួយ)ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មិនលើសពី ៦(ប្រាំមួយ)ឆ្នាំ ចំពោះដំណាំវល្លិ និងដំណាំឈើ និងមិនលើសពី ៤(បួន) ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងៗទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ ។

**មាត្រា ៨.-**

ពូជដំណាំដែលចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬ កាលបរិច្ឆេទសិទ្ធិអាទិភាព ។

ROYAUME DU CAMBODGE

មាត្រា ៩.-

ពូជដំណាំ ដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សាឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះ ត្រូវបានផលិតតាមរយៈភេទ ឬ អភេទក្តី ។

មាត្រា ១០.-

ពូជដំណាំ ដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ ។

## ផ្នែកទី ២

## វិសាលភាព និងសុពលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

មាត្រា ១១.-

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានបង្កាត់ ឬ រកឃើញ និង អភិវឌ្ឍពូជថ្មីនៃដំណាំ ហើយមានបំណងការពារកម្មសិទ្ធិបញ្ញាលើពូជថ្មីនោះ ត្រូវដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបញ្ជូនឯកសារនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់នេះ ។

វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រោយពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ១២.-

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាស្ថាប័នទទួលខុសត្រូវក្នុងការចុះបញ្ជីការពារពូជថ្មីនៃដំណាំ មានតួនាទីដូចខាងក្រោម :

១-ផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ

២-ផ្ទាស់ប្តូរម្ចាស់កម្មសិទ្ធិ

៣-ប្រកាសមោឃភាព ឬ លុបចោល

៤-ទទួលពាក្យចុះបញ្ជី ផ្លាស់ប្តូរ ឬ លុបចោលឈ្មោះពូជថ្មីនៃដំណាំ

៥-ចេញអាជ្ញាប័ណ្ណបញ្ជា និង

៦-កត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ ។

**មាត្រា ១៣.-**

អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីនៃដំណាំ ត្រូវ :

ក-មានសញ្ជាតិជាខ្មែរ ឬ សញ្ជាតិបរទេស ប៉ុន្តែត្រូវមាននិវេសនដ្ឋានទៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ខ-មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬ នៅរដ្ឋណាមួយ ដែលមានបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានសិទ្ធិលក់ ឬ ផ្ទេរសិទ្ធិរបស់ខ្លួនបាន ។ ការលក់ ឬ ការផ្ទេរទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយភាគីពាក់ព័ន្ធ ហើយត្រូវកត់ត្រានៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១៥.-**

ការយកពូជ ឬ បំណែកពូជ ដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាព ការផលិត ឬ ការផលិតឡើងវិញ ការកំណត់លក្ខខណ្ឌក្នុងគោលបំណងពង្រីកពូជ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬ ការចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល និង ការធ្វើសន្និធិ ត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

ម្ចាស់សិទ្ធិ អាចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ពូជដំណាំរបស់ខ្លួន ដោយភ្ជាប់នូវលក្ខខណ្ឌ ឬ ការកំណត់ផ្សេងៗ ។

ការធ្វើអាជីវកម្ម និង ប្រើប្រាស់ ដូចមានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះនូវផលិតផលដែលប្រមូលបានពីការដាំដុះពូជថ្មីនៃដំណាំ ដោយពុំមានការអនុញ្ញាត ត្រូវសុំ

ការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ ម្ចាស់សិទ្ធិមានឱកាសសមស្របក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ។ នៅពេលម្ចាស់សិទ្ធិបានដឹងពីការប្រើប្រាស់ និង ធ្វើអាជីវកម្ម ដោយពុំមានការអនុញ្ញាត តែមិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួន ម្ចាស់សិទ្ធិនឹងបាត់សិទ្ធិប្តឹងតវ៉ា ។

សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក៏មានវិសាលភាពគ្របដណ្តប់ផងដែរទៅលើពូជ :

-ដែលបានបង្កើតថ្មី ដោយយកលក្ខណៈពិសេសសំខាន់ៗចេញពីពូជបានការពារ

-ដែលពុំមានភាពខុសគ្នាដាច់ស្រឡះ ពីពូជបានការពារ

-ដែលផលិតកម្មរបស់វាត្រូវការប្រើប្រាស់ឡើងវិញនូវពូជដែលបានការពារ ។

**មាត្រា ១៦.-**

សិទ្ធិការពារពូជថ្មីនៃដំណាំ ពុំមានវិសាលភាពគ្របដណ្តប់ចំពោះករណីដូចខាងក្រោម :

១-ការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍

២-ការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម

៣-ការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងទៀត លើកលែងតែវាក្យខណ្ឌទី ៤ មាត្រា ១៥ នៃច្បាប់នេះ ។

ដោយផ្អែកលើការការពារផលប្រយោជន៍ស្របច្បាប់ និង ព្រំដែនសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចដាក់ចេញនូវបទប្បញ្ញត្តិដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនានា ដើម្បីអនុញ្ញាតឱ្យកសិករផលិត និង ប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផលដែលប្រមូលផលបានពីការដាំដុះពូជថ្មីនៃដំណាំ ដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្ត ។

**មាត្រា ១៧.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ត្រូវបាត់បង់សិទ្ធិចំពោះបំណែកពូជនៃពូជដែលទទួលបានការការពារ ឬ ពូជដំណាំដូចមានចែងក្នុងវាក្យខណ្ឌទី ៤ នៃមាត្រា ១៥ ដែលត្រូវបានដាក់លក់ ឬ ចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិ ឬ មានការយល់

ព្រមពីម្ចាស់សិទ្ធិ ។ សិទ្ធិខាងលើនឹងមិនបាត់បង់ទេ ក្នុងករណីពូជ ឬ បំណែកពូជដែលយកចេញពីពូជដែលបានការពារ ត្រូវបានយកទៅពង្រីកពូជបន្ត ឬ នាំចេញទៅពង្រីកពូជក្នុងប្រទេសដែលមិនផ្តល់ការការពារ លើកលែងតែក្នុងគោលបំណងយកទៅប្រើប្រាស់ចុងក្រោយ ។

**មាត្រា ១៨.-**

ក្នុងរយៈពេលអនុវត្តសិទ្ធិ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានកាតព្វកិច្ចផ្តល់សំណាកពូជដែលអាចដុះបាន ហើយមានចរិតលក្ខណៈដូចបានបញ្ជាក់ក្នុងសំណុំលិខិតស្នើសុំសិទ្ធិការពារ តាមតម្រូវការរបស់អង្គភាពមានសមត្ថកិច្ច ។

ក្នុងគោលបំណងថែរក្សាពូជថ្មីនៃដំណាំ ម្ចាស់សិទ្ធិក៏មានកាតព្វកិច្ចផ្តល់ព័ត៌មាននានាដែលពាក់ព័ន្ធនឹងពូជថ្មីនៃដំណាំ និង បង្កភាពងាយស្រួលក្នុងការត្រួតពិនិត្យដល់អង្គភាពមានសមត្ថកិច្ច ។

**មាត្រា ១៩.-**

សុពលភាពសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល ២០ (ម្ភៃ) ឆ្នាំ លើកលែងតែដំណាំដែលមានលក្ខណៈពិសេសដូចជាដំណាំវល្លិ និងដំណាំឈើ ដែលត្រូវមានរយៈពេល ២៥ (ម្ភៃប្រាំ) ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ ។

## ផ្នែកទី ៣
## ការបញ្ចប់ មោឃភាព និងការលុបចោល

**មាត្រា ២០.-**

សិទ្ធិការពារពូជថ្មីនៃដំណាំនឹងត្រូវបានបញ្ចប់មុនកាលបរិច្ឆេទផុតសុពលភាព ក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយផ្ញើលិខិតជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

កាលបរិច្ឆេទនៃការបញ្ចប់ ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ បើគ្មានការកំណត់កាលបរិច្ឆេទសុំបញ្ចប់ច្បាស់លាស់ នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ ។

ROYAUME DU CAMBODGE

**មាត្រា ២១.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវប្រកាសជាមោឃភាពនូវសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្នុងករណីរកឃើញថា :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៧ ឬ មាត្រា ៨ នៃច្បាប់នេះមិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ

២-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ មិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ ដោយផ្អែកលើព័ត៌មាន និង ឯកសារដែលផ្តល់ដោយអ្នក បង្កាត់ពូជដំណាំ

៣-សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ត្រូវបានផ្តល់ទៅឱ្យបុគ្គលដែលគ្មានសិទ្ធិទទួល ។

**មាត្រា ២២.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវលុបសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ក្នុងករណីដូចខាងក្រោម :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ លែងបំពេញ បាន

២-ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មិនបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់ បញ្ជី ដោយ :

ក-មិនបានផ្តល់នូវព័ត៌មាន ឯកសារ ឬ ពូជដំណាំ ដែលចាំបាច់សម្រាប់ ការផ្ទៀងផ្ទាត់

ខ-ខកខានមិនបានបង់កម្រៃ ដើម្បីរក្សាសិទ្ធិឱ្យនៅជាធរមាន ឬ

គ-មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែល ទទួលបានសិទ្ធិការពារនោះ ត្រូវបានលុប ។

## ផ្នែកទី ៤

## ការដាក់ពាក្យ និង សិទ្ធិអាទិភាព

**មាត្រា ២៣.-**

អ្នកដាក់ពាក្យសុំការពារពូជថ្មីនៃដំណាំ ត្រូវដាក់ពាក្យជូនមន្ត្រីកាន់កាប់បញ្ជីតាមគំរូ ពាក្យសុំដែលបានកំណត់ ។

៦

អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ឯកសារ ឬ ពូជដំណាំ តាមកាលបរិច្ឆេទ និង ទីកន្លែង ដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ។

មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះកាលបរិច្ឆេទទទួលពាក្យសុំ បន្ទាប់ពីបានបង់កម្រៃរួច ។

គំរូពាក្យសុំ ឯកសារ ឬ ពូជដំណាំនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២៤.-**

អ្នកដាក់ពាក្យសុំ អាចប្រើប្រាស់សិទ្ធិអាទិភាពនៃពាក្យសុំលើកដំបូងនៅបរទេសសម្រាប់ពូជដំណាំដូចគ្នានៅប្រទេសណាមួយដែលជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ។

ក្នុងករណីមានពាក្យសុំច្រើននៅច្រើនប្រទេស សិទ្ធិអាទិភាពនឹងត្រូវផ្តល់ចំពោះតែការដាក់ពាក្យសុំលើកដំបូងបង្អស់ ។

អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់សិទ្ធិអាទិភាពឱ្យបានច្បាស់លាស់ក្នុងពាក្យសុំដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយសិទ្ធិអាទិភាពត្រូវមានរយៈពេល ១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យលើកដំបូងបង្អស់ ។

**មាត្រា ២៥.-**

ដើម្បីប្រើប្រាស់សិទ្ធិអាទិភាពរបស់ខ្លួនបាន អ្នកដាក់ពាក្យសុំត្រូវប្រគល់ឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់ដំបូងបង្អស់ចំនួនមួយច្បាប់ និង ត្រូវមានការបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម ដោយការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំដំបូងបង្អស់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំនៅព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីកាន់កាប់បញ្ជី អាចផ្តល់ពេលវេលាសមស្របបន្ថែម សម្រាប់ការផ្តល់ព័ត៌មានឯកសារ ឬ ពូជដំណាំ តាមការស្នើសុំ ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះមិនបានបំពេញត្រឹមត្រូវទេនោះ ការទាមទារសិទ្ធិអាទិភាពត្រូវចាត់ទុកថាមិនបានទាមទារឡើយ ។

## ផ្នែកទី ៥
## ការដាក់ឈ្មោះពូជដំណាំ និងការប្រើប្រាស់

**មាត្រា ២៦.–**

អ្នកដាក់ពាក្យសុំ ត្រូវដាក់ឈ្មោះពូជដំណាំស្របទៅតាមបទប្បញ្ញត្តិនៃផ្នែកនេះ ។

ឈ្មោះពូជថ្មីនៃដំណាំ ត្រូវចាត់ទុកថាមិនសមស្រប ក្នុងករណីដូចខាងក្រោម :

ក-មិនអាចសម្គាល់ពូជដំណាំបាន

ខ-មានសញ្ញាតែមួយ លើកលែងតែសញ្ញានោះ អាចសម្គាល់ពូជដំណាំបាន

គ-នាំឱ្យសាធារណជនយល់ខុស ឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ ឬ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជ

ឃ-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលមានរួចហើយក្នុងប្រភេទដំណាំតែមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋជាភាគីហត្ថលេខី

ង-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលទទួលបានសិទ្ធិមុន ។

មានតែឈ្មោះដែលបានប្រើក្នុងការស្នើសុំ ឬ ចុះបញ្ជី នៅរដ្ឋជាភាគីហត្ថលេខីទេ ដែលត្រូវប្រើសម្រាប់ការស្នើសុំ ឬ ចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែឈ្មោះដែលមានន័យមិនសមស្របតាមប្រពៃណីវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា អ្នកកាន់កាប់បញ្ជីអាចតម្រូវឱ្យផ្តល់ឈ្មោះថ្មីបាន ។

**មាត្រា ២៧.–**

បុគ្គលធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី ទោះបីជាសិទ្ធិការពារផុតសុពលភាពក៏ដោយ លើកលែងតែសិទ្ធិដែលទទួលបានមុនណាមួយរាំងដល់ការប្រើប្រាស់បែបនេះ ។

ពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬ ការបញ្ជាក់ប្រហាក់ប្រហែលផ្សេងទៀត អាចភ្ជាប់ជាមួយឈ្មោះពូជថ្មីនៃដំណាំដែលបានការពារនៅពេលដែលពូជនោះត្រូវបានធ្វើអាជីវកម្ម ។

**មាត្រា ២៨.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវលុបឈ្មោះពូជដំណាំដែលបានចុះបញ្ជីរួចហើយ ប្រសិនបើឈ្មោះនោះមិនគួរត្រូវបានចុះបញ្ជី ។ ករណីនេះ ម្ចាស់សិទ្ធិត្រូវស្នើឈ្មោះថ្មីសមស្រប ដើម្បីចុះបញ្ជី ។

**មាត្រា ២៩.-**

ត្រូវបានហាមឃាត់ :

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រើប្រាស់ឈ្មោះដែលបានចុះបញ្ជី ដោយចេតនា

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជាលើពូជផ្សេងទៀតនៃដំណាំក្នុងប្រភេទដំណាំតែមួយ ដោយចេតនា ។

## ផ្នែកទី ៦
## ការពិនិត្យពាក្យស្នើសុំ និងការបោះពុម្ពផ្សាយ

**មាត្រា ៣០.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យពាក្យសុំដើម្បីកំណត់ថា បានបំពេញនូវលក្ខខណ្ឌនៃភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព ។ នៅពេលដែលលក្ខខណ្ឌទាំងនោះមិនត្រូវបានបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធពាក្យស្នើសុំ ។

ក្នុងគោលបំណងកំណត់ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ។

